ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 13-Jan-2012, 15:27
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី ជំនុំជម្រះនៅដំណាក់កាលដំបូង

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១២ ខែមករា ឆ្នាំ២០១២**

**ម៉ោង ០៩: ០៩នាទី**

**សវនាការលើកទី១៤**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាតេអូ គ្រីប៉ា
*(Mr.Matteo CRIPPA)*

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក វេង ហ៊ត់

លោក ច័ន្ទ តារាវស្ស៊ី

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្ដម

លោក ម៉ៃខល កាណាវ៉ាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ពេជ អង្គ

លោក ហុង គឹមសួន

លោក ឡោ ជុនធី

លោកស្រី ម៉ុច សុវណ្ណារី

លោក វ៉េន ពៅ

លោកស្រី ទីស្រ៊ីនណា

លោកស្រី ស៊ីន សុវ៉ន

លោក សំ សុគង់

លោកស្រី នូស៊ីន សាកាវ៉ាទី

*(Ms. Nushin SARKARATI)*

លោក បាណាបេ ណេគ្វី

*(Mr. Barnabé NEKUIE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក អាប់ឌុលឡាក់ ថារីក | អង់គ្លេស |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោក នួន ជា | ខ្មែរ |
| លោក ខៀវ សំផន | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅ ជនជាប់ចោទ នួន ជា**

សួរដោយលោក ឌេល លីសាក់ ផ្តើមពី ....................................................................ទំព័រ ០៦

**ការសួរសំណួរទៅ ជនជាប់ចោទ ខៀវ សំផន**

សួរដោយលោក ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី....................................................ទំព័រ ៥០

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៩:២៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការពិនិត្យដេញដោលលើភស្តុតាង។ មុននឹងចាប់ផ្តើមកិច្ចពិភាក្សាដេញដោលអង្គជំនុំជម្រះសូមរំឭកដល់ភាគីថា ដើម្បីឲ្យកិច្ចដំណើរការពិភាក្សាដេញដោលប្រព្រឹត្តទៅត្រឹមត្រូវច្បាស់លាស់ល្អ ភាគីនានាគប្បីចងចាំ និងអនុវត្តឲ្យបានល្អតាមសំណើរបស់អង្គភាពបកប្រែភាសា ដើម្បីធានាដល់ការធ្វើប្រតិចារឹកកិច្ចដំណើរការនីតិវិធីដូចខាងក្រោម៖

ភាគីគប្បីចងចាំថា នៅអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺប្រើប្រាស់បីភាសា និងមានចម្រុះវប្បធម៌។ ដូច្នេះនៅពេលភាគីឡើងធ្វើការតាំងសំណួរបង្ហាញអត្តសញ្ញាណឯកសារ ឬធ្វើសេចក្តីថ្លែងការណ៍ប្តឹងសុំ សូមឲ្យនិយាយឲ្យបានយឺតៗ ហើយច្បាស់លាស់។ គប្បីអាននូវតួលេខ កាលបរិច្ឆេទឲ្យបានយឺត ហើយច្បាស់ ប្រសិនបើអាចធ្វើបានសូមឲ្យអានបញ្ជាក់សាជាថ្មីម្តងទៀត។

[០៩:១១:១៩]

គប្បីប្រកបឈ្មោះទាំងឡាយដែលមានអក្ខរាវិរុទ្ធច្រើន ឬក៏ពិបាកសរសេរ។ ជាពិសេសភាគីអន្តរជាតិដែលអានឈ្មោះបុគ្គលដែលពាក់ព័ន្ធនៅក្នុងសំណុំរឿងជាជនជាតិខ្មែរ។ អ៊ីចឹងសូមឲ្យអានឲ្យបានច្បាស់លាស់ បើមិនដូច្នោះទេ គឺនាំឲ្យមានការសង្ស័យទាំងការឆ្លើយ ទាំងការសរសេរចូលប្រតិចារឹកវាជួបប្រទះនឹងការលំបាក។ ភាគីត្រូវបើកកុងតាក់មីក្រូហ្វូនជាមុនសិន មុននឹងផ្តើមនិយាយ។ បញ្ហានេះយើងបានរំឭកច្រើនលើកច្រើនសាហើយ ប៉ុន្តែអំឡុងពេលថ្មីៗនេះឃើញថា បញ្ហានេះគឺនៅតែអត្ថិភាពនៅក្នុងកិច្ចពិភាក្សាដេញដោលនៃអង្គជំនុំជម្រះយើងដដែល។ អង្គជំនុំជម្រះសង្ឃឹមថា ភាគីទាំងអស់ដែលចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីនឹងខិតខំប្រឹងប្រែងអនុវត្តឲ្យបានល្អទាំងអស់គ្នា។

[០៩:១២:៣៨]

អនុរក្សាមន្ទីរឃុំឃាំងនាំលោក នួន ជា មកកាន់ឈើរាងរង់ក្រចកសេះនៅពីមុខអង្គជំនុំជម្រះ។

*(ជនជាប់ចោទ នួន ជា ទៅកាន់ឈើរាងរង់ក្រចកសេះ)*

អញ្ជើញលោក អាង ឧត្តម!

[០៩:១៣:០៥]

**លោក អាង ឧត្តម៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមទាញចំណាប់អារម្មណ៍លើសេចក្តីណែនាំរបស់លោកប្រធានអំមិញបន្តិច។ ខ្ញុំឮថា ឲ្យបុគ្គលិកនៅទីនេះធ្វើពេលអាន ពាក្យខ្មែរ ឈ្មោះខ្មែរឲ្យច្បាស់ៗ ខ្ញុំគិតថាប្រហែលជាពួកគាត់មិនអាចអានចំ ឬត្រូវច្បាស់ទេ។ ឧទាហរណ៍ដូចជា កន្លងមកលោកព្រះរាជអាជ្ញាគាត់អានឈ្មោះ ខឹម ងួនៗ គឺអត់ត្រូវ ហើយមានការឆ្លើយឆ្លងគ្នាច្រើន ប៉ុន្តែសម្រួលចំណុចនេះ នៅពេលដែលមានឈ្មោះខ្មែរ គួរតែអស់លោកអ្នកនិយាយឈ្មោះហ្នឹង ឲ្យសហការី ឬសហភាគារបស់ខ្លួនជាខ្មែរហ្នឹងជួយអានឲ្យត្រូវតែម្តងទៅវាលឿនជាង។ បើឲ្យបរទេសអានឈ្មោះខ្មែរ ខ្ញុំថាអាចពិបាកនឹងត្រូវ និងពិបាកនឹងចំ។ បើសិនជាឲ្យសហភាគាដែលនៅអង្គុយក្បែរជួយអានឲ្យចំតែម្តងនឹងលឿនជាង។

សូមអរគុណលោកប្រធាន។

[០៩:១៤:១១]

**ប្រធានអង្គជំនុំ៖**

អរគុណនូវការផ្តល់គំនិតយោបល់ដូច្នេះ ដែលអង្គជំនុំជម្រះកំណត់ឲ្យខិតខំប្រឹងប្រែង អង្គជំនុំជម្រះយល់ថា ភាគីសុទ្ធតែបានត្រៀមខ្លួនជាស្រេចនៅក្នុងការតាំងសំណួរ ចំពោះភាគីដែលពាក់ព័ន្ធនៅក្នុងរឿងក្តី។ អ៊ីចឹងបើសិនជាជួបនូវឈ្មោះមនុស្ស ឬក៏ឈ្មោះទីកន្លែង គឺអាចអានសាកល្បងនៅក្នុងការិយាល័យរបស់ខ្លួន ហើយប្រឹងកែសម្រួល។ នេះគឺជាបំណង បានន័យថាខិតខំ មិនបណ្តោយឲ្យ--ធម្មតា មិនបានពញ្ញាក់ មិនបានប្រាប់ថាអ្នកឯងអានហ្នឹងមិនត្រូវទេ ត្រូវអានម្តងទៀត ដើម្បីឲ្យបានច្បាស់លាស់ ហាត់សមតាំងពីនៅការិយាល័យឯណោះ មិនមែនមកហាត់សមនៅទីនេះទេ កន្លែងនេះមិនមែនកន្លែងហាត់សមទេ។ ហើយក៏សូមអរគុណដែរ លើចំណុចចុងក្រោយនេះក្នុងករណីចាំបាច់អង្គជំនុំជម្រះនឹងផ្តល់លទ្ធភាពនេះទៅឲ្យភាគីជាតិ ដើម្បីបំពេញបន្ថែម។ យើងនឹងប្រើប្រាស់មធ្យោបាយនេះបន្ថែមទៀត។ ប៉ុន្តែគឺបញ្ហាវាមានច្រើនទាំងឈ្មោះបុគ្គលដែលពាក់ព័ន្ធ ទាំងទីកន្លែង។ អ៊ីចឹងគឺប្រសិនបើយើងធ្វើរបៀបនេះច្រើនដោយមិនបាច់ប្រុងប្រយ័ត្នក្នុងការកំណត់ ក្នុងការអានឲ្យបានច្បាស់ ឬក៏វាមិនដូច ក៏វាខិតជិតដែលអាចយល់បាននោះទេ។ នោះវានឹងនាំឲ្យតម្រូវការអាចបន្ថែមបុគ្គលិកមួយទៀតសម្រាប់គ្រាន់តែអាន នោះអាចចំណាយពេលវេលាច្រើនទៀត។ ប៉ុន្តែក្នុងករណីចាំបាច់យើងនឹងអនុវត្ត

ដូច្នេះ។ សូមអរគុណ។

[០៩:១៦:០៨]

មុននឹងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញា អង្គជំនុំជម្រះសូមជម្រាបសួរទៅសហព្រះរាជអាជ្ញាថា តើសហព្រះរាជអាជ្ញាត្រូវការពេលវេលាប៉ុន្មានទៀត ដើម្បីក្នុងការតាំងសំណួរចំពោះជនជាប់ចោទ នួន ជា នៅក្នុងអង្គហេតុវគ្គទីមួយដែលសម្រាប់ធ្វើសវនាការដេញដោលនេះ។ គឺកម្រិតត្រឹមវគ្គមួយ គឺប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា អង្គជំនុំជម្រះមានបំណងថាឱ្យសហព្រះរាជអាជ្ញានូវពេលវេលាមួយព្រឹកនេះក្នុងការសួរដេញដោលចំពោះ នួន ជា សម្រាប់អង្គហេតុវគ្គមួយ។ តើសហព្រះរាជអាជ្ញាមានមតិយោបល់យ៉ាងណាដែរ?

[០៩:១៧:១៥]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ជាការពិត គឺយើងបានដឹងអំពីភាពចាំបាច់ដែលត្រូវធ្វើដំណើរការទៅឱ្យបានលឿនតាមដែលអាចធ្វើទៅបាន។ ដូច្នេះខ្ញុំនឹងព្យាយាមបញ្ចប់នៅក្នុងព្រឹកនេះ យើងបានសួរច្រើនទៅលើបញ្ហាពាក់ព័ន្ធទៅនឹងគោលនយោបាយ ជាពិសេសនៅក្នុងទសវត្សរ៍ទី៦០។ ដូច្នេះគឺខ្ញុំនឹងផ្តល់ជូននូវព័ត៌មានថា តើចំណុចណាខ្លះដែលខ្ញុំនឹងសួរនៅក្នុងព្រឹកនេះ ជាពិសេសខ្ញុំនឹងសួរអំពីកងការពារសម្ងាត់ ហើយខ្ញុំនឹងលើកឡើងអំពីហេតុការណ៍នៃមហាសន្និបាតឆ្នាំ១៩៦៣ និងទសវត្សរ៍៦០។ ដូច្នេះសំណួរដែលខ្ញុំចង់សួរនោះ គឺជាសំណួរដែលសួរបន្ត និងបញ្ជាក់ឱ្យច្បាស់ទៅលើហេតុការណ៍ទាំងឡាយដែលបានកើតឡើង និងពាក់ព័ន្ធទៅនឹងគោលនយោបាយនៅក្នុងសម័យនោះ។

ដូចគ្នានេះផងដែរ គឺខ្ញុំនឹងសួរអំពីចំណុចពាក់ព័ន្ធទៅនឹងហេតុការណ៍ដែលវាកើតឡើងក្នុងទសវត្សរ៍ទី៧០ផងដែរ។ ចំណុចចុងក្រោយ ខ្ញុំនឹងសួរអំពីបញ្ហាគោលនយោបាយដែលបានបង្កើតឡើងពាក់ព័ន្ធទៅនឹងសហករណ៍ និងបញ្ហាប្រជាជននៅក្នុងទសវត្សរ៍ទី៧០ និងឆ្នាំ៧៥។

ដូច្នេះបញ្ហាទាំងអស់ដែលនៅសល់នេះ គឺខ្ញុំជឿថាចំណុចទាំងអស់នេះវាសំខាន់ណាស់ ហើយខ្ញុំនឹងព្យាយាមសួរឱ្យបានច្រើនទៅលើជនជាប់ចោទរូបនេះ។ ហើយធ្វើយ៉ាងណាដើម្បីឱ្យយើងទទួលបានចម្លើយផ្ទាល់តែម្តងទៅនឹងសំណួរដែលយើងបានចោទសួរ។ ហើយយើងខ្ញុំក៏សង្ឃឹមថា ជនជាប់ចោទនឹងសហការជាមួយយើង ដើម្បីឱ្យយើងអាចសួរឱ្យបានច្រើនជាងនេះ។

[០៩:១៩:០៧]

ដូច្នេះខ្ញុំនឹងព្យាយាមធ្វើយ៉ាងណាឲ្យបានសួរឲ្យបានច្រើន ហើយឲ្យបានចប់សព្វគ្រប់។ ខ្ញុំសង្ឃឹមថា ខ្ញុំនឹងជម្រាបនូវព័ត៌មានណាខ្លះ ប្រធានបទណាខ្លះដែលខ្ញុំនឹងសួរនៅក្នុងព្រឹកនេះ ហើយប្រសិនបើចំពោះចំណុចណាដែលអង្គជំនុំជម្រះគិតថាមិនពាក់ព័ន្ធនោះអាចជម្រាបមកខ្ញុំបាន ហើយខ្ញុំនឹងអាចរំលងហើយចូលទៅដល់ចំណុចមួយទៀត។

ខ្ញុំគិតថាខ្ញុំបានឆ្លើយតបទៅនឹងការណែនាំរបស់លោកប្រធាន។ សូមអរគុណ។

[០៩:១៩:៣៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ! សូមអញ្ជើញលោក នួន ជា!

**លោក នួន ជា៖**

សូមគោរពលោកប្រធាន នៅមុនពេលយើងបន្តសវនាការព្រឹកនេះ ខ្ញុំមានមតិខ្លីមួយ ដែលខ្ញុំចង់លើកឡើងទាក់ទងនឹងរឿងឯកសារ។ ជាដំបូង ខ្ញុំចង់និយាយម្តងទៀត ដើម្បីកត់ត្រាទុកថា ខ្ញុំមិនអាចគិតពីយថាភាពអំពីឯកសារថតចម្លង ដែលបង្ហាញមកខ្ញុំនៅក្នុងពេលសវនាការសួរដេញដោលនេះបានទេ។

អាស្រ័យហេតុនេះហើយ ខ្ញុំសូមរក្សាសិទ្ធិរបស់ខ្ញុំដើម្បីជំទាស់ទៅនឹងយថាភាពនូវរាល់ឯកសារដែលបង្ហាញមកខ្ញុំ ឬក៏ដាក់នៅចំពោះមុខអង្គជំនុំជម្រះដោយភាគីនានា ក៏ដូចជាដាក់ដោយខ្ញុំ ឬក៏តាមរយៈមេធាវីរបស់ខ្ញុំនៅគ្រប់ពេល រហូតដល់ចប់សំណុំរឿង។

ខ្ញុំធ្វើសេចក្តីថ្លែងការណ៍នៅពេលនេះ គឺជាទូទៅដើម្បីចៀសវាងលើកឡើងពីជំហររបស់ខ្ញុំជាដដែលៗ នៅពេលខាងមុខទៀត។ តែទោះបីជាយ៉ាងណាក៏ដោយ ខ្ញុំមានបំណងពិនិត្យនូវឯកសារដែលសហព្រះរាជអាជ្ញាមានបំណងបង្ហាញមកខ្ញុំ និងដើម្បីពន្យល់ជាបឋមអំពីឯកសារ បើទោះជាខ្ញុំអាចនឹងធ្វើការជំទាស់ទៅនឹងយថាភាពរបស់ឯកសារទាំងនោះនៅពេលក្រោយក៏ដោយ។ ដើម្បីធ្វើដូចនេះ ក្នុងវិធីដោយមានប្រសិទ្ធភាព ខ្ញុំសូមស្នើដល់អង្គជំនុំជម្រះបង្គាប់ដល់សហព្រះរាជអាជ្ញា ជូនដំណឹងដល់ខ្ញុំនូវឯកសារដែលចង់បង្ហាញឲ្យខ្ញុំឲ្យបានក្នុងពេលវេលាសមស្រប នៅពេលដែលមានបំណងសួររូបខ្ញុំទាក់ទងទៅនឹងឯកសារទាំងនោះ។ ធ្វើដូចនេះអាចឲ្យខ្ញុំពិនិត្យពិច័យយ៉ាងម៉ត់ចត់ និងដាក់ការសន្និដ្ឋានដ៏មានប្រយោជន៍ទៅលើឯកសារទាំងនោះនៅក្នុងតុលាការ។

[០៩:២៣:១៣]

នៅក្នុងករណីដែលឯកសារវែង ខ្ញុំសូមស្នើដល់ព្រះរាជអាជ្ញាបញ្ជាក់នូវចំណុចដែលពាក់ព័ន្ធផង។

រហូតមកដល់ពេលនេះ ខ្ញុំមានការលំបាកក្នុងការពិនិត្យឯកសារដែលបង្ហាញមករូបខ្ញុំនៅក្នុងសវនាការ។ ព្រោះខ្ញុំមិនត្រូវបានផ្តល់ឲ្យនូវពេលវេលាគ្រប់គ្រាន់ដើម្បីអាន និងពិចារណានូវមុនពេលត្រូវបានសួរលើឯកសារនោះទេ។ ដោយសារតែបញ្ហានេះ ខ្ញុំមើលឃើញថា ខ្ញុំលំបាកយល់សំណួរជាច្រើនរបស់ព្រះរាជអាជ្ញាដែលសួរចេញពីឯកសារ។

ខ្ញុំជឿជាក់ថា សំណើរបស់ខ្ញុំនេះនឹងធានានូវការបង្ហាញភស្តុតាងរបស់ខ្ញុំដោយរលូន និងធានាផងដែរនូវសវនាការដ៏ឆាប់រហ័ស។

[០៩:២៤:៣២]

ជាថ្មីម្តងទៀត បើទោះជាខ្ញុំមានបំណងពន្យល់អំពីឯកសារ ដែលបង្ហាញដល់ខ្ញុំក្នុងសវនាការក៏ដោយ ក៏មិនមានន័យថា ខ្ញុំទទួលយកយថាភាពរបស់ឯកសារទាំងនោះទេ។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន។ ដោយសារថ្ងៃនេះលោកបានបង្ហាញនូវជំហរច្បាស់លាស់ ហើយមានសំណើមួយចំនួនដែលអង្គជំនុំជម្រះនឹងយកទៅពិចារណា។

ហើយបញ្ហាទាំងអស់នេះ បញ្ហាឯកសារ យថាភាពនៃឯកសារនេះអង្គជំនុំជម្រះបានសម្រេចរួចហើយ។ ហើយថ្ងៃនេះគឺលោក នួន ជា បានបង្ហាញច្បាស់លាស់ថា លោកនិយាយបញ្ហានេះជាលើកចុងក្រោយ ដោយសារបញ្ហានេះគឺនិយាយរឿងដដែលៗ ហើយអង្គជំនុំជម្រះបានសម្រេចរួចហើយ។ អង្គជំនុំជម្រះមិននិយាយដដែលទេ សម្រេចតែម្តងរួចហើយ ព្រោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះលុះត្រាតែមានសេចក្តីសម្រេចថ្នាក់លើដែលបដិសេធសេចក្តីសម្រេចរបស់ខ្លួនទើបវាអស់តម្លៃ។ ហើយអង្គជំនុំជម្រះបានជម្រាបរួចហើយកាលពីម្សិលមិញគឺថា ប្រសិនបើលោក មិនឆ្លើយតបទៅនឹងសំណួរដែលសហព្រះរាជអាជ្ញាសួរពាក់ព័ន្ធនឹងឯកសារដែលមាននៅក្នុងសំណុំរឿង នោះគឺអង្គជំនុំជម្រះចាត់ទុកថា លោករក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងសំណួរ។ ដូច្នេះសហព្រះរាជអាជ្ញា មិនបាច់រង់ចាំទេកាលបើគាត់រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបគឺលោកអាចប្រើសំណួរបន្តទៀត ដើម្បីពន្លឿនកិច្ចពិភាក្សាដេញដោល។

[០៩:២៦:៤៤]

ចំណែកឯសំណើថា សុំឲ្យព្រះរាជអាជ្ញាផ្តល់នូវឯកសារជាមុន ឲ្យបានមុនដើម្បីលោកពិនិត្យពិចារណានោះ អង្គជំនុំជម្រះនឹងពិនិត្យពិចារណាលើបញ្ហានេះជាក្រោយ។ ដោយមូលហេតុសប្តាហ៍ក្រោយយើងនឹងពិភាក្សាអំពីយថាភាពនៃឯកសារនេះផង ហើយនិងបញ្ហានីតិវិធីដែលគ្រោងនឹងរៀបចំដូច្នេះផង។ ប៉ុន្តែយ៉ាងហោចណាស់ឯកសារទាំងអស់នេះ គឺបានធ្វើបីឆ្នាំមកហើយ។ ហើយមានទាំងជំនួយការរបស់មេធាវីលោក ដែលបានជួយជ្រោមជ្រែងកិច្ចការរបស់លោករហូតដល់បួនរូបផងដែរ។

អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅសហព្រះរាជអាជ្ញា ប៉ុន្តែសហព្រះរាជអាជ្ញាសូមជ្រាបថាសហព្រះរាជអាជ្ញាមានទាំងជាភាគីអន្តរជាតិ ហើយនិងមានភាគីជាតិ។ អ៊ីចឹងចំណាយខិតខំធ្វើយ៉ាងណាដើម្បីពន្លឿននៃកិច្ចស៊ើបសួរដេញដោលនេះឲ្យបានឆាប់រហ័ស។

សូមអញ្ជើញ!

[០៩:២៨:០៣]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមបន្ថែមព័ត៌មានមួយទៀតទាក់ទងទៅនឹងការពន្យល់ទៅលើការតាំងសំណួរនេះ។ សហភាតាជាតិរបស់ខ្ញុំប្រហែលជាសុំរយៈពេលមួយម៉ោង មួយម៉ោងកន្លះ ដើម្បីធ្វើការតាំងសំណួរទៅកាន់ជនជាប់ចោទ។ លោក នួន ជា នៅពេលដែលយើងសម្រាកកាលពីម្សិលមិញយើងបានពិភាក្សាអំពីបញ្ហាកងការពារសម្ងាត់។ សំណួរបន្ទាប់ដែលខ្ញុំចង់សួរលោកនោះ គឺថាលោកបានលើកឡើងកាលពីសប្តាហ៍មុនលោកបានជម្រាបចៅក្រម ខាតវ៉ាយធ៍ ថាកងការពារសម្ងាត់នេះគឺមានអំណាចក្នុងការកម្ទេចគិញដែលជ្រៀតជ្រែកចូលនៅក្នុងកិច្ចប្រជុំរបស់បក្ស។

**ស៖** ខ្ញុំចង់សួរថាតើកងការពារសម្ងាត់នេះបានធ្វើយ៉ាងម៉េចទៅលើពួកគិញទាំងឡាយដែលបានចូលរុករានក្នុងកិច្ចប្រជុំរបស់បក្សនោះ?

[០៩:២៩:០៩]

**លោក នួន ជា៖**

**ឆ៖** ខ្ញុំសូមគោរពលោកប្រធាន។ បញ្ហានេះកម្ពុជាប្រជាធិបតេយ្យមានការប្រុងប្រយ័ត្នបដិវត្តន៍យ៉ាងខ្ពស់ចំពោះពួកក្បត់ដែលជ្រៀតចូលក្នុងអង្គការ សហករណ៍ក្តី នៅក្នុងប្រជាជនក្តី។ ដូច្នោះគេមានចាត់តាំងជាអ្នកស៊ើបការណ៍ពិនិត្យពិចារណាមនុស្សឲ្យបានច្បាស់លាស់ដែរ បានរាយការណ៍ឡើងទៅ

ថ្នាក់លើ ហើយថ្នាក់លើសម្រេចពិនិត្យពិចារណាម៉ត់ចត់ ទើបសម្រេច។ ឲ្យកងការពារសម្ងាត់នេះ មានវិធានការយ៉ាងម៉េចៗ ទៅតាមសភាពការណ៍ជាក់ស្តែង។

សូមជម្រាបលោកប្រធានប៉ុណ្ណឹង។

**ស៖** ថាតើអ្នកណាដែលគេបានប្រជុំពិភាក្សាគ្នា ថាធ្វើចាត់វិធានការយ៉ាងណា ដើម្បីកម្ទេចខ្មាំងនុ៎ង?

**ឆ៖** សូមជម្រាបលោកប្រធាន អ្នកដែលគេមានសិទ្ធិ គឺអ្នកដែលគេមានភារកិច្ចតាមដាន ពិនិត្យពិចារណា។ មនុស្សដែលមានសកម្មភាពគួរឲ្យ ឬនាំឲ្យសង្ស័យថាជាគិញបង្កប់។

[០៩:៣១:៣៧]

**ស៖** នៅពេលដែលគេរកឃើញថា បុគ្គលម្នាក់ជាគិញជ្រៀតចូលក្នុងបក្សនោះ ដូចដែលលោកបានជម្រាប។ ថាតើគេចាប់គិញនុ៎ងទៅដាក់ចូលនៅក្នុងមន្ទីរសន្តិសុខដែរឬទេ? ហើយគេឲ្យត្រឡប់ទៅវិញដែរឬទេ? ឬក៏គេសម្លាប់ចោល? ដូច្នេះថាតើអ្នកដែលកងការពារសម្ងាត់បានរកឃើញថា ជាគិញបង្កប់ចូល ជ្រៀតចូលបក្សនោះ ថាតើគេធ្វើអ្វីចំពោះគិញទាំងអស់នុ៎ង?

សូមអរ--

**ឆ៖** សូមជម្រាបលោកប្រធាន ច្បាស់ បើ-- បញ្ហានេះមិនមែនប្រើពេលវេលាខ្លីទេ ប្រើពេលវេលាយូរតាមដាន ជួនណាមានដល់មួយឆ្នាំ ពីរឆ្នាំ ហើយបញ្ជូនទៅឲ្យមន្ទីរ ស-២១។ មន្ទីរសន្តិសុខ គេពិនិត្យពិចារណា យកចម្លើយថែមទៀត។

[០៩:៣២:៥៨]

**ស៖** លោក នួន ជា ខ្ញុំចង់សួរអំពីរយៈពេលមុនខែមេសា ឆ្នាំ១៩៧៥។ ជាពិសេសរយៈកាលដែលយើងពិភាក្សានៅក្នុងទសវត្សរ៍ទី៦០ ដែលបក្សបានបង្កើតបក្សកងការពារសម្ងាត់។ ដូច្នេះនៅពេលនេះ ខ្ញុំសួរសំណួរបន្តទៅលើសំណួររបស់ខ្ញុំ ថាតើមន្ទីរសន្តិសុខត្រូវបានបង្កើតឡើងជាដំបូងដោយបក្សនោះនៅក្នុងឆ្នាំណាដែរ? ថាតើមានមន្ទីរសន្តិសុខណា ដែលត្រូវបានបង្កើតក្នុងទសវត្សរ៍ទី៦០ ឬក៏ទសវត្សរ៍៧០ មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដែរឬទេ?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនដឹងច្បាស់ទេ ពីព្រោះខ្ញុំមិនបានទទួលនាទីខាងសន្តិសុខ ពីព្រោះខ្ញុំទទួលនាទីខាងសភា។

[០៩:៣៤:១៤]

**សះ** ខ្ញុំដឹងថា លោកបានឆ្លើយថា លោកមិនទទួលខុសត្រូវទៅលើមន្ទីរសន្តិសុខនោះទេ ប៉ុន្តែលោកជាអនុលេខារបស់បក្ស។ ដូច្នេះខ្ញុំចង់សួរថា លោកបានដឹងដែរឬទេ ថាតើមានមន្ទីរសន្តិសុខទាំងឡាយណា ដែលបានបង្កើតមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដែរឬទេ?

**ឆះ** សូមជម្រាបលោកប្រធាន ខ្ញុំមិនបានដឹងទេ។

**សះ** តើលោកអាចជម្រាប អង្គជំនុំជម្រះដែរឬទេ ថាតើ ស-៣៩ នោះគឺជាអ្វីដែរ?

ឆះ ខ្ញុំសូមជម្រាបលោកប្រធានថា ខ្ញុំមិនដឹងទេ។

**សះ** តើលោកអត់ដែលធ្លាប់ឮអំពី ស-៣៩ ទេឬលោកនិយាយអ៊ីចឹង មែនទេ?

**ឆះ** សូមគោរពលោកប្រធានត្រូវហើយ ខ្ញុំដឹងតែភារកិច្ចគឺការងារអ្នកណាអ្នកនោះដឹង ភារកិច្ចអ្នកណាអ្នកនោះដឹង អ្នកដទៃមិនមានសិទ្ធិទៅជ្រៀតជ្រែកសួរកិច្ចការរបស់គេទេ ពីព្រោះខ្ញុំគិតគូរខាងអប់រំ។ អនុលេខាទទួលនាទីខាងអប់រំបក្ស។

**សះ** តើលោកបានដឹងថា មានការបង្កើត ម-១៣ មុនឆ្នាំ១៩៧៥ មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដែរឬទេ?

**ឆះ** ជម្រាបលោកប្រធាន ខ្ញុំមិនបានដឹងទេ។

**សះ** នៅពេលនេះ ខ្ញុំសូមសួរអំពីសន្និបាតបក្សលើកទីពីរ ដែលបានរៀបចំប្រជុំក្នុងឆ្នាំ១៩៦៣ តើលោកបានចាំដែរឬទេថាសន្និបាតទីពីររៀបចំប្រជុំនៅទីណាដែរ?

[០៩:៣៧:០២]

**ឆះ** សូមជម្រាបលោកប្រធាន សន្និបាតលើកទីពីរនេះ តាមខ្ញុំចាំរៀបចំនៅផ្ទះល្វែងផ្លូវឌីហ្គោល។

**សះ** តើផ្ទះល្វែងនេះជាផ្ទះល្វែងរបស់អ្នកណាដែរ?

**ឆះ** ជម្រាបលោកប្រធានផ្ទះរបស់អ្នកណាខ្ញុំមិនដឹងទេ ពីព្រោះជាផ្ទះជួល។ អ៊ីចឹងម្ចាស់គេឈ្មោះអីៗ ខ្ញុំមិនដឹងទេ។

**សះ** តើមានមនុស្សប៉ុន្មាននាក់ដែរ ដែលចូលរួមនៅក្នុងមហាសន្និបាតលើកទីពីរឆ្នាំ១៩៦៣ នេះ?

**ឆះ** ជម្រាបលោកប្រធាន បញ្ហានេះ ខ្ញុំក៏មិនបានចាំដែរ។

**សះ** តើលោកនៅចាំបានថា ចំនួនអ្នកចូលរួមនៅក្នុងសមាជលើកទីពីរនេះច្រើនជាងចំនួនអ្នកចូលរួមក្នុងសមាជទីមួយ ឬក៏ៗមានចំនួនដដែល?

**ឆះ** សូមជម្រាបលោកប្រធាន បើនិយាយពីចំនួនរួម ខ្ញុំយល់ឃើញថាច្រើនជាងបន្តិច។

[០៩:៣៩:១១]

**ស៖** លោកមាននៅចាំបានថា មានសមាជិកថ្មីៗ ឬក៏អ្នកថ្មីចូលរួមក្នុងសមាជលើក-- ចូលរួមសន្និបាតលើកទីពីរ ដែលមិនបានចូលរួមក្នុងសន្និបាតលើកទីមួយដែរឬទេ?

**ឆ៖** សូមជម្រាបលោកប្រធាន សូមលោកព្រះរាជអាជ្ញាបញ្ជាក់សំណួរថែមទៀត ខ្ញុំស្តាប់មិនទាន់។

**ប្រធានអង្គជំនុំ៖**

លោកព្រះរាជអាជ្ញាតាំងសំណួរចុងក្រោយអំមិញនេះសាជាថ្មីម្តងទៀត ដើម្បីឲ្យច្បាស់ ព្រោះជនជាប់ចោទស្តាប់សំណួររបស់លោកមិនទាន់ទេ។

[០៩:៤០:០៣]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** តើលោកមាននៅចាំថា មានអ្នកណាដែលបានមកចូលរួមនៅក្នុងមហាសន្និបាតលើកទី២ នេះដែលពីមុនមកគឺថា គាត់មិនធ្លាប់បានចូលរួមនៅក្នុងមហាសន្និបាតលើកទី១ទេ តើលោកនៅចាំបានទេ?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំនៅចាំមិនបានទេ ព្រោះវាច្រើនឆ្នាំមកហើយ។

**ស៖** បញ្ហាសំខាន់មួយ ដែលបានសម្រេចនៅក្នុងមហាសន្និបាតលើកទី២ គឺថាបោះឆ្នោតជ្រើសរើស ប៉ុល ពត ឲ្យធ្វើជាលេខាបក្ស។ ពីមុនលោកបានបញ្ជាក់ថា ហេតុផលដែល ប៉ុល ពត ត្រូវបានជ្រើសតាំងឲ្យធ្វើជាលេខាបក្ស ជាជាងការជ្រើសរើសរូបលោកនោះ ដោយសារតែរូបលោកមានជាប់ទាក់ទងជាមួយនឹង ស៊ីវ ហេង ដែលជាអតីតអគ្គលេខាធិការបក្ស ហើយគាត់បានចូលខ្លួនមកជាមួយនឹងសម្តេច សីហនុ នៅក្នុងឆ្នាំ១៩៥៨។ តើនេះជាហេតុផលដែលនាំឲ្យ ប៉ុល ពត ក្លាយទៅជាលេខាបក្ស ដោយសារតែមានមនុស្សនៅក្នុងក្រុមនោះបានចោទប្រកាន់លោកថា លោកមានជាប់ទាក់ទងជាមួយនឹង ស៊ីវ ហេង។

**ឆ៖** សូមជម្រាបលោកប្រធាន លក្ខណៈវិនិច្ឆ័យដើម្បីជ្រើសរើសជាលេខាបក្សមិនមែនមានតែមួយខហ្នឹងទេ មានច្រើនខទៅទៀត។ ខ្ញុំចាំខ្លះជាពិសេសគុណធម៌បដិវត្តន៍សមត្ថភាពដឹកនាំ ហើយនិងមានមហាជនឧបត្ថម្ភគាំទ្រ។ នេះម៉្យាង។ ចំណុចម៉្យាងទៀត អាយុបក្សក៏គិតដែរ ប៉ុន្តែជាបន្ទាប់ទេ។

[០៩:៤២:៣៨]

**ស៖** សំណួរខ្ញុំដែលសួរលោកនោះគឺថា ថាតើមានអ្នកដែលនៅក្នុងក្រុមហ្នឹងគឺថា បានចោទប្រកាន់លោកដោយសារថាលោកមានជាប់ទាក់ទង ឬក៏ជាប់សាច់ញាតិជាមួយនឹង ស៊ីវ ហេង តើដូច្នេះឬទេ?

**ឆ៖** សូមជម្រាបលោកប្រធាន នេះជាខមួយទេ។ ប៉ុន្តែខឯទៀតៗវាមានច្រើនខដែរ គឺសមត្ថភាពដឹកនាំ សមត្ថភាពនយោបាយ ប្រៀបធៀបនឹងលេខាបក្ស ប៉ុល ពត គាត់មានសមត្ថភាពច្រើនជាងខ្ញុំ។

**ស៖** តើអ្នកណាជាប្រធានក្រុមអ្នកដែលចូលរួមនៅក្នុងមហាសន្និបាតលើកទី២?

**ឆ៖** ជម្រាបលោកប្រធាន ខ្ញុំមិនយល់ប្រធានក្រុមយ៉ាងម៉េច? ខ្ញុំសូមលោកប្រធានជួយបញ្ជាក់។

[០៩:៤៤:០៧]

**ប្រធានអង្គជំនុំ៖**

លោកព្រះរាជអាជ្ញាតាំងសំណួរជាថ្មីឱ្យបានច្បាស់លាស់ ហើយសំណួរគប្បីពិនិត្យសំណុំរឿង ហើយប្រើពាក្យពេចន៍ ដែលមាននៅក្នុងឯកសារដើម្បីឱ្យយល់អំពីរចនាសម្ព័ន្ធ នៃការងារដើម្បីការប្រើពាក្យហ្នឹងវាត្រឹមត្រូវ។ កន្លងមកយើងមានពាក្យច្រើនណាស់ ដូចជាលេខា និងប្រធានហ្នឹង គេប្រើពេលណា។ លេខាគេប្រើពេលណានៅក្នុងបក្ស នៅក្នុងអាជ្ញាធររដ្ឋបាលអីជាដើម ហើយកន្លងមកថ្មីៗនេះគឺយើងប្រើពាក្យមិនច្បាស់លាស់ ដូចជាសមាជិកបក្ខជន ហើយសមាជិកមជ្ឈិម គណៈកម្មាធិការមជ្ឈិមបក្ស សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ជាដើម កាលណាតាំងសំណួរមិនត្រូវនោះគឺនាំឱ្យការឆ្លើយហ្នឹងក៏មិនបានត្រឹមត្រូវ ឬក៏មិនចំនូវគោលបំណងនៃការសួរដែរ។ ដូច្នេះសូមប្រើពាក្យពេចន៍ឱ្យចំនឹងគោលបំណងនៃការសួរនេះ។

សូមសួរម្តងទៀតបាទ!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមទោសលោកប្រធាន គាត់ថានៅក្នុងក្រុមអ្នកចូលរួម ហៅថាក្រុមប្រជាជន មានក្រុមប្រជាជន ដែលតាមការយល់របស់ខ្ញុំ ដូច្នេះខ្ញុំមិនដឹងថាតើខ្ញុំអានពាក្យពេចន៍នេះត្រឹមត្រូវឬក៏អត់ទេ។ កាលណាខ្ញុំនិយាយថា មនុស្សមួយក្រុមនេះ គឺជាមនុស្សដែលលោកបានលើកឡើងពីលើកមុនថាជាក្រុមប្រជាជន។ អ៊ីចឹងតើលោកយល់ទេ ក្រុមប្រជាជននេះ?

**ឆ៖** សូមជម្រាបលោកប្រធាន សូមអធ្យាស្រ័យ សូមអភ័យទោស អាចលោកព្រះរាជអាជ្ញាយល់ខុស យល់ច្រឡំ អត់ទោស។ ក្រុមប្រជាជន ជាក្រុមមួយផ្សេងដោយឡែក សម្រាប់ធ្វើការងារចំហ

ចេញ-- ដូចជាចេញកាសែត ចេញសេចក្តីថ្លែងការណ៍ចំហ អីៗអស់នេះ។ ក្រុមនេះធ្វើការងារចំហ។ ឯបក្សផ្សេងដោយឡែក។ បក្សកាលនោះនៅសម្ងាត់ ដូច្នោះកុំច្រឡំក្រុមប្រជាជន ហើយនិងបក្ស ពីរនេះខុសគ្នា។ ខ្ញុំសូមបញ្ជាក់ហើយ បញ្ជាក់ទៀត ដូចជាខ្ញុំបានបញ្ជាក់មកមុនហើយ។

[០៩:៤៧:០៣]

**ស៖** ខ្ញុំបានដឹងច្បាស់គឺ ហើយសំណួររបស់ខ្ញុំថាតើមានៗអ្នកណាដែលជាប់ទាក់ទងជាមួយនឹងក្រុមប្រជាជន ដូចជា កែវ មាស ដែលគាត់បានចូលរួមនៅក្នុងមហាសន្និបាតលើកទីពីរនេះ?

**ឆ៖** សូមជម្រាបលោកប្រធាន កែវ មាស ជាសមាជិកក្រុមប្រជាជនមិនបានចូលរួមក្នុងសមាជលើកទីពីរនេះទេ ពីព្រោះបានចែកគ្នាដាច់ហើយ។ ក្រុមប្រជាជនជាផ្នែកចំហ ឯមួយផ្នែកទៀត គឺខាងបក្ស មិនពាក់ព័ន្ធអីនឹងផ្នែកចំហទេ។ ខ្ញុំសូមបញ្ជាក់ម្តងទៀត។

**ស៖** សក្ខីកម្មរបស់លោកនោះគឺថា ដូច្នេះមិនមានអ្នកណាដែលជាប់ទាក់ទងជាមួយនឹងក្រុមប្រជាជនបានចូលរួមនៅក្នុងមហាសន្និបាតលើកទីពីរនេះទេ។ តើនេះត្រឹមត្រូវទេ?

**ឆ៖** សូមជម្រាបលោកប្រធាន ត្រឹមត្រូវហើយ!

**ស៖** ខ្ញុំសូមបញ្ជាក់ជាមួយលោកថា គឺថាមានៗការបោះឆ្នោតគណៈកម្មការជ្រើសរើស ដោយបានបោះឆ្នោតជ្រើសរើស ប៉ុល ពត ជាលេខាបក្ស ហើយលោកជាអនុលេខាបក្ស។ តើគណៈអចិន្ត្រៃយ៍នៅក្នុងមហាសន្និបាតលើកទីពីរដែលបានបោះឆ្នោតនេះ គឺថាបានបោះឆ្នោតសមាជិកគណៈអចិន្ត្រៃយ៍នេះរួមមានទាំង សោ ភឹម និង អៀង សារី ផងដែរទេ?

[០៩:៤៩:០៩]

**ឆ៖** សូមជម្រាបលោកប្រធាន ពាក្យថាបោះឆ្នោត ហើយនិងជ្រើសតាំង តែងតាំងនេះ វាខុសគ្នា។ ជ្រើសតាំង គឺជ្រើសរើសដោយគ្មានបោះឆ្នោតទេ ដោយគ្មានលើកដៃអីទេ។ នេះខ្ញុំគ្រាន់តែសូមបញ្ជាក់ទេ។ មានការជ្រើសតាំង តែងតាំង ឬក៏បោះឆ្នោតសម្ងាត់ៗ បោះឆ្នោតចំហ។ វាមានបីប្រភេទហ្នឹងតាមខ្ញុំចាំ។ ដូច្នេះដែលលោកព្រះរាជអាជ្ញាសួរនេះ តើសួរបោះឆ្នោត ឬក៏ជ្រើសតាំង ឬក៏តែងតាំង?

**ស៖** លោក នួន ជា លោកគឺជាមនុស្សម្នាក់ដែលមានវត្តមាននៅក្នុងមហាសន្និបាតលើកទីពីរនេះ។ អ៊ីចឹងខ្ញុំសួរទៅលោកវិញ ថាតើគេជ្រើសតាំង ឬក៏គេបោះឆ្នោតនាពេលនោះ?

**ឆ៖** សូមជម្រាបលោកប្រធាន ពេលនោះគឺជ្រើសតាំង។

**ស៖** តើវាត្រឹមត្រូវទេដែលថាគណៈកម្មាធិការអចិន្ត្រៃយ៍ដែលបានជ្រើសតាំងនោះគឺថាមានប៉ុល ពត ត្រូវបានជ្រើសតាំងប៉ុល ពត ជាលេខាបក្ស លោកជាអនុលេខាបក្ស និងអៀង សារី ជាសមាជិក តើនេះត្រឹមត្រូវដែរឬទេ?

**ឆ៖** សូមជម្រាបលោកប្រធាន ត្រឹមត្រូវហើយ។

**ស៖** តើមានអ្នកណាផ្សេងទៀតត្រូវបានជ្រើសតាំងឲ្យធ្វើជាសមាជិកពេញសិទ្ធិនៅក្នុងមហាសន្និបាតលើកទីពីរនេះដែរឬទេ? ឬក៏អាចបោះឆ្នោតជាសមាជិកបម្រុង ឬសមាជិកពេញសិទ្ធិក្នុងមហាសន្និបាតលើកទីពីរនេះដែរឬទេ?

**ឆ៖** សំណួរ-- សូមជម្រាបលោកប្រធាន សំណួរលោកព្រះរាជអាជ្ញាខ្ញុំពិបាកយល់ មានជ្រើសតាំងផង មានបោះឆ្នោតផង មានស្អីផង។ តើលោកសំដៅយកអីឲ្យច្បាស់លាស់មក ដើម្បីខ្ញុំស្រួលឆ្លើយ។ ពីព្រោះបើបោះឆ្នោតផង ជ្រើសតាំងផង តែងតាំងផង វាច្របូកវាច្របល់ វាមិនដឹងជាឯណាឯណីទេ។

[០៩:៥២:២០]

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញាអន្តរជាតិតាំងសំណួរចុងក្រោយនេះសាជាថ្មីម្តងទៀតដើម្បីឲ្យច្បាស់លាស់។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ប្រហែលជានេះដោយសារការបកប្រែ ខ្ញុំប្រើពាក្យថាចាត់តាំង ឬក៏ជ្រើសតាំងនេះ គឺថាក្រៅពីមនុស្សបួននាក់ដែលខ្ញុំបានលើកឡើងនេះ គឺថាមានអ្នកដទៃទៀតត្រូវបានចាត់តាំងឲ្យធ្វើជាសមាជិកបម្រុង ឬក៏សមាជិកពេញសិទ្ធិនៅក្នុងសមាជលើកទីពីរនេះ?

**ឆ៖** សូមជម្រាបលោកប្រធាន មាន។ ដែលខ្ញុំសូមបន្ថែមគឺ សោ ភឹម, តាម៉ុក, សុន សេន។ ហើយអ្នកណាទៀត ប៉ុន្មាននាក់ទៀត ខ្ញុំអាចភ្លេច។

**ស៖** ក្រៅពីការជ្រើសតាំងសមាជិកគណៈមជ្ឈិម និងសមាជិកអចិន្ត្រៃយ៍ថ្មីនេះ តើលោកមាននៅចាំថា មានបញ្ហាអ្វីផ្សេងទៀតត្រូវបានសម្រេចនៅក្នុងមហាសន្និបាតលើកទីពីរនេះដែរឬទេ?

**ឆ៖** តាមខ្ញុំចាំ ច្រឡំ ឬក៏ត្រូវ គឺកែប្រែឈ្មោះបក្ស ពីបក្សពលករកម្ពុជា មកជាបក្សកុម្មុយនីស្តកម្ពុជា។ នេះមួយ។

[០៩:៥៥:០០]

**ស៖** សូមអរគុណលោក នួន ជា។ ខ្ញុំសូមត្រឡប់ទៅរយៈពេលចន្លោះពីឆ្នាំ១៩៦៣ ទៅដល់៧៣ ខ្ញុំសុំឱ្យធ្វើការបញ្ជាក់អំពីទីតាំង ដែល ប៉ុល ពត ក៏ដូចជាថ្នាក់ដឹកនាំបក្សដទៃទៀតបានទៅរស់នៅពេលដែលពួកគេបានចាកចេញពីទីក្រុងភ្នំពេញ គិតមុនឆ្នាំ១៩៧៣។ នៅក្នុងសៀវភៅរបស់លោក ខៀវ សំផន ដែលនិយាយអំពីប្រវត្តិសាស្ត្រកម្ពុជាថា ប៉ុល ពត, អៀង សារី និង សុន សេន ត្រូវបានស្ថិតនៅក្នុងទីតាំងមួយនៅភូមិចំបក់ នៅខេត្តតែនីង នៅភាគ-- វៀតណាមភាគខាងត្បូង ដែលជាចលនារណសិរ្សរំដោះជាតិនៅវៀតណាមភាគខាងត្បូងនោះ។ តើនេះ គឺជាទីតាំងដំបូងដែល ប៉ុល ពត, អៀង សារី និង សុន សេន បានធ្វើដំណើរទៅស្នាក់នៅទីនោះមែនទេ?

**ប្រធានអង្គជំនុំ៖**

លោក នួន ជា ស្តាប់សំណួរបានទេ? សំណួរចុងក្រោយអម្បាញ់មិញ។ តាម--

[០៩:៥៧:១២]

**ជ៖** នៅព្រំដែនវៀតណាម ប៉ុន្តែដីខ្មែរជាប់ព្រំដែនវៀតណាម។

**ស៖** សំណួររបស់ខ្ញុំ ថាតើទីតាំងនោះជាទីតាំងនៅក្នុង-- ដែលជាទីតាំងចលនារំដោះជាតិរបស់វៀតណាមខាងត្បូង ឬក៏នៅក្បែរនោះ?

**ជ៖** សូមជម្រាបលោកប្រធាន នៅជិតនៅឆ្ងាយពីព្រោះជាការសម្ងាត់របស់គេ ខ្ញុំមិនដឹងទេ។

**ស៖** តើនេះមិនមែនជាការពិតទេឬ ដែលថាលោកគឺជាមនុស្សម្នាក់ដែលបាននាំ អៀង សារី និង សុន សេន ទៅកាន់មូលដ្ឋាននោះ ទៅកាន់ទីតាំងនោះ?

**ជ៖** សូមជម្រាបលោកប្រធាន មិនមែនខ្ញុំទេ។ ប៉ុន្តែជាគោលការណ៍សម្រេចរួម គឺប៉ុល ពត ឱ្យសម្រេចឱ្យចេញ ប៉ុន្តែអ្នកដែលគេទទួលភារកិច្ចខាងបច្ចេកទេសនាំចេញសម្ងាត់យ៉ាងម៉េចៗ ខ្ញុំមិនបានដឹងទេ។ ដឹងតែគោលការណ៍រួមថា ត្រូវចេញ។

[០៩:៥៩:១៣]

**ស៖** លោក ខៀវ សំផន ក៏បានសរសេរនៅក្នុងសៀវភៅរបស់គាត់។ សូមដកស្រង់៖ "នៅដើមឆ្នាំ១៩៧៤ សាឡុត ស បានបញ្ចុះបញ្ចូលវៀតកុងឱ្យចូលក្នុងប្រទេសកម្ពុជា រៀបចំទីកន្លែង ដើម្បីចៀសវាងទំនាស់ខាងនយោបាយ ដូច្នេះធ្វើឱ្យប្រទេសកម្ពុជា គឺថាអាចនឹងបង្កើតចលនាបដិវត្តន៍ដោយខ្លួនឯងបាន"។ ដែលនៅនោះយើងហៅថា មន្ទីរ១០០ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់វៀតណាម គឺឯកសារ D213.2 ERN ជាអង់គ្លេស 00498238 ជាភាសាបារាំង 00643842 និងERNជា

ភាសាខ្មែរ00380380 សំណួររបស់នេះគឺថា លោក នួន ជា ថាតើ ប៉ុល ពត, អៀង សារី និង សុន សេន ត្រូវបានចល័ត ឬក៏ជម្លៀសទៅកាន់ទីតាំងមួយនៅជិតព្រំដែនវៀតណាម។ ប៉ុន្តែនៅដើមឆ្នាំ១៩៧៤ នេះក៏បានបង្កើតនូវមន្ទីរមួយហៅថាមន្ទីរ១០០ នៅក្នុងទីតាំងនេះ។ តើនេះត្រឹមត្រូវដែរទេ?

**ជ៖** តាមខ្ញុំចាំដូចមិនត្រឹមត្រូវទេ។ ពីព្រោះឆ្នាំ៧៤ នោះតាមខ្ញុំចាំផ្លាស់មូលដ្ឋានទៅនៅខាងរតនគិរីណោះបាត់ទៅហើយ ឈប់នៅកន្លែងហ្នឹងទៀតហើយ ពីព្រោះខ្លាំងវាវាតត្បាតខ្លាំងណាស់។

**ស៖** លោក នួន ជា ខ្ញុំសូមចូលទៅអំឡុងពេលដែលមន្ទីរ១០០ បានបង្កើតនៅខេត្តរតនគិរី។ ឥឡូវនេះ ខ្ញុំសូមសួរទាក់ទងទៅនឹងរយៈពេលចន្លោះពី១៩៦៣ ទៅដល់៦៦ នៅពេលមន្ទីរ១០០នេះ គឺថាមានទីតាំងនៅជិតព្រំដែនវៀតណាម។ តើនៅក្នុងចន្លោះអំឡុងពេលនេះ លោកនៅចាំថាទីតាំងនៃមន្ទីរ១០០ស្ថិតនៅជិតព្រំដែនវៀតណាមដែរឬទេ?

[១០:០២:០៥]

**ជ៖** តាមខ្ញុំចាំ ពីព្រោះខ្ញុំមិនបានទៅនៅជាមួយទេ។ ខ្ញុំមិនដឹងទេ-- ប៉ុន្តែមន្ទីរនេះដែលខ្ញុំទៅធ្វើការម្តង ខ្ញុំធ្លាប់ទៅធ្វើការម្តងជាមួយ ប៉ុល ពត មន្ទីរនេះខ្ញុំមិនដឹងជានៅជិត ឬក៏នៅឆ្ងាយពីព្រោះភូមិសាស្ត្រព្រៃខ្ញុំមិនជំនាញទេ។ ប៉ុន្តែខ្ញុំឃើញថា ប៉ុល ពត មិនចង់នៅជិតវៀតណាមទេ ពីព្រោះកុំឲ្យមានការច្របូកច្របល់គ្នារវាងខ្មែរហើយនិងវៀតណាម ឲ្យដាច់ពីគ្នា។ វៀតណាមគេនៅខាងវៀតណាមទៅ ឯខ្មែរយើងនៅខាងខ្មែរយើងទៅគ្រាន់តែមានទាក់ទងគ្នាជាផ្លូវបក្ស ឬក៏ជាផ្លូវទាក់ទងគ្នារឿងអីផ្សេងៗ ប៉ុន្តែថាឲ្យនៅឡូកឡំលាយឡំជាមួយគ្នា អត់មានទេ។

**ស៖** នៅពេលដែលលោកជជែកលេងជាមួយនឹងលោក ខឹម ងន់ លោកបានជម្រាបលោក ខឹម ងន់ ថាលោកបានរៀបរាប់អំពីទីតាំងមន្ទីរ១០០ ដែលវានៅជិតព្រំដែនវៀតណាម។ លោកបានលើកឡើងថា "ខ្ញុំបានទៅវិញទៅមក ខ្ញុំនាំកម្មាភិបាលទៅធ្វើការនៅទីនោះ យកនាំពីកោះកុងទៅដល់ទីតាំងនោះ"។ ខ្ញុំអានឯកសារពី-- ខ្ញុំអានចេញពីឯកសារលេខ IS20.28 លេខERNជាអង់គ្លេស 00078197។ ដូច្នេះថាតើលោកបានធ្វើដំណើរជាញឹកញយទៅមន្ទីរ១០០ នោះដែរឬទេ ដែលមន្ទីរនោះនៅជិតព្រំដែនវៀតណាម? លេខ ERN ជាភាសាបារាំងគឺ 00596190 និងជាភាសាខ្មែរ គឺ 00184668។

[១០:០៤:៥៩]

**ជ៖** សូមជម្រាលោកប្រធាន តាមខ្ញុំចាំ យូរៗខ្ញុំទៅម្តងទេ មិនមែនទៅញឹកញាប់។ ឯមន្ទីរហ្នឹងវានៅឆ្ងាយពីគ្នាដែរ ពីព្រោះ ប៉ុល ពត គាត់មិនចង់នៅជិតវៀតណាមទេ។ ខ្ញុំសូមជម្រាបឲ្យច្បាស់។

**ស៖** លោក នួន ជា លោក ខៀវ សំផន បានសរសេរអំពីការប្រជុំបីដងរបស់គណៈជម្លឹម ដែលការប្រជុំនោះ គឺធ្វើឡើងនៅក្នុងមន្ទីរ១០០ នៅជិតព្រំដែនវៀតណាម គឺប្រជុំនៅក្នុងឆ្នាំ១៩៦៤, ៦៥ និង ៦៦។ ដូច្នេះខ្ញុំចង់សូមសួរកិច្ចប្រជុំនីមួយៗ របស់គណៈជម្លឹម។ ចំណុចទីមួយ ទាក់ទងទៅនឹងឆ្នាំ១៩៦៤ ដូច្នេះខ្ញុំសូមសួរដូចតទៅថា តើលោកបានចូលរួមប្រជុំរបស់គណៈមជ្ឈិម ឬក៏គណៈអចិន្ត្រៃយ៍នៅមន្ទីរ១០០ នៅក្នុងចន្លោះឆ្នាំ១៩៦៤ ដល់ឆ្នាំ១៩៦៦ ដែរឬទេ?

[១០:០៦:៣១]

**ឆ៖** សូមជម្រាបលោកប្រធាន ឆ្នាំ៦៤, ៦៥ ឬក៏ដល់ ៦៦ គឺ ប៉ុល ពត, អៀង សារី, សុន សេន នេះចេញពីមន្ទីរ១០០ នៅវៀតណាមនេះទៅខាងភូមិភាគឦសាន ដូចជាខ្ញុំបានជម្រាបមកហើយ។ ហេតុដូច្នោះពេលនោះ ប៉ុល ពត ខែតុលា ឆ្នាំ៦៥ ប៉ុល ពត ធ្វើដំណើរទៅហាណូយ ប៉េកាំងឯណោះទេ។

**ស៖** លោក នួន ជា តើត្រឹមត្រូវដែរឬទេ ដែលថារហូតមកដល់ឆ្នាំ១៩៦៦ ដែលថាក្រោយពីឆ្នាំ១៩៦៦ ទៅទើបមន្ទីរ១០០ នេះបានផ្លាស់ប្ដូរទីតាំងទៅរតនគិរី? តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ទៅរតនគិរី តាមខ្ញុំចាំមុនឆ្នាំ១៩៦៦។

**ស៖** ខ្ញុំចង់សួរអំពីគណៈអចិន្ត្រៃយ៍ នៅពេលដែលគេផ្លាស់ប្ដូរទីតាំងទៅរតនគិរីនោះ តើមានហេតុផលអ្វី ដែលគេប្ដូរមន្ទីរ១០០ ពីទីតាំងជិតព្រំដែនវៀតណាមនោះទៅរតនគិរី?

[១០:០៨:៥០]

**ឆ៖** តាមខ្ញុំ ព្រោះរតនគិរីជាភូមិសាស្ត្រល្អសម្រាប់ធ្វើជាមូលដ្ឋានបដិវត្តន៍ ហើយវាគ្មានខ្មាំងទៅដល់ផងទេ។ ដូច្នោះបានជាជ្រើសរើសយកភូមិភាគឦសានហ្នឹង គឺថារតនគិរីហ្នឹង ធ្វើជាមូលដ្ឋានបដិវត្តន៍របស់គណៈមជ្ឈិម។

**ស៖** តើលោកធ្វើដំណើរញឹកញយប៉ុនណាដែរទៅរតនគិរី ក្នុងអំឡុងពេលដែលមន្ទីរ១០០ដាក់ទីតាំងនៅរតនគិរីនោះ?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំទៅតែម្ដងទេ ពីព្រោះផ្លូវវាលំបាក មិនទាន់មានផ្លូវឡានផ្លូវអីទេ ទៅជើងដើរ ទៅមួយខែ មកមួយខែ។

[១០:១០:១៥]

**ស៖** ដោយសារតែត្រូវការចំណាយពេលច្រើនធ្វើដំណើរទៅរតនគិរី ដូច្នេះហើយ តើត្រឹមត្រូវដែរឬទេថា កិច្ចប្រជុំមួយចំនួនដែលលោកជួបប្រជុំជាមួយនឹងមេដឹកនាំដទៃទៀតក្នុងពេលដែលមន្ទីរ១០០

នៅរតនគិរីនោះ កិច្ចប្រជុំនៅទីនោះគឺមិនសូវជាប្រជុំញឹកញយនោះទេ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** សូមជម្រាបលោកប្រធាន ត្រឹមត្រូវហើយ។

**ស៖** ខ្ញុំសូមអនុញ្ញាតសួរឆ្នាំ១៩៦៤ ពាក់ព័ន្ធទៅនឹងកិច្ចប្រជុំរបស់គណៈមជ្ឈិម ដែលក្នុងពេលនោះលោក ខៀវ សំផន បានសរសេរនៅក្នុងសៀវភៅរបស់គាត់ថា គាត់លើកឡើងថា កិច្ចប្រជុំរបស់គណៈមជ្ឈិមនៅក្នុងឆ្នាំ១៩៦៤ ខែតុលា នោះ គឺមានរយៈពេលមួយអាទិត្យ ដែលពេលនោះ គឺធ្វើឡើងប្រជុំនៅក្នុងព្រៃជិតព្រំដែនវៀតណាម។ លេខ ERN-- របស់ខ្មែរគឺ 00380380 ភាសាអង់គ្លេសគឺ 603842 ហើយភាសាបារាំងគឺ 006404938238 (ស៊ីក) តើលោកមានបានចូលរួមប្រជុំនៅក្នុងឆ្នាំ១៩៦៤ ខែតុលា នោះដែរឬទេ?

[១០:១២:០៧]

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនបានចូលប្រជុំនឹងគេទេ។

**ស៖** លោក ខៀវ សំផន ក៏និយាយអំពីកិច្ចប្រជុំក្នុងខែមករា ឆ្នាំ១៩៦៥ នៅក្នុងពេលនោះ គឺបក្សបដិសេធមិនផ្លាស់ប្តូរចលនាពីប្រជាធិបតេយ្យទៅសង្គមនិយមនោះទេ។ តើលោកបានចាំទេ ថាលោកបានចូលរួមកិច្ចប្រជុំនៅក្នុងខែមករា ឆ្នាំ១៩៦៥ របស់គណៈមជ្ឈិម?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនបានចាំទេ។

**ស៖** ចំណុចចុងក្រោយលោក ខៀវ សំផន ក៏បានសរសេរលើកឡើងនៅក្នុងសៀវភៅរបស់គាត់ផងដែរថា "នៅក្នុងកិច្ចប្រជុំគណៈមជ្ឈិមឆ្នាំ១៩៦៦ នៅពេលនោះ គឺមានការចេញសេចក្តីសម្រេចចំនួនបី ទីមួយផ្លាស់ប្តូរឈ្មោះរបស់បក្ស ក្លាយទៅជាបក្សកុម្មុយនីស្តកម្ពុជា។ ចំណុចទីពីរ គឺសម្រេចថាផ្លាស់ប្តូរទីតាំងមូលដ្ឋានរបស់បក្សទៅរតនគិរី ហើយចំណុចទីបី គឺចូលរួមនៅក្នុងតស៊ូប្រដាប់អាវុធ"។ ឯកសារនេះមានលេខ D213.2 ឯកសារភាសាខ្មែរគឺ00380389 ដល់ 390 ហើយចំពោះអង់គ្លេសគឺ 004982243 តើលោកចាំថាលោកបានចូលរួមនៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការមជ្ឈិមនៅក្នុងឆ្នាំ១៩៦៦ ដែរឬទេ?

[១០:១៤:៣៩]

**ឆ៖** ក្នុងខែកញ្ញា សូមជម្រាប គោរពលោកប្រធាន ឆ្នាំ១៩៦៦ តាមខ្ញុំចាំចលនាវាឡើងខ្លាំងហើយ ដូច្នោះ ខ្ញុំក៏បានចូលរួមប្រជុំដែរ សម្រេចឲ្យមានការរួមផ្សំការតស៊ូនយោបាយ រួមផ្សំអាវុធដោយយកនយោបាយជាមូលដ្ឋានដដែល។ អាវុធគ្រាន់តែជាការពារខ្លួនប៉ុណ្ណោះទេ។

**ស៖** តើកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍នៅពេលនោះ គឺដូចគ្នាទៅនឹងកិច្ចប្រជុំរបស់គណៈមជ្ឈិមដែរឬទេ?

**ឆ៖** សូមជម្រាបលោក-- គោរពលោកប្រធាន! លោកព្រះរាជអាជ្ញាសួរ វារួមពេក ប្រជុំមជ្ឈិមហ្នឹងវាច្រើនដង ហើយប្រជុំហ្នឹងវាដូចជាប្រជុំមជ្ឈិមដែរឬទេ? ប្រជុំមជ្ឈិមពេលណា? អីណា? ពីព្រោះកិច្ចប្រជុំមជ្ឈិមហ្នឹងវាច្រើនដងដែរ។ មិនដឹងយកប្រជុំមជ្ឈិមខែណា? ឆ្នាំណា? ខ្ញុំពិបាកឆ្លើយដែរ។

[១០:១៦:២៥]

**ប្រធានអង្គជំនុំ៖**

លោកតំណាងព្រះរាជអាជ្ញាអន្តរជាតិសូមរៀបចំសំណួរសាជាថ្មី សម្រួលៗសំណួរធ្វើយ៉ាងណាឱ្យងាយយល់ដែលជាក់ច្បាស់ ដើម្បីឱ្យជនជាប់ចោទអាចសម្រេចឆ្លើយតបបាន ឬក៏គាត់សម្រេចចិត្តមិនឆ្លើយតបនោះជាសិទ្ធិរបស់គាត់។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកបាននិយាយអំពីការប្រជុំដែលលោកបានលើកឡើងថា មានការចេញសេចក្ដីសម្រេចប្រើប្រាស់ការតស៊ូអាវុធ ដោយសារនៅពេលនោះមានភាពតានតឹងក្នុងការតស៊ូប្រដាប់អាវុធនៅក្នុងឆ្នាំ១៩៦៦។ ដូច្នេះ ខ្ញុំសូមលើកឡើងសួរថាតើកិច្ចប្រជុំដែលលោកលើកឡើងថាមានការសម្រេចឱ្យការតស៊ូអាវុធនោះ គឺជាការប្រជុំរបស់គណៈអចិន្ត្រៃយ៍របស់គណៈមជ្ឈិម ឬក៏ការប្រជុំរបស់ខាងអង្គការបក្សណាដែរ?

[១០:១៧:៣៣]

**ឆ៖** សូមជម្រាបលោកប្រធាន ការសម្រេចនេះគឺប្រជុំអចិន្ត្រៃយ៍។

**ស៖** តើមាននរណាខ្លះចូលរួមនៅក្នុងការប្រជុំអចិន្ត្រៃយ៍នៅពេលនោះ?

**ឆ៖** ក្នុងពេលនោះ ខ្ញុំក៏មិនចាំដែរ ប៉ុន្តែមាន ប៉ុល ពត, មាន សុន សេន ហើយនិងមានកម្មាភិបាលមួយចំនួនទៀត។ ប៉ុន្តែកាលណោះ ដូចតាមខ្ញុំចាំ ប៉ុល ពត មិនបាននៅក្នុងប្រទេស-- ប៉ុល ពត ដូចជាធ្វើដំណើរទៅក្រៅប្រទេសទៅហើយ។ ប្រជុំរួច ប៉ុល ពត ធ្វើដំណើរទៅក្រៅប្រទេស។

**ស៖** តើលោក អៀង សារី បានចូលរួមនៅក្នុងការប្រជុំនោះដែរឬទេ?

**ឆ៖** សូមជម្រាបលោកប្រធាន លោក អៀង សារី មិននៅទេ។ គាត់ទៅនៅប្រចាំនៅក្រៅប្រទេសឯណោះទេ។

**ស៖** ចាតើលោក អៀង សារី ទៅធ្វើការនៅឯក្រៅប្រទេសក្នុងឆ្នាំ១៩៦៦ នោះគាត់ធ្វើអីដែរ?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំក៏មិនច្បាស់ដែរ គាត់ជាអ្នកតំណាងឲ្យបក្សកុម្មុយនីស្តកម្ពុជាទៅប្រចាំការនៅវៀតណាម ហើយនិងចិន ប៉ុន្តែធ្វើការល្អិតយ៉ាងម៉េចៗ ខ្ញុំមិនក្តាប់មិនបានទេ ខ្ញុំដឹងតែរួមប៉ុណ្ណឹង។

[១០:១៩:៤៥]

**ស៖** ចាតើការប្រជុំរបស់គណៈអចិន្ត្រៃយ៍នៅពេលនោះហ្នឹង ប្រជុំនៅទីណាដែរ?

**ឆ៖** ខ្ញុំសូមសួរលោកព្រះរាជអាជ្ញា ប្រជុំពេលនោះៗ ពេលណា? ពីព្រោះវាច្រើន។ សូមលោកព្រះរាជអាជ្ញាបញ្ជាក់ឲ្យច្បាស់។

**ស៖** យើងកំពុងតែនិយាយអំពីការប្រជុំរបស់គណៈអចិន្ត្រៃយ៍នៅក្នុងឆ្នាំ១៩៦៦។ ដូច្នេះខ្ញុំសូមសួរថាតើការប្រជុំរបស់គណៈអចិន្ត្រៃយ៍ក្នុងឆ្នាំ១៩៦៦នេះ គេប្រជុំនៅទីណាដែរលោក នួន ជា?

**ឆ៖** សូមជម្រាបលោកប្រធានការប្រជុំនៅក្នុងព្រៃ ខ្ញុំមិនចាំទេ។

**ស៖** ចាតើលោកចាំថា ការប្រជុំនៅក្នុងឆ្នាំ១៩៦៦នោះ នៅរតនគិរី ឬក៏នៅក្នុងមន្ទីរ១០០ ដែលនៅជិតព្រំដែនវៀតណាម តើនៅទីតាំងមួយណាដែរ?

**ឆ៖** ដូចជាខ្ញុំជម្រាបអ៊ីចឹងគឺថា ព្រំដែនហ្នឹងវាច្របូកវាច្របល់គ្នាណាស់។ ប៉ុន្តែខ្ញុំជឿជាក់ថាជាដីខ្មែរ មិនមែនដីវៀតណាមទេ។ ពីព្រោះនៅខាងនោះ ដូចជាលោក ប្រធានជ្រាបស្រាប់ហើយ វាមិនឯណាព្រំដែនខ្មែរ ឯណាព្រំដែនវៀតណាម វាព្រៃហើយវា សូម្បីតែភ្នាក់ងារខ្មែរយើងហ្នឹងក៏មិនដែលដើរទៅដល់ផង។

[១០:២២:១៦]

**ស៖** ខ្ញុំបានយល់អំពីអ្វីដែលលោកឆ្លើយលើបញ្ហាទីតាំង ដែលថា មន្ទីរនោះស្ថិតនៅក្នុងទីតាំងទឹកដីកម្ពុជា ឬក៏វៀតណាម។ ប៉ុន្តែខ្ញុំចង់សូមសួរលោក នួន ជា ថាតើការប្រជុំរបស់គណៈអចិន្ត្រៃយ៍ក្នុងឆ្នាំ១៩៦៦ នោះប្រជុំហ្នឹងគឺ ប្រជុំនៅទីតាំងដើមរបស់មន្ទីរ១០០ ឬក៏ប្រជុំក្រោយពីមន្ទីរ១០០នោះប្តូរទីតាំងទៅរតនគិរី?

**ឆ៖** សូមជម្រាបលោកប្រធាន ការប្រជុំចល័តឡើងចល័តចុះ មិនមែននៅមួយកន្លែងទេ។ ម្តងទៅប្រជុំនៅកន្លែងនេះ ម្តងទៅប្រជុំនៅកន្លែងនោះ។ ដូច្នោះឲ្យខ្ញុំកំណត់ថា នៅកន្លែងណាច្បាស់វាមិនច្បាស់ទេ ពីព្រោះពេលនោះ ខ្ញុំសូមជម្រាប កប៉ាល់ហោះបេ៥២នែ៎ ទម្លាក់គ្រាប់បែកសឹងតែរាល់ថ្ងៃរាល់យប់ហ្នឹង។ ដូច្នោះ នៅមួយកន្លែងមិនបានទេ។ សភាពការណ៍ ទាល់តែយល់សភាពការណ៍ហ្នឹងច្បាស់បានដឹងថា វាលំបាកវាអីយ៉ាងម៉េចៗ ប៉ុន្តែបើថាមិនដឹងច្បាស់ ទេខ្ញុំពិបាកជម្រាបដែរ ពីព្រោះមិនមែននៅមួយកន្លែងបានឯណា។ ដូច្នោះឲ្យកំណត់ថាត្រង់ណេះត្រង់ណោះ ភូមិនេះភូមិនោះក៏វាមិនបាន។ សូមជម្រាបលោកប្រធានប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ នៅពេលដែលមន្ទីរ១០០ ប្តូរទីតាំងទៅរតនគិរីតើត្រឹមត្រូវដែរឬទេ ថាលោក អៀង សារី ត្រូវបានជ្រើសតាំងជាលេខាបក្សនៃភូមិភាគឦសាន?

[១០:២៤:៤០]

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនចាំទេ។

**ស៖** ក្រោយពេលដែល ប៉ុល ពត, អៀង សារី និង សុន សេន និងមេដឹកនាំដទៃទៀត ដូរទីតាំងទៅរតនគិរី ថាតើការបែងចែកការទទួលខុសត្រូវនៅក្នុងប្រទេស រវាងលោក និងមេដឹកនាំដែលគាត់ទៅរតនគិរីនោះ តើមានការបែងចែកការទទួលខុសត្រូវក្នុងប្រទេសនេះយ៉ាងម៉េចដែរ?

**ឆ៖** សូមជម្រាបលោកប្រធាន ការបែងចែកការដឹកនាំនៅក្នុងប្រទេសចែកជាពីរផ្នែក។ ផ្នែកមួយ គឺខាងភូមិភាគឦសាន មានរតនគិរី មណ្ឌលគិរី ដូចជាមានក្រចេះ ស្ទឹងត្រែង ហើយនិង អីទៀត។ ឯខាងផ្នែកខាងក្រោមនេះ ផ្នែកទីពីរ គឺខ្ញុំទទួលខុសត្រូវដឹកនាំ ប៉ុន្តែអ្នកដែលទទួលផ្ទាល់នោះ គឺលេខាភូមិភាគគេទទួលផ្ទាល់ មាននិរតី ពាយព្យ បូព៌ា ឧត្តរ។ នេះគេចែកជាពីរផ្នែកអ៊ីចឹងការដឹកនាំ។

**ស៖** នៅក្នុងពេលដែលអំពី លោកលើកឡើងអម្បាញ់មិញនេះ គឺថាតើមានប៉ុន្មានភូមិភាគដែរ? វាដូចដែលលោកបានលើកឡើងថា ភូមិភាគឦសាន ភូមិភាគឧត្តរ ឬក៏ភូមិនិរតីជាដើម។ អ៊ីចឹងថាតើនៅក្នុងអំឡុងពេលនុ៎ងមានភូមិភាគប៉ុន្មានដែរ?

**ឆ៖** ខ្ញុំចាំមិនច្បាស់ដែរ ដូចមាន ប្រាំ-ប្រាំមួយភូមិភាគ។ ត្រង់នេះខ្ញុំសូមជម្រាបឲ្យច្បាស់។ ការចែកភូមិភាគនេះវាមិនទៀងទាត់ទេ។ វាសំដៅទៅបម្រើការដឹកនាំ បើដឹកនាំកន្លែងណាវាស្រួល-- បើដឹកនាំចាត់តាំងភូមិភាគយ៉ាងម៉េច ដើម្បីដឹកនាំឲ្យស្រួល ក៏ចែកជាភូមិភាគទៅ។ បើថាដឹកនាំវាពិបាកក៏ចូលរួមភូមិភាគតែមួយមក។ ឧទាហរណ៍ ខ្ញុំលើកឧទាហរណ៍ដូចជាកំពង់ឆ្នាំងនេះ។ កំពង់ឆ្នាំងនេះ

វានៅដាច់តែឯង ពីព្រោះវាជាប់មកខាងពោធិសាត់ មកខាងអីនេះផង-- ពោធិសាត់ កំពង់ឆ្នាំងនេះវាជាប់មកខាងពោធិសាត់នេះដែរ។ ដូច្នេះឱ្យវាស្តាប់ក្រឡាណ៍ា ខ្ញុំជម្រាបពិបាកជម្រាបណាស់ ពីព្រោះវាទៅតាមសភាពការណ៍ជាក់ស្តែងនៃការប្រយុទ្ធ។

[១០:២៨:៤៧]

**ស៖** ដូច្នេះ ក្នុងអំឡុងពេលនោះ គឺពេលដែលមន្ទីរ១០០ មានទីតាំងនៅរតនគិរី លោកទទួលខុសត្រូវលើទូទាំងប្រទេស លើកលែងតែភាគឦសានតែប៉ុណ្ណោះ ថាតើមានមេដឹកនាំណាផ្សេងទៀត ដែលនៅជាមួយលោកនៅក្នុងទីក្រុងភ្នំពេញដែរឬទេ?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនមែនទទួលដឹកនាំរួមហ្នឹងទេ។ ប៉ុន្តែជួយមើលការដឹកនាំឯអ្នកដែលគេដឹកនាំផ្ទាល់នោះគឺប្រធានភូមិភាគ ដូចជាខ្ញុំបានជម្រាបមកហើយ។ ក្រៅពីហ្នឹងក៏មានគណៈកម្មការក្រុងរបស់គេដែរ។

[១០:២៩:៥៨]

**ប្រធានអង្គជំនុំ៖**

លោកព្រះរាជអាជ្ញា ឥឡូវនេះដល់ម៉ោងសមល្មមនឹងសម្រាកហើយ។ ហើយមុននឹងសម្រាកអង្គជំនុំជម្រះសូមជម្រាបទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីថា សូមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី រៀបចំនូវសមាសភាពរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលលោកប្រគល់សិទ្ធិឱ្យសម្រាប់កិច្ចពិភាក្សាដេញដោល សម្រាប់បរិបទនីមួយៗ សម្រាប់ជនជាប់ចោទនីមួយៗ ឬក៏សម្រាប់គោលដៅនៃសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកជំនាញជាដើម ហើយស្នើសុំឱ្យប្រាប់មកអង្គជំនុំជម្រះជាមុន ចៀសវាងដល់ពេលលើកមតិជំទាស់ទៅ គុណភាពរបស់គាត់ហ្នឹងមិនទាន់មានត្រូវបានផ្ទេរនៅឡើយ។ នេះគឺសូមរៀបចំបញ្ហានេះឱ្យបានល្អ ដើម្បីឱ្យកិច្ចប្រតិបត្តិការក្នុងការពិភាក្សាដេញដោលរបស់យើងទៅថ្ងៃមុខមានប្រសិទ្ធភាព។

អង្គជំនុំជម្រះសូមប្រកាសសម្រាកម្ភៃនាទី ហើយចាប់ពីពេលនេះទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទីនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

*(សវនាការសម្រាកពីម៉ោង ១០:៣១ នាទី ដល់ម៉ោង ១០:៥២ នាទី)*

[១០:៥២:០៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ជាបន្តប្រគល់វេទិកាទៅសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរចំពោះជនជាប់ចោទ នួន ជា។ សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោក នួន ជា យើងបានពិភាក្សាគ្នានិយាយអំពីរចនាសម្ព័ន្ធ ឬក៏អង្គការចាត់តាំង ដែលមាននៅក្នុងអំឡុងពេល ប៉ុល ពត, អៀង សារី និង សុន សេន និងមន្ទីរ១០០ មានទីតាំងនៅរតនគិរី ហើយលោកបានរៀបរាប់អំពីភូមិភាគ គឺថាវាមានហើយ លោកក៏បាននិយាយថា មានគណៈកម្មាធិការក្រុងមួយ។ អ៊ីចឹងសំណួររបស់ខ្ញុំដំបូងនេះ គឺថាអ្នកណាជាអ្នកស្ថិតនៅ ឬក៏គ្រប់គ្រងគណៈកម្មការក្រុងពីឆ្នាំ១៩៦៦ ទៅដល់ ១៩៧០ នៅពេលដែលមានគណៈកម្មការក្រុងនោះ?

**លោក នួន ជា៖**

**ឆ៖** ខ្ញុំសូមជម្រាបលោកប្រធាន គណៈកម្មការក្រុងនេះ វាឯករាជ្យរបស់វានៅក្រោមការមើលជួយ ខ្ញុំគិត-- គ្រាន់តែជួយមើល ប៉ុន្តែការចាត់ចែងធ្វើការងារអី សម្រេចគណៈកម្មការក្រុងគេទេ។ ខ្ញុំដឹងត្រឹមប៉ុណ្ណឹង។ ខ្ញុំគ្រាន់តែមើលរួម។

**ស៖** សំណួររបស់ខ្ញុំ ថាតើអ្នកណាស្ថិតនៅក្នុងគណៈកម្មការក្រុងភ្នំពេញ នៅពេលដែលលោករៀបរាប់អំឡុងពេលចន្លោះពីឆ្នាំ១៩៦៦ ដល់១៩៧០ នោះ?

[១០:៥៥:០២]

**ឆ៖** សូមជម្រាបលោកប្រធាន មាន វន វេត។

**ស៖** តើលោកមាននៅចាំបានថាមានអ្នកណាផ្សេងទៀតក្រៅពី វន វេត ដែលស្ថិតនៅក្នុងគណៈកម្មការក្រុងនេះដែរឬទេ?

**ឆ៖** អ្នកឯទៀត-- គោរពលោកប្រធាន ខ្ញុំមិនស្គាល់ទេ ហើយក៏មិនចាំឈ្មោះផង ពីព្រោះការនេះគឺការសម្ងាត់របស់គេ។

**សៈ** តើវាត្រឹមត្រូវឬទេនៅពេលដែលមន្ទីរ១០០ ស្ថិតនៅរតនគិរី ដោយសារតែការលំបាក និងការធ្វើដំណើររយៈពេលយូរក្នុងអំឡុងពេលនោះ គឺថាមិនមានការប្រជុំរបស់គណៈមជ្ឈិមទេ តើនេះវាដូច្នេះមែនទេ?

**ផៈ** សូមជម្រាបលោកប្រធាន មែន!

[១០:៥៦:៥៧]

**សៈ** តើលោកមានទំនាក់ទំនង ឬក៏ការប្រាស្រ័យទាក់ទងណាមួយជាមួយនឹងលោក ខៀវ សំផន មុនឆ្នាំ១៩៦៧ តើលោកមានទំនាក់ទំនង-- មុនឆ្នាំ១៩៧៧ តើលោកមានទំនាក់ទំនងជាមួយ ខៀវ សំផន ទេ?

**ផៈ** សូមជម្រាបលោកប្រធាន ខ្ញុំគ្មានទំនាក់ទំនងអ្វីជាមួយលោក ខៀវ សំផន ទេ។

**សៈ** ខ្ញុំសូមសួរសំណួរពីរបីទៀត ទាក់ទងមុននឹងឆ្នាំ១៩៦៧ គឺថាមាន ខៀវ សំផន, ហ៊ូ នឹម ដែលបានភៀសខ្លួនចេញពីទីក្រុងភ្នំពេញ។ នៅក្នុងសៀវភៅដែលគាត់សរសេរឆ្នាំ២០០០ អំពីប្រវត្តិសាស្ត្រកម្ពុជា គឺលោក ខៀវ សំផន បាននិយាយថាគាត់បានចាកចេញពីទីក្រុងភ្នំពេញ។ សូមដកស្រង់សម្ដី៖ "យើងខ្ញុំបានទទួលសំណើរបស់បក្សកុម្មុយនីស្តកម្ពុជា ដើម្បីឲ្យយើងទៅជ្រកកោននៅជនបទ" ហើយគាត់ក៏បានបញ្ជាក់ផងដែរថា សំណើនោះបានផ្ញើមកឲ្យគាត់តាមរយៈលិខិតមួយដែលមាននីរសារមួយដែលគាត់ស្គាល់ ហើយនិងទុកចិត្តយកមកឲ្យគាត់។ នេះគឺជាឯកសារ IS4.2 ERN ជាភាសាខ្មែរ 001038 ទៅដល់ 821 អង់គ្លេស 0010373 ដល់ 1374 ហើយជាអង់គ្លេស 00595394 ដល់ 595395។

សំណួររបស់ខ្ញុំ តើលោកមានបានជួយសម្រួលដល់ ខៀវ សំផន និង ហ៊ូ នឹម ឲ្យគាត់ចាកចេញពីទីក្រុងភ្នំពេញនៅក្នុងឆ្នាំ១៩៦៧ នោះដែរឬទេ?

**ផៈ** សូមជម្រាបលោកប្រធាន ខ្ញុំមិនដឹងរឿងហ្នឹងទេ!

**សៈ** លោកមានចាំថាអ្នកណាបានសរសេរលិខិតដែលលោក ខៀវ សំផន បានលើកឡើងថាបក្សនឹងនាំគាត់ទៅកាន់ទីជនបទនោះ?

[១១:០០:០០]

**ផៈ** ខ្ញុំមិនដឹងទេ ជម្រាបលោកប្រធាន គោរពលោកប្រធាន។ ពីព្រោះមិនមែនភារកិច្ចរបស់ខ្ញុំដូចខ្ញុំជម្រាបអ៊ីចឹង ការងារអ្នកណា ការងារអ្នកនោះគេដឹង។

**ស៖** តើនេះជាចម្លើយរបស់លោក ដែលថាលោកមិនដឹងទាល់តែសោះ នៅពេលដែលបក្សបានជម្លៀសលោក ខៀវ សំផន ទៅឲ្យជ្រកកោននៅជនបទ។ តើលោកមិនដឹងទាល់តែសោះ ឬនៅក្នុងឆ្នាំ១៩៦៧នោះ?

**ជ៖** ជម្រាបលោកប្រធាន គោរពលោកប្រធាន។ ខ្ញុំមិនដឹងទាល់តែសោះ!

**ស៖** តើលោកនៅចាំបានទេថា ដោយសារតែការធ្វើដំណើរវាពិបាក និងវែងឆ្ងាយទៅរតនគិរី ហើយទំនាក់ទំនងជាមួយនឹងថ្នាក់ដឹកនាំនៅទីនោះ។ នៅចុងឆ្នាំ១៩៦៧ មានកិច្ចប្រជុំមួយនៅទីក្រុងភ្នំពេញ នៅផ្ទះ វន វ៉េត។ កិច្ចប្រជុំរវាងលោក, សោ ភឹម, តា ម៉ុក, តាមុំាង និង វន វ៉េន ហើយនិង គង់ សុផល ដើម្បីនិយាយគ្នា អំពីការចាប់ផ្ដើមការតស៊ូប្រដាប់វុធ។ តើលោកនៅចាំរឿងនេះបានទេ?

[១១:០១:៤៥]

**ជ៖** ខ្ញុំចាំមិនបានទេ សូមគោរពលោកប្រធាន។

**ស៖** លោកមាននៅចាំនៅពេលដែលលោកប្រាប់ទៅ ខឹម ងន់ នៅពេលលោកមានការពិភាក្សាជាមួយគាត់នៅក្នុងឆ្នាំ១៩៨៨។ ខ្ញុំយោងឯកសារ IS20.8 ERN ជាភាសាខ្មែរ 0078198 អង់គ្លេស 00184669 និង ERN ជាភាសាបារាំង 00596192។ លោកបានរៀបរាប់ជាមួយនឹងលោក ខឹម ងន់ ទាក់ទងទៅនឹងសេចក្ដីសម្រេច ដើម្បីចាប់ផ្ដើមការតស៊ូប្រដាប់អាវុធនៅក្នុងឆ្នាំ១៩៦៨ គឺកិច្ចប្រជុំនេះ ជាកិច្ចប្រជុំនៅចុងឆ្នាំ១៩៦៧ និយាយអំពីការចាប់ផ្ដើមការតស៊ូប្រដាប់អាវុធក្នុងឆ្នាំ១៩៦៨។

**ជ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនចាំទេ!

**ស៖** លោក នួន ជា ឥឡូវនេះ ខ្ញុំសូមត្រឡប់ទៅអំឡុងពេលបន្ទាប់ពីខែមីនា ឆ្នាំ១៩៧០ គឺព្រឹត្តិការណ៍រដ្ឋប្រហារនៅពេលនោះ ហើយចូលមកដល់ឆ្នាំ១៩៧២។ សំណួររបស់ខ្ញុំដំបូង គឺទាក់ទងទៅនឹងសម្ព័ន្ធភាពរវាងបក្ស គឺរវាងសម្ដេចនរោត្តម សីហនុ ដែលយើងនៅពេលនោះហៅថា សម្ព័ន្ធភាព ហ្រ្គុង ឬ ហ្វុង នេះ គឺសម្ព័ន្ធភាពនេះ គឺកើតមានឡើងដោយសារតែរដ្ឋប្រហារឆ្នាំ១៩៧០។

**ជ៖** គោរពលោកប្រធាន។ លោកសួរខ្ញុំថាម៉េច?

[១១:០៥:00]

**ស៖** សំណួរគឺបន្ទាប់ពីរដ្ឋប្រហារខែមីនា ឆ្នាំ១៩៧៥ ថាតើអ្នកណាជាអ្នកចាប់ផ្ដើមចរចាឲ្យមានសម្ព័ន្ធភាពរវាងបក្ស ហើយនិងសម្ដេចនរោត្តម សីហនុ នោះ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញ!

**លោក គង់ សំអុន៖**

សូមគោរពលោកប្រធាន អម្បាញ់មិញ ខ្ញុំឮដូចជាឆ្នាំ១៩៧៥ ការបកប្រែ។ អ៊ីចឹង សូមផ្ទៀងផ្ទាត់។ សូមអរគុណ។

[១១:០៥:៤៤]

**ប្រធានអង្គជំនុំ៖**

អ្នកបកប្រែរៀបចំនូវការបកប្រែឱ្យត្រឹមត្រូវកាលបរិច្ឆេទ ដូចខ្ញុំបានជម្រាបអ៊ីចឹង។ ហើយនិងបញ្ហាប្រើពាក្យឱ្យអស់ ដូចអំមិញយើងប្រើពាក្យថា "បក្ស" ជាមួយនរោត្តម សីហនុ នេះ មិនដឹងបក្សណាទេ។

ការបកប្រែឱ្យអស់សេចក្ដី ឲ្យចំបញ្ហា ហើយកាលបរិច្ឆេទនេះសំខាន់ណាស់ ម្សិលមិញមានបញ្ហានេះម្ដងហើយ បានរំឭកម្ដងហើយ។ សហព្រះរាជអាជ្ញាតាំងសំណួរសាជាថ្មីម្ដងទៀត ហើយប្រើពាក្យពេចន៍ឲ្យចំ ឲ្យច្បាស់ ឲ្យអស់សេចក្ដី។ ជាពិសេស គឺកាលបរិច្ឆេទ បើលោកកំណត់កាលបរិច្ឆេទ គឺសូមឲ្យបានច្បាស់លាស់ ហើយអ្នកបកប្រែភាសាដូចគ្នា។

ការដែលនាំឲ្យ ការកំណត់កាលបរិច្ឆេទខុសនេះ ឧទាហរណ៍ ឆ្នាំ១៩៧០ យើងកំណត់ទៅជា៧៥វិញ វាអត់មានព្រឹត្តិហេតុដែល នៃគោលបំណងនៃការសួរបានទេ។ អ៊ីចឹងសំណួរនេះវាឥតន័យ ហើយអត់អាចឆ្លើយ មិនដឹងឆ្លើយថារបៀបម៉េចទេ ពីព្រោះកាលបរិច្ឆេទហ្នឹង ៧៥ វាអត់មានរដ្ឋប្រហារទេ។

សូមព្រះរាជអាជ្ញាអន្តរជាតិតាំងសំណួរអម្បាញ់មិញនេះសាជាថ្មីម្ដងទៀត ហើយអ្នកបកប្រែរៀបចំឲ្យមានការប្រុងប្រយ័ត្នក្នុងការបកប្រែឲ្យបានពេញលេញ ហើយជាក់ច្បាស់។

[១១:០៧:០០]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** គឺខ្ញុំសំដៅទៅលើរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ សំណួររបស់ខ្ញុំគឺក្រោយពីរដ្ឋប្រហារនោះថា តើអ្នកជាអ្នកទទួលខុសត្រូវចរចាដើម្បីឲ្យមានសម្ព័ន្ធភាពរវាង ហ្នឹង គឺរវាងបក្ស ព្រះ

រាជអាជ្ញាប្រើពាក្យថា “បក្ស” គឺ បក្សកុម្មុយនីស្តកម្ពុជា ជាមួយនឹងសម្តេចនរោត្តម សីហនុ។

**លោក នួន ជា៖**

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនដឹងទេ ព្រោះខ្ញុំនៅឯស្រុកខ្មែរឯណោះ។ សម្តេច កាលណោះដូចខ្ញុំចាំនៅស្រុកចិន។

[១១:០៨:២០]

**ស៖** លោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ចលនាតស៊ូប្រដាប់អាវុធជាតិ។ លោកនៅអាចរៀបរាប់ជូនអង្គជំនុំជម្រះអំពីចលនាកងទ័ពរំដោះជាតិនេះបានទេ?

**ឆ៖** ខ្ញុំសូមសួរបញ្ជាក់លោក គោរពលោកប្រធាន រៀបរាប់យ៉ាងម៉េច? ពីព្រោះកងទ័ពគេមានរបស់គេទៅហើយ ពីព្រោះខ្ញុំមិនមែនកាន់ខាងកងទ័ព។ ខ្ញុំមិនកាន់ខាងកងទ័ពទេ ខ្ញុំជម្រាបហើយជម្រាបទៀត។ ខាងភូមិភាគ ប្រធានភូមិភាគទេ គេកាន់។

[១១:០៩:២៨]

**ស៖** តើមានតួនាទី លោកមានតួនាទី ឬក៏មុខងារអីនៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជា ឬក៏រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជានេះដែរឬទេ?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំគ្មាននាទីអីទេ។

**ស៖** តើលោកមានដឹងទេ ថាតើរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា មានរៀបចំកិច្ចប្រជុំអីនៅចន្លោះរវាងខែមីនា ១៩៧០ ទៅដល់ខែមេសា ១៩៧៥ ទេ?

**ឆ៖** សូមគោរពលោកប្រធាន ខ្ញុំមិនដឹងទេ!

**ស៖** តើមានតំណាងណាម្នាក់ដែលត្រូវបានចាត់តាំងឲ្យទទួលតួនាទី នៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជា ឬនៅក្នុងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជានោះដែរឬទេ?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនដឹងទេខាងរដ្ឋបាល!

**ស៖** ខ្ញុំគិតថា លោកមិនអាចជម្រាបជូនអង្គជំនុំជម្រះ អំពីតួនាទីរបស់លោក ខៀវ សំផន នៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជា ឬនៅក្នុងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជានេះបានទេ?

**ឆ៖** សូមជម្រាបគោរពលោកប្រធាន ខ្ញុំមិនដឹងតួនាទីគាត់ធ្វើអីទេ។

**ស៖** ខ្ញុំចង់សួរសំណួរមួយចំនួនទាក់ទងទៅនឹងអំឡុងពេលដែលបក្សមានមន្ទីរនៅរតនគិរី ហើយបានដូរមកស្ទឹងជីនិត បន្ទាប់ពីរដ្ឋប្រហារខែមីនា ១៩៧០ គឺថាបក្សបានផ្លាស់ប្តូរពីមន្ទីរ១០០ រតនគិរី

មកស្ទឹងជីនិត តើនេះត្រឹមត្រូវដែរទេ?

**ឆ៖** គោរពលោកប្រធាន ខ្ញុំមិនចាំទេ!

**ស៖** តើលោកមានចំណាយពេលវេលាណា នៅមន្ទីររបស់បក្សនៅស្ទឹងជីនិត នៅចន្លោះពីឆ្នាំ ១៩៧០ ដល់ឆ្នាំ១៩៧៥ ដែរឬទេ?

**ឆ៖** សូមជម្រាបលោកប្រធាន គោរពលោកប្រធាន។ ខ្ញុំមិននៅមួយកន្លែងទេ! ខ្ញុំចល័តឡើង ចល័តចុះ!

**ស៖** ខ្ញុំបានដឹងថា លោកផ្លាស់ប្តូរទីតាំងជាញឹកញាប់។ ប៉ុន្តែសំណួររបស់ខ្ញុំគឺថា មានមន្ទីររបស់ បក្សដែលស្ថិតនៅស្ទឹងជីនិត ដែលពេលនោះគឺថា លោកចំណាយពេលវេលាចន្លោះពីឆ្នាំ១៩៧០ ទៅដល់ ១៩៧៥ តើមែនទេ?

[១១:១៣:៤៦]

**ឆ៖** ដូចខ្ញុំជម្រាបហើយជម្រាបទៀត លោកសួរ-- ថាខ្ញុំមិននៅមួយកន្លែងទេ! បន្តិចខ្ញុំទៅនៅ ឯនោះ ទៅអប់រំកន្លែងនេះ បន្តិចចុះទៅភាគនេះ បន្តិចចុះទៅភាគខាងនោះ ហើយក៏ខ្ញុំក៏ចុះទៅអប់រំមក ខាងស្ទឹងជីនិតដែរ។ មកអប់រំមួយពេលពីរពេលអ៊ីចឹងទៅ ហើយខ្ញុំទៅកន្លែងផ្សេងទៀតទៅ។

**ស៖** តើនេះ ជាការត្រឹមត្រូវទេ ដែលបក្សបានបង្កើតសាលាបណ្តុះបណ្តាលនយោបាយមួយ នៅឯមន្ទីរនៅស្ទឹងជីនិតពីឆ្នាំ១៩៧០ ទៅដល់ឆ្នាំ១៩៧១ នោះ?

**ឆ៖** សូមជម្រាបគោរពលោកប្រធាន គ្មានសាលាទេ។

**ស៖** នៅពេលដែលលោកបើកវគ្គបណ្តុះបណ្តាលវគ្គនយោបាយនៅស្ទឹងជីនិត នៅក្នុងឆ្នាំ១៩៧០ ទៅឆ្នាំ១៩៧៥ នោះ តើលោកបើកវគ្គបណ្តុះបណ្តាលនោះនៅទីណា? តើលោកប្រើប្រាស់មន្ទីរមួយណា ដែលលោកប្រើប្រាស់បើកវគ្គបណ្តុះបណ្តាលនយោបាយនោះ?

**ឆ៖** គោរពលោកប្រធាន ជួនណាទៅពឹងពាក់ខាងមន្ទីរភាគរបស់គេ។

**ស៖** តើលោកមាននៅចាំមន្ទីរមួយហៅថា មន្ទីរ ស-៧១ នៅក្នុងចន្លោះពីឆ្នាំ១៩៧០ ទៅ១៩៧៥ ហ្នឹង លោកនៅចាំមន្ទីរស-៧១ ហ្នឹង ដែរឬទេ? មានទីតាំងនៅទីណា?

**ឆ៖** សូមគោរពលោកប្រធាន ខ្ញុំមិនចាំទេ។

**ស៖** នៅក្នុងកិច្ចសម្ភាសន៍ផ្តល់ចម្លើយជាមួយសហចៅក្រមស៊ើបអង្កេត លោក ខៀវ សំផន បាននិយាយថា គាត់បានជួយជាមួយលោក និង ប៉ុល ពត នៅក្នុងខែកញ្ញា ឆ្នាំ១៩៧០ នៅស្ទឹងជីនិត។

ហើយឯកសារយោងគឺសំណុំរឿង D46 ERN ជាអង់គ្លេស 00156744, REN ជាភាសាបារាំង 00156667, ERN ជាភាសាខ្មែរ 00156614។ សំណួររបស់ខ្ញុំលោក នួន ជា តើលោកនៅចាំមានកិច្ចប្រជុំមួយដែលលោក ខៀវ សំផន បានជួបលោកនៅក្នុងខែកញ្ញា ឆ្នាំ១៩៧០ នោះ លោកនៅចាំបានទេ?

[១១:១៧:៣៤]

**ឆ៖** សូមជម្រាបលោកប្រធាន គោរពលោកប្រធាន ខ្ញុំនៅចាំមិនបានទេ។

**ស៖** លោកមានបានដឹងថាតើលោក ខៀវ សំផន ស្ថិតនៅទីណាទេ ចន្លោះពីខែមីនា ១៩៧០ ដល់ខែមេសា ១៩៧៥?

**ឆ៖** គោរពលោកប្រធាន ខ្ញុំមិនដឹងទេ! ពីព្រោះជាការសម្ងាត់។

**ស៖** ខ្ញុំសូមអានឲ្យលោកស្ដាប់ចេញពីព្រឹត្តិប័ត្រទង់បដិវត្ត ប៉ុន្តែមុននឹងខ្ញុំអានចេញពីឯកសារនេះ ខ្ញុំសូមបញ្ជាក់ថា នៅពេលដែលមន្ទីរ១០០ ស្ថិតនៅក្នុងខេត្តរតនគិរីនោះ គឺថាមិនមានកិច្ចប្រជុំរបស់គណៈមជ្ឈិមទេ តើត្រឹមត្រូវទេ នៅក្នុងឆ្នាំ១៩៧០ ឬ៧១ នោះ កិច្ចប្រជុំរបស់គណៈមជ្ឈិមបានចាប់ផ្ដើមឡើងវិញ តើនេះត្រឹមត្រូវដែរទេ?

**ឆ៖** ដូច-- គោរពលោកប្រធាន ដូចជាខ្ញុំបានជម្រាបហើយ ថាខ្ញុំមិនចាំទេ! វាច្រើនឆ្នាំមកទៅហើយ។

**ស៖** លោក នួន ជា នៅពេលដែលគណៈមជ្ឈិមរៀបចំប្រជុំនៅក្នុងចន្លោះខែមីនា ឆ្នាំ១៩៧០ រហូតដល់ខែមេសា ឆ្នាំ១៩៧៥ នោះ តើគណៈមជ្ឈិមហ្នឹង រៀបចំប្រជុំនៅទីណាដែរ ចន្លោះពេលនុ៎ង?

[១១:១៩:៥៩]

**ឆ៖** ដូចជាខ្ញុំបានជម្រាបអ៊ីចឹង គឺនៅក្នុងព្រៃ ខ្ញុំមិនស្គាល់កន្លែងទេ ពី៧០ ទៅ៧៥ នោះ ពីព្រោះផ្លាស់ឡើង ផ្លាស់ចុះ។

**ស៖** តើការប្រជុំរបស់គណៈមជ្ឈិមចន្លោះពេលនុ៎ងនៅក្នុងព្រៃ ក្នុងខេត្តរតនគិរី ឬក៏នៅក្នុងព្រៃជិតស្ទឹងជីនិត?

**ឆ៖** សូមជម្រាបគោរពលោកប្រធាន តាមខ្ញុំចាំគឺមកស្ទឹងជីនិតហើយ។

**ស៖** នៅពេលនេះ ខ្ញុំសូមអានជូនលោកនូវសេចក្ដីប្រកាសថ្លែងការណ៍មួយរបស់លោក ប៉ុល ពត នៅក្នុងឆ្នាំ១៩៧៥ ថ្លែងទៅកាន់ទ័ពបដិវត្តន៍កុម្មុយនីស្ដកម្ពុជា។ ឯកសារលេខ D243.2.1 ខ្មែរលេខ 00063334 អង់គ្លេសគឺ 004196 បារាំងគឺ00538971។ លោកប្រធាននៅក្នុងថ្ងៃនេះ យើងមានបញ្ហា

ក្នុងការបញ្ជាំងឯកសារនៅក្នុងអេក្រង់។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតអាននូវសេចក្តីប្រកាសថ្លែងការណ៍របស់លោក ប៉ុល ពត ជូនកាន់-- ទៅកាន់ជនជាប់ចោទ បន្ទាប់មក ខ្ញុំនឹងសួរសំណួរទៅកាន់គាត់។

សេចក្តីថ្លែងការណ៍របស់លោក ប៉ុល ពត ដែលខ្ញុំសូមអានជូនលោកនោះគឺមានដូចតទៅ៖

[១១:២២:៣០]

"ក្រោយពីរដ្ឋប្រហារនៅក្នុងឆ្នាំ១៩៧០ អង្គការដឹកនាំនៅតាមភូមិភាគនានាមានការលំបាកក្នុងការទាក់ទងគ្នាទៅវិញទៅមក ក៏ប៉ុន្តែវាសំខាន់ដែលត្រូវការរៀបចំកិច្ចប្រជុំគណៈមជ្ឈិម ដើម្បីវាយតម្លៃស្ថានភាពក្រោយរដ្ឋប្រហារ និងដើម្បីចាត់វិធានការធ្វើសង្គ្រាម និងធ្វើការវាយតម្លៃ តើសង្គ្រាមគួរធ្វើឡើងដោយរបៀបណា?"

ដូច្នេះ ខ្ញុំចង់សួរលោក នួន ជា ថាតើត្រឹមត្រូវដែរឬទេ ក្រោយពីរដ្ឋប្រហារ កិច្ចប្រជុំរបស់គណៈមជ្ឈិមរៀបចំប្រជុំឡើងវិញ ហើយនៅពេលប្រជុំនោះ គេពិភាក្សាសំខាន់នោះគឺការតស៊ូអាវុធប្រឆាំងទៅនឹងរបបរបស់ លន់ នល់ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** គោរពលោកប្រធាន ខ្ញុំសូមមើលឯកសារនោះ បើមាន។

**ស៖** លោកប្រធាន ខ្ញុំមានឯកសារថតចម្លងមួយច្បាប់នេះ ដែលខ្ញុំអាចផ្តល់ជូនបាន។ ទំព័រខ្មែរឯកសារភាសាខ្មែរនោះ លេខវាគឺ 63334។

[១១:២៤:៥៩]

**ឆ៖** កូពីទេ! សុំឯកសារដើមមកមើលមើល៍ ដូចជាខ្ញុំបានជម្រាបមកហើយ។

**ប្រធានអង្គជំនុំ៖**

បន្តទៅសំណួរផ្សេងទៀត! អង្គជំនុំជម្រះបានហើយរួចហើយ គាត់មិនឆ្លើយតបមានន័យថាគាត់រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងសំណួរ។ លោកព្រះរាជអាជ្ញាបន្តការតាំងសំណួរផ្សេងទៀត។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** តើលោកចាំដែរឬទេ នៅពេលប្រជុំរបស់គណៈមជ្ឈិមនោះ គឺលោកបានពិភាក្សាអំពីការតស៊ូអាវុធប្រឆាំងទៅនឹងរបប លន់ នល់ ដែលការប្រជុំនោះគឺនៅក្នុងចន្លោះខែមីនា ឆ្នាំ១៩៧០ ដល់ខែមេសា ឆ្នាំ១៩៧៥?

**ឆ៖** គោរពលោកប្រធាន! ពី៧០ ដល់ ៧៥ វាប្រាំឆ្នាំ តើប្រជុំនោះ ប្រជុំចន្លោះនោះឆ្នាំណាខែណា? ខ្ញុំសូមដឹងមើលដើម្បីឲ្យច្បាស់ កាលបរិច្ឆេទវាយ៉ាងម៉េច!

**ស៖** ថាតើគណៈមជ្ឈិមបានជួបប្រជុំគ្នាញឹកញយប៉ុនណាដែរ ចន្លោះឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ នោះ?

**ឆ៖** គោរពលោកប្រធាន កំណត់ឲ្យត្រឹមត្រូវ កំណត់មិនបានទេ! សម្រេចទៅតាមសភាពការណ៍។

**ស៖** តើត្រឹមត្រូវ ឬក៏មិនត្រឹមត្រូវ ដែលថាគណៈមជ្ឈិមនោះបានជួបប្រជុំគ្នាជារៀងរាល់ឆ្នាំ នៅក្នុងចន្លោះឆ្នាំ១៩៧០ ទៅដល់ឆ្នាំ១៩៧៥ ឬក៏គណៈមជ្ឈិមនេះមានកិច្ចប្រជុំវិសាមញ្ញផ្សេងទៀត?

**ឆ៖** គោរពលោកប្រធាន ជួនកាលមានប្រជុំសាមញ្ញ ជួនកាលមានប្រជុំវិសាមញ្ញ វាមិនទៀងទាត់ សម្រេចដូចខ្ញុំជម្រាបអ៊ីចឹង សម្រេចទៅតាមសភាពការណ៍វាប្រែប្រួល។

[១១:២៨:២៧]

**ស៖** ដូច្នេះក្នុងចន្លោះ៧០ ដល់៧៥ គឺខែ មីនា ឆ្នាំ១៩៧០ ដល់ខែមេសា ឆ្នាំ១៩៧៥ ថាតើមានការប្រជុំដោយឡែកក្នុងចំណោមគណៈអចិន្ត្រៃយ៍ដែរ ឬទេ?

**ឆ៖** គោរពលោកប្រធាន ខ្ញុំមិនចាំទេ ពីព្រោះគណៈអចិន្ត្រៃយ៍វាធ្វើការប្រចាំថ្ងៃ មានការអីពិសេសប្រជុំទៅ គ្មានទេហីទៅ។ ដូច្នោះរកកំណត់យ៉ាងនេះយ៉ាងនោះវាមិនបាន។

[១១:២៩:៣០]

**ស៖** ថាតើការប្រជុំរបស់គណៈអចិន្ត្រៃយ៍នោះ គេប្រជុំនៅទីណាដែរនៅក្នុងចន្លោះខែមីនា ឆ្នាំ១៩៧០ ដល់មេសា ១៩៧៥នោះ?

**ឆ៖** គោរពលោកប្រធាន ខ្ញុំមិនឆ្លើយទេ ឆ្លើយច្រើនដងហើយ។ សង្គ្រាមចល័ត សង្គ្រាមឈ្លបវាចល័ត។

**ស៖** លោកនិយាយថាការប្រជុំរបស់គណៈអចិន្ត្រៃយ៍ហ្នឹង គឺផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាប-- គោរពលោកប្រធាន ត្រឹមត្រូវ។

**ស៖** លោកបានឆ្លើយមុននេះថា មុនឆ្នាំ១៩៧៥ កងកម្លាំងយោធា គឺមានកងទ័ពខាងភូមិភាគ តើត្រឹមត្រូវដែរឬទេថា គឺមានគណៈកម្មការទ័ពរួមគ្នាដែលបានធ្វើការសម្របសម្រួលទៅលើកងទ័ពប្រចាំភូមិភាគ?

**ឆ៖** គោរពលោកប្រធាន ខ្ញុំមិនយល់សំណួររបស់លោកព្រះរាជអាជ្ញា។

**ស៖** ខ្ញុំចង់សួរថានៅក្នុងភូមិភាគនីមួយៗមានទ័ពដោយឡែកៗពីគ្នា។ ដូច្នេះ ថាតើយុទ្ធសាស្ត្រ និងយុទ្ធវិធីរបស់កងទ័ពនោះគេធ្វើយ៉ាងម៉េចដែរនៅក្នុងជួរកងទ័ពនៅក្នុងចន្លោះខែមីនា ឆ្នាំ១៩៧០ ដល់ ខែមេសា ឆ្នាំ១៩៧៥?

**ឆ៖** គោរពលោកប្រធាន ដូចខ្ញុំជម្រាបហើយ ថាខ្ញុំមិនបានទទួលខាងកងទ័ពទេ។ ដូច្នោះខ្ញុំមិនដឹងគេធ្វើយ៉ាងម៉េចទេ សម្រេចនៅតាមភូមិភាគមួយៗគេធ្វើទៅតាមសភាពការណ៍របស់គេ។

[១១:៣២:១៥]

**ស៖** លោក នួន ជា ថាតើមានគណៈកម្មការរួបរួមកងទ័ពប្រដាប់អាវុធដែរឬទេ ដែលមានអ្នកតំណាងមកពីខាងភូមិភាគរួមជាមួយនឹងសមាជិករបស់គណៈមជ្ឈិម ដែលនៅក្នុងគណៈកម្មការរួបរួមកងទ័ពជាមួយគ្នានេះ គឺវាមានការធ្វើការងារទៅលើបញ្ហាកងទ័ត តើត្រឹមត្រូវដែរឬទេ?

**ឆ៖** គោរពលោកប្រធាន បើបើកវគ្គរៀនសូត្រនែ៎ មាន ចម្រុះ មានកម្មាភិបាល មានកងទ័ព មានអី អាហ្នឹងបើបើកវគ្គរៀនសូត្រ! ប៉ុន្តែបើគ្មានវគ្គរៀនសូត្រទៅ ខ្ញុំមិនដឹងទេ។

**ស៖** ដូច្នេះលោកលើកឡើងថាក្នុងនាមជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា លោកមិនបានដឹងទេ ថានៅក្នុងអំឡុងពេលមួយនោះ គឺមានគណៈកម្មការចម្រុះយោធាដែលបានធ្វើការងារទៅលើយុទ្ធវិធី និងយុទ្ធសាស្ត្រយោធា តើពិតជាដូច្នោះដែរឬទេ?

**ឆ៖** គោរពលោកប្រធាន ខ្ញុំមិនយល់ពាក្យសំណួររបស់លោកព្រះរាជអាជ្ញា ធ្វើយុទ្ធវិធី យុទ្ធសាស្ត្រយ៉ាងម៉េច?

**ស៖** ខ្ញុំនឹងសួរដោយសាមញ្ញវិញ តើលោកដឹង ឬក៏មិនបានដឹង ថាមានគណៈកម្មការសម្របសម្រួលយោធាចម្រុះដែលគេបង្កើតឡើងនៅក្នុងចន្លោះខែមីនា ១៩៧០ និងខែមេសា ១៩៧៥?

**ឆ៖** ខ្ញុំជម្រាបហើយ ជម្រាបទៀតថា ខ្ញុំមិនបានកាន់ខាងយោធាទេ ដូច្នោះខ្ញុំមិនដឹងទេ។

[១១:៣៤:៤៤]

**ស៖** នៅក្នុងពេលដែលលោកឆ្លើយថ្ងៃទី១៤ ខែធ្នូ ២០១១ លោកបានលើកឡើងថា លោក អៀង សារី នៅបរទេសនៅក្នុងប្រទេសចិន។ លោកបានលើកឡើងថា លោក អៀង សារី ត្រឡប់មកប្រទេសកម្ពុជាវិញ។ ខ្ញុំសូមដកស្រង់សម្តីលោកថា៖ “គាត់មកវិញរយៈពេល៥ទៅ៦ខែ”។ គឺខ្ញុំដកស្រង់ចេញពីឯកសារ E1/21.2.7។ ខ្ញុំសូមសួរថា នៅពេលដែលលោក អៀង សារី ត្រឡប់មកពីប្រទេសចិនវិញ ប្រាំ ប្រាំមួយខែម្តងនោះ ក្នុងចន្លោះឆ្នាំ១៩៧១ ដល់ ៧៥ នោះ តើលោក អៀង សារី មានបានចូលរួម

ប្រជុំជាមួយនឹងមេដឹកនាំបក្សដទៃទៀតដែរឬទេ?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនដែលថា ប្រាំ-ប្រាំមួយខែទេ!

**ស៖** កំណត់ហេតុ គឺបានកត់ត្រាទៅលើអ្វីដែលលោកបានលើកឡើង។ តើត្រឹមត្រូវដែរឬទេ នៅពេលដែលលោក អៀង សារី ត្រឡប់មកពីប្រទេសចិន មកដល់ប្រទេសកម្ពុជាចន្លោះឆ្នាំ១៩៧១ និង៧៥ គឺគាត់បានមកចូលរួមនៅក្នុងកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍? តើគាត់បានមានមកចូលរួមនៅក្នុងគណៈអចិន្ត្រៃយ៍ដែរឬទេ?

[១១:៣៦:២១]

**ឆ៖** ខ្ញុំមិនចាំទេ។

**ស៖** នៅពេលនេះខ្ញុំចង់សូមសួរលោកមួយចំនួនទៀត ពាក់ព័ន្ធទៅនឹងសន្និបាតបក្សលើកទីបី នៅឆ្នាំ១៩៧១។ ថាតើលោកមានបានចូលរួមនៅក្នុងសន្និបាតបក្សលើកទីបី ដែលបានរៀបចំឡើងក្នុងឆ្នាំ១៩៧១ ដែរឬទេលោក នួន ជា?

**ឆ៖** ក្នុងឆ្នាំ១៩៧១? ខ្ញុំបានចូលរួម!

**ស៖** តើសន្និបាតបក្សនោះ គេរៀបចំប្រជុំនៅទីណាដែរលើកទីបីនុ៎ង?

**ឆ៖** ខ្ញុំមិនចាំកន្លែង! គោរពលោកប្រធាន។

[១១:៣៧:៣៧]

**ស៖** តើលោកមានបានចាំទេ ថាតើមានមនុស្សប៉ុន្មានដែរ ដែលចូលរួមនៅក្នុងសន្និបាតបក្សលើកទីបីនៅពេលនោះ?

**ឆ៖** គោរពលោកប្រធាន ខ្ញុំមិនចាំចំនួនមនុស្សទេ!

**ស៖** តើលោកចាំទេ នៅពេលសន្និបាតបក្សលើកទីបីនោះ គេមានពិភាក្សាអំពីអ្វីខ្លះ? ហើយគេបានសម្រេចទៅលើបញ្ហាអ្វីខ្លះ នៅក្នុងសន្និបាតបក្សលើកទីបី ឆ្នាំ១៩៧១នោះ?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនចាំទេ។

**ស៖** តើលោកអាចបញ្ជាក់ជូនអង្គជំនុំជម្រះដែរឬទេ ថាក្រៅពីដែលលោកដែលបានចូលនៅក្នុងសន្និបាតបក្សឆ្នាំ១៩៧១ តើមាននរណាគេទៀតដែលចូលរួម?

**ឆ៖** ជម្រាបគោរពលោកប្រធាន ខ្ញុំមិនចាំទេ។

[១១:៤០:០៥]

**សៈ** តើលោកបានចាំដែរឬទេថា គណៈអចិន្ត្រៃយ៍មានការប្រជុំនៅក្នុងឆ្នាំ១៩៧២ ដែលសម្រេចឲ្យមានការបិទផ្សារនៅតាមភូមិភាគ? តើលោកមានបានចាំ មានការប្រជុំសម្រេចបែបហ្នឹងដែរឬទេ លោក នួន ជា?

**ជៈ** គោរពលោកប្រធាន ខ្ញុំមិនចាំទេ! ព្រោះនេះខាងផ្នែករដ្ឋបាល។

**សៈ** ខ្ញុំសូមអានជូនលោកនូវសេចក្តីថ្លែងការណ៍នៅក្នុងខែកញ្ញា ដល់ តុលា ឆ្នាំ១៩៧៦ ដែលនៅក្នុងនោះបានបង្ហាញអំពីកិច្ចប្រជុំនៅក្នុងឆ្នាំ១៩៧២។ ខ្ញុំអានពីឯកសារ D243/2.1.7 ខ្មែរ ERN លេខ 00063072 អង់គ្លេសគឺ 00450501 បារាំងគឺ 00491878 គឺវាដកស្រង់ចេញពីឯកសារទង់បដិវត្តមានដូចតទៅ។ សូមស្រង់សេចក្តីៈ

[១១:៤១:៤៥]

"បក្សបានវាយតម្លៃ ហើយយល់ឃើញថា ស្ថានភាពកើតឡើងដូច្នេះៗ បានសម្រេចបិទផ្សារនៅតាមតំបន់រំដោះមួយចំនួននៅក្នុងឆ្នាំ១៩៧២។ ការបិទផ្សារនោះ គឺជាកិច្ចការមួយ ហើយវាគឺជាចលនារបស់ខាង-- ចលនារបស់បក្សដើម្បីលុបបំបាត់ចោលពួកចក្រពត្តិ។ យើងបានធ្វើការគ្រប់គ្រងទៅលើផលិតផលមួយចំនួនដូចជា ស្រូវ, ប្រេង និងថ្នាំជាដើម។ នៅពេលដែលយើងបានមានលទ្ធភាពគ្រប់គ្រងទៅលើផលិតផលទាំងអស់នោះហើយ យើងនឹងព្យាយាមគ្រប់គ្រងទៅលើយុទ្ធសាស្ត្រនៅក្នុងសេដ្ឋកិច្ច។ យើងមិនឲ្យមានទំនិញទាំងឡាយណាដែលវាហូរចូល និងចាកចេញពីតំបន់រំដោះនោះទេ។ ដូច្នេះហើយផ្សារទាំងឡាយនោះនឹង គឺត្រូវបិទមិនឲ្យលក់ទំនិញទាំងអស់នោះ"។

តើលោកនឹកឃើញដែរឬទេ លោក នួន ជា ដែលថាបក្សបានសម្រេចនៅក្នុងឆ្នាំ១៩៧២ ឲ្យបិទផ្សារចោលទាំងអស់នៅតាមតំបន់ និងភូមិភាគរំដោះ?

[១១:៤២:៥៦]

**ជៈ** គោរពលោកប្រធាន ខ្ញុំមិនចាំទេ! ដូចជាគ្មានឲ្យបិទផ្សារឯណាទេឆ្នាំ១៩៧២។

**សៈ** តើលោកអាចនឹកឃើញទេថា តើនៅពេលណាដែរ ដែលមានការឲ្យបិទផ្សារនៅតាមភូមិភាគរំដោះនោះ?

**ជៈ** គោរពលោកប្រធាន បញ្ហានេះនៅលើសិទ្ធិរបស់គណៈភូមិភាគ។

**សៈ** ថាតើទឹកដីនៅក្នុងប្រទេសកម្ពុជាទំហំប៉ុន្មាន ឬក៏មានទឹកដីក្នុងប្រទេសកម្ពុជាប៉ុន្មានដែរ ដែលត្រូវបានរំដោះនៅចន្លោះឆ្នាំ១៩៧១ ដល់ ឆ្នាំ១៩៧២ នោះ?

[១១:៤៥:១៤]

**ផ៖** សូមគោរពលោកប្រធាន ខ្ញុំស្តាប់មិនបានទេ។

**ស៖** ខ្ញុំសូមសួរចំណុចជាក់លាក់មួយ តើលោកនឹកឃើញដែរឬទេថា នៅពេលមួយនោះគឺខេត្តក្រចេះត្រូវបានរំដោះ។

**ផ៖** បាទ ខេត្តក្រចេះត្រូវបានរំដោះមែន។

**ស៖** តើខេត្តក្រចេះត្រូវបានរំដោះនៅក្នុងពេលណាឆ្នាំណាដែរ?

**ផ៖** ដូចជាលោកមានយោបល់អំមិញដូចឆ្នាំ៧១,៧២។

**ស៖** តើត្រឹមត្រូវដែរឬទេ នៅពេលដែលក្រចេះត្រូវបានរំដោះក្នុងឆ្នាំ១៩៧១ និង៧២ នោះអ្នកនៅក្នុងខេត្តក្រចេះត្រូវបានអនុញ្ញាតឲ្យរស់នៅក្នុងខេត្តនោះដដែល ហើយផ្សារទាំងឡាយនោះគឺក៏គេអនុញ្ញាតឲ្យបើកលក់ជាធម្មតាដែរ តើត្រឹមត្រូវដែរឬទេ?

**ផ៖** គោរពលោកប្រធាន នៅដដែល។

**ស៖** តើលោកនឹកឃើញដែរឬទេថា មានពេលមួយនោះបក្សបានសម្រេច ដោយសារមិនសប្បាយចិត្តទៅលើការរស់នៅ អាកប្បកិរិយារបស់ប្រជាជននៅក្នុងខេត្តក្រចេះ។ ដូច្នេះហើយនៅពេលនោះទើបសម្រេចបិទផ្សារនៅក្នុងខេត្តក្រចេះ ហើយជម្លៀសប្រជាជនទៅតាមសហករណ៍ តើលោកចាំទៅលើព្រឹត្តិការណ៍ហ្នឹងដែរឬទេ?

**ផ៖** គោរពលោកប្រធាន ខ្ញុំមិនចាំទេ! ពីព្រោះខ្ញុំនៅខាងនេះ ខេត្តក្រចេះនៅខាងផ្សេងឯនោះ។ នៅខាងភូមិភាគពាយ័ព្យ (ប្លែសាន)-- អំនៅខាងភូមិភាគបូព៌ា នែនៅខាងគេគ្រប់គ្រងផ្សេងនោះ។

**ស៖** តើលោកអាចពន្យល់ជូនអង្គជំនុំជម្រះដែរឬទេ តើគេនិយាយថា ចាប់រឹបអូសប្រជាជននោះវាមានន័យយ៉ាងម៉េចដែរ?

**ផ៖** គោរពលោកប្រធាន ខ្ញុំមិនដែលឮគេចាប់រឹបអូសប្រជាជន។

**ប្រធានអង្គជំនុំ៖**

លោកព្រះរាជអាជ្ញា សួរសំណួរម្តងទៀត។ ចាប់រឹបអូសប្រជាជន ពាក្យនេះជាភាសាខ្មែរ គឺពិបាកយល់។

[១១:៤៧:៤៩]

**លោក ម៉ៃខល ផេសមិន៖**

វាជាការល្អប្រសិនបើខាងសហព្រះរាជអាជ្ញាជាតិនោះ អាចធ្វើការដកស្រង់សម្តីជាភាសាខ្មែរទៅដើម្បីឲ្យបានយល់ច្បាស់ទាំងអស់គ្នា។

**ប្រធានអង្គជំនុំ៖**

បាទៗអរគុណច្រើន។

**លោក ខេល លីសាក់៖**

គឺខ្ញុំរីករាយធ្វើដូច្នោះ ក៏ប៉ុន្តែនៅពេលនេះ អ្វីដែលខ្ញុំចង់សួរនេះគឺដើម្បីចង់បង្ហាញគឺទង់បដិវត្ត ខែធ្នូ ឆ្នាំ១៩៧៦ ដល់ខែមករា ១៩៧៧ គឺឯកសារលេខ D43.2.1.9។ សំណួរដែលខ្ញុំចង់ចោទសួរនោះគឺមាននៅក្នុងលេខខ្មែរ ERN 00063040 ERN ជាភាសាអង់គ្លេសគឺ 009491479 បារាំងគឺ 00504049។ យើងខ្ញុំក៏អាចធ្វើការបញ្ចាំងឯកសានេះ នៅក្នុងអេក្រង់ផងដែរ។

[១១:៤៩:៣០]

ខ្ញុំយល់ឃើញថា អេក្រង់នោះមិនអាចបញ្ចាំងបាននោះទេ ដូច្នេះយើងមិនអាចបង្ហាញទេលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

មន្ត្រីច្បាប់អាចបង្ហាញឯកសារនេះនៅលើអេក្រង់ទូរទស្សន៍បានទេ?

[១១:៥០:១៥]

**លោក នួន ជា៖**

សូមឲ្យយកឯកសារនោះ មកឲ្យខ្ញុំមើលមើល៍ ខ្ញុំទទួចប៉ុន្មានដងទៅហើយ តែដដែលៗ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ អង្គជំនុំជម្រះមិនតម្រូវដូច្នោះទេ អំមិញគឺបញ្ហាខ្លឹមសារនៃឯកសារដែលជាការតាំងសំណួរ។ សហព្រះរាជអាជ្ញារងអន្តរជាតិ លើទំព័រឯកសារអម្បាញ់មិញនេះ តើលោកអាចអានបានដែរឬទេ ដើម្បីឲ្យច្បាស់លាស់ ពីព្រោះឆ្លងកាត់ការបកប្រែ វាជាហេតុនាំឲ្យមិនយល់នូវគោលបំណងនៃការសួរ។ កាលបើមិនយល់អំពីគោលបំណងនៃការសួរ ការឆ្លើយក៏មិនដឹងថាឆ្លើយយ៉ាងដូចម្តេចដែរ។

**លោក ខេល លីសាក់៖**

លោកប្រធានអ្វីដែលខ្ញុំសូមស្នើឡើងនេះ គឺថាអង្គជំនុំជម្រះ ឬក៏ខាងសហភាតារបស់ខ្ញុំអាចអាន

ឯកសារដើមជាភាសាខ្មែរ គឺដើម្បីឲ្យយើងអានជាភាសាដើមនេះជូនទៅកាន់ជនជាប់ចោទ។ ខ្ញុំគិតថា ខ្ញុំក៏អាចអានជាភាសាអង់គ្លេសដែរ ក៏ប៉ុន្តែវាជាការល្អខាងសហព្រះរាជអាជ្ញាសហការីរបស់ខ្ញុំហ្នឹង អាចអាចជាភាសាជាតិទៅ ជាឯកសារដើម។

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញារងជាតិ អាចអានបានដែរទេ?

[១១:៥២:១៣]

**លោក សេង ប៊ុនឃាង៖**

បាទសូមអរគុណលោកប្រធាន។ ខ្ញុំនឹងអានជាភាសាខ្មែរ ចាំសហការីរបស់ខ្ញុំនឹងព្រីនឯកសារហ្នឹងចេញសិន។ សូមអរគុណ។

**លោក ឌេល លីសាក់៖**

គឺខ្ញុំសូមអភ័យទោស ដោយសារយើងអំមិញហ្នឹង ចំណាយពេលប៉ុន្មាននាទី ដោយសារតែយើងរៀបចំអេក្រង់ហ្នឹង ឲ្យបញ្ចាំងឲ្យចេញ ហើយយើងធ្វើយ៉ាងណានេះ ព្យាយាមរកឯកសារដើមនេះដើម្បីបញ្ចាំងនៅក្នុងអេក្រង់ ដូច្នេះហើយប្រហែលជាចំណាយពេលមួយពីរនាទីទៀតតែប៉ុណ្ណោះ។

**លោក នួន ជា៖**

ឯកសារនេះ មកឲ្យខ្ញុំមើល។ ឯកសារ--

**ប្រធានអង្គជំនុំ៖**

បញ្ហានេះ អង្គជំនុំជម្រះបានជម្រាបហើយ បានសម្រេចរួចហើយ។ ដោយសារឯកសារមានច្រើនសែនទំព័រនៅក្នុងសំណុំរឿងនេះ ហើយបច្ចេកទេសនៃការរៀបចំសំណុំរឿងក្ដីដ៏ធំធេង ដូចសំណុំរឿងក្ដីនេះ ដែលយើងបានធ្វើតាមទម្រង់នៃការរៀបចំឯកសារ ចងក្រងឯកសារនៅក្នុងសំណុំរឿងដូចគ្នាទៅនឹងសំណុំរឿងក្ដីនៅតុលាការអន្តរជាតិនានា ដែលគេបាននឹងកំពុងធ្វើសព្វថ្ងៃនេះ។ ហើយអង្គជំនុំជម្រះបានសម្រេចបញ្ហានេះរួចហើយ។ ភាគីមានសិទ្ធិដាក់ លោកមានសិទ្ធិឆ្លើយ បើលោកមិនឆ្លើយរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប។ អង្គជំនុំជម្រះបានសម្រេចពីម្សិលមិញរួចហើយ ពីថ្ងៃ១០ រួចហើយ។

[១១:៥៦:៥៥]

សូមអញ្ជើញលោក អាង ឧត្តម!

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន ប្រហែលជាខ្ញុំអាចជួយបាន ពួកខ្ញុំរកឃើញហ្នឹងជាភាសាខ្មែរ។ ខាងព្រះរាជអាជ្ញាចង់បានឯកសារហ្នឹងទេ ក្រែងលោ ខ្ញុំរកទាន់ខ្ញុំឃើញមុន។

**ប្រធានអង្គជំនុំ៖**

អរគុណ ហើយ--

សូមអញ្ជើញ!

[១១:៥៧:៤៤]

**លោក សេង ប៊ុនឃាង៖**

បាទសូមអរគុណលោកប្រធាន។ ឥឡូវនេះឯកសារនេះបានទទួលហើយ។ ខ្ញុំសូមអានជាភាសាខ្មែរ នៅត្រង់ ERN លេខ 00063040 ចាប់ផ្ដើមដោយ "ម្នាក់ក៏យក ពីរនាក់ក៏យក មួយរយនាក់ក៏យក មួយពាន់នាក់ក៏យក រហូតដល់ដណ្ដើមប្រជាជនពី ភ្នំពេញទៀត។ មាគ៌ាពង្រឹងប្រជាជនពីខ្មាំងរបស់បក្សគឺត្រឹមត្រូវណាស់។ ក្នុងសកលលោកគ្មានយ៉ាងនេះទេ បើខ្មាំងមានប្រជាជន ខ្មាំងមានយោធា ខ្មាំងមានសេដ្ឋកិច្ច។ បើខ្មាំងគ្មានប្រជាជន វាគ្មានកម្លាំងយោធា គ្មានកម្លាំងសេដ្ឋកិច្ច ហេតុផលយើងត្រឹមត្រូវ។

ដូច្នេះមាគ៌ាយើងត្រឹមត្រូវណាស់ កន្លែងណាគឺយើងវាយដណ្ដើមប្រជាជនដែរ។ ឧទាហរណ៍វាយខាងបាណាមនៅឆ្នាំ៧៣ យកទាំងអស់ក្នុងក្រុងបាណាម បញ្ចេញចេញទាំងអណិកជនវៀតណាម អណិកជនចិន ទាំងទាហាន ទាំងប៉ូលិស យកទាំងអស់ ពង្រឹងប្រជាជនពីខ្មាំង។ ឧទាហរណ៍វាយផ្លូវលេខ៦។

[១១:៥៩:២៥]

ចេនឡាទីពីរ ឆ្នាំ៧១ ខ្មាំងវាបម្រុងយកពីតាំងគោកទៅដល់កំពង់ធំ។ វាកាត់ពីកំពង់ធំ មកត្រើងយកត្រីកោណនេះ ដើម្បីចាប់ប្រជាជន ប្រមូលប្រជាជនយកកម្លាំងនយោបាយ ប្រមូលប្រជាជនយកកម្លាំងសេដ្ឋកិច្ច ដណ្ដើមភូមិភាគឧត្តរទៅទល់នឹងក្រចេះ ដើម្បីពួកអាធីវ វាយពីខាងត្បូងមកយកក្រចេះ។ តែវាវាយមិនឈ្នះ ដោយសារអ្វី? ដោយសារយើងដកប្រជាជន។ ដល់ដកប្រជាជនអស់ វាគ្មានកម្លាំងបន្ថែម គ្មានកម្លាំងបន្ថែមជាសេដ្ឋកិច្ច គ្មានកម្លាំងបន្ថែមជាកម្លាំងមនុស្ស វាកាន់តែខ្សោយទៅ។ យើងវាយកាត់ជាកង់ៗ ធ្វើឲ្យកងស្រួចវាដាច់ក្បាលដាច់កន្ទុយ។ បង្កបង្កើតលក្ខណ:សម្បត្តិ ដើម្បីវាយផ្តាច់។ កត្តានៃជ័យជម្នះ គឺយើងដកប្រជាជន។ ឧទាហរណ៍ យើងរំដោះឧដុង្គក្នុងឆ្នាំ៧៤ យើងដក

ប្រជាជនទាំងអស់ ដល់ដណ្ដើមវិញវាគ្មានកម្លាំង។ គ្មានកម្លាំងប្រជាជន គ្មានកម្លាំងសេដ្ឋកិច្ច គ្មានកម្លាំងយោធា។ យើងវាយវាបាន ហើយមិនបាច់វាយផង។ ដល់យើងវាយផ្ដាច់ភ្នំពេញ យើងទុកចោល យើងវាយយកខាងមុខវិញ។

[១២:០១:៣៧]

នេះជាមាគ៌យុទ្ធសាស្ត្រមួយ មានសារៈសំខាន់ណាស់ ក្ដាប់ប្រជាជន ដណ្ដើមប្រជាជន។ ដូច្នេះបានជាបក្ខជនយើង យុទ្ធជនយើង យុទ្ធនារីយើង រដ្ឋអំណាចមានមូលដ្ឋានធ្វើអីដែលប៉ះពាល់ប្រជាជន ត្រូវយល់ន័យជាយុទ្ធសាស្ត្រនៃប្រជាជនយ៉ាងនេះ គឺប្រជាជននៅខាងណា ខាងនោះឈ្នះហើយ។ ទោះជាប្រជាជនយុទ្ធសាស្ត្រ ជាប្រជាជនយុទ្ធវិធីក្ដី។ ប្រជាជនយុទ្ធវិធីនៅជាមួយយើង ក៏ជួយយើងដែរ។ តែបើប្រជាជនយុទ្ធវិធីនៅជាមួយខ្មាំង គឺជួយខ្មាំង”។

បាទ សូមចប់ការដកស្រង់ត្រឹមនេះ។ សូមអរគុណ។

[១២:០២:៣៧]

**ប្រធានអង្គជំនុំ៖**

អរគុណសហព្រះរាជអាជ្ញារងជាតិ។

សូមអញ្ជើញលោកសហព្រះរាជអាជ្ញាអន្តរជាតិ!

សូមអញ្ជើញ!

**លោក នួន ជា៖**

ប្រធាន អានអំមិញ យើងពង្រឹងប្រជាជនពីខ្មាំងយ៉ាងម៉េច? ខ្ញុំស្ដាប់មិនយល់។ អានពីរដង យើងពង្រឹងប្រជាជនពីខ្មាំង ពីរដងអំមិញហ៎។ ម៉េចពង្រឹងប្រជាជនពីខ្មាំង បានន័យថាយ៉ាងម៉េច?

ដូច្នោះបានជាខ្ញុំថា ចង់សូមមើលឯកសារហ្នឹងឲ្យច្បាស់មើល៍ តើវាយ៉ាងម៉េច? ពីព្រោះបើនិយាយតែពង្រឹងប្រជាជន ពីខ្មាំង មិនដឹងជាបានន័យថាយ៉ាងម៉េចទេ?

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះលោកចាំស្ដាប់សំណួរ ដែលសហព្រះរាជអាជ្ញាអន្តរជាតិនឹងសួរសំណួរមួយសំណួរចុងក្រោយមុននឹងសម្រាកពិសាអាហារថ្ងៃត្រង់។ ចាំស្ដាប់សំណួរសិន ហើយអាចឆ្លើយនឹងសំណួរនេះបានដែរឬទេ?

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សំណួរទីមួយ ខ្ញុំចង់សួរលោក នួន ជា នោះ គឺថាតើលោកអាចពន្យល់ជូនអង្គជំនុំជម្រះ ពាក់ព័ន្ធទៅនឹងមាត៌ារបស់បក្ស ដែលនិយាយអំពីការវាយដណ្តើមប្រជាជននោះដែរឬទេ?

[១២:០៤:២៣]

**លោក នួន ជា៖**

**ជ៖** ខ្ញុំសូមសិទ្ធិមិនឆ្លើយ។

**លោក ឌេល លីសាក់៖**

លោកប្រធាន គឺបើសិនជាលោកប្រធានអនុញ្ញាតនោះ ខ្ញុំអាចផ្តល់ព័ត៌មានថ្មីៗ ថាតើខ្ញុំត្រូវការរយៈពេលប៉ុន្មានទៀត។ ចំពោះខ្ញុំៗ សុំពេលពេលបន្ថែមពីកន្លះម៉ោង ទៅមួយម៉ោង។ ពេលវេលានេះ គឺអាស្រ័យទៅលើជនជាប់ចោទ។ ហើយចំពោះសហការីរបស់ខ្ញុំនោះ គឺប្រហែលជាត្រូវការមួយម៉ោងទៅមួយម៉ោងកន្លះ។

[១២:០៥:០៥]

ដូច្នេះហើយចំពោះក្រុមខាងសហព្រះរាជអាជ្ញានេះ គឺយើងត្រូវការពេលវេលាច្រើនបំផុតនោះគឺរយៈពេលកន្លះថ្ងៃ។ ពេលពេញមួយរសៀលនេះតែម្តង។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ពេលវេលាសមល្មមនឹងសម្រាកពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ចាប់ពីពេលនេះទៅរហូតដល់ម៉ោងមួយកន្លះ សូមអញ្ជើញចូលវិញមួយកន្លះរសៀលនេះ។ ហើយ--

សូមអញ្ជើញលោក នួន ជា!

[១២:០៥:៣៧]

**លោក នួន ជា៖**

សុខភាពខ្ញុំមិនគ្រប់គ្រាន់ ចេះតែទន់ខ្សោយទៅៗ ដូច្នោះ ថ្ងៃត្រង់ខ្ញុំមិនអាចចូលរួមសវនាការបានទេ។ សូមជម្រាបលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

លោកស្នើសុំយ៉ាងម៉េចទៅ? សូមដាក់សំណើឲ្យបានច្បាស់លាស់ កាលបើសំណើមិនច្បាស់ ការ

សម្រេចវាជួបនឹងការលំបាកក្នុងការសម្រេច វានាំឲ្យការសម្រេចមិនច្បាស់លាស់ដែរ។ ព្រោះជាតុលាការ ជាអង្គជំនុំជម្រះត្រូវសម្រេចឲ្យបានច្បាស់លាស់ ជាក់ច្បាស់ក្នុងការសម្រេច។

[១២:០៦:១៧]

**លោក នួន ជា៖**

គោរពលោកប្រធាន ចាំដាក់សេចក្ដីស្នើពេលក្រោយ ឥឡូវនេះ។ ចាំឲ្យមេធាវីខ្ញុំធ្វើ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ លោកស្នើបានន័យថានៅរសៀលនេះ លោកស្នើមិនចូលរួមផ្ទាល់នៅក្នុងបន្ទប់សវនាការនេះទេ។ ប៉ុន្តែ លោកសូមដកខ្លួនថយទៅតាមដាន ដំណើរការសវនាការពីចម្ងាយនៅបន្ទប់ខាងក្រោមដែលមានរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់លោកតាមដាន ដែលបានធ្វើកន្លងមកដូចជាពីម្សិលមិញអ៊ីចឹង ពិតមែនទេ?

[១២:០៧:០៤]

**លោក នួន ជា៖**

នៅខាងក្រោម ដើម្បីតាមដាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតតាមការស្នើសុំនេះ ប៉ុន្តែអង្គជំនុំជម្រះតម្រូវឲ្យមេធាវីការពារក្ដីហ្នឹងដាក់នូវឯកសារពាក្យលះបង់សិទ្ធិក្នុងការចូលរួមដោយផ្ទាល់ ហើយនិងទៅបន្តតាមដានសវនាការពីចម្ងាយតាមមធ្យោបាយសោតទស្សន៍ តាមបន្ទប់ ពីបន្ទប់នៅខាងក្រោមសាលសវនាការនេះ ដោយមានចុះហត្ថលេខា និង/ឬ ឬក៏ផ្ដិតម្រាមដៃជាក់លាក់ពីជនជាប់ចោទ។

[១២:០៧:៤៦]

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន លោក អៀង សារី ក៏មានករណីដូចគ្នាដែរ ដោយសារគាត់ទ្រាំទ្រអង្គុយមួយព្រឹកនេះហើយៗ មានបញ្ហាប៉ះពាល់សុខភាពជាពិសេសឆ្អឹងខ្នង ហើយក៏សូមលោកប្រធានអនុញ្ញាតឲ្យគាត់បោះបង់ការចូលរួមផ្ទាល់នៅរសៀលនេះ។ តែសូមចូលរួមផ្ទាល់នៅបន្ទប់រង់ចាំនៅជាន់ក្រោយសម្រាប់ពេលរសៀលនេះ។ ហើយយើងនឹងដាក់ពាក្យតាមតម្រូវការជូនតុលាការ សូមលោកប្រធានមេត្តាអនុញ្ញាតផង។ សូមអរគុណ។

[១២:០៨:១៦]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតជាមួយគ្នានឹងលោក នួន ជា ដែរ ប៉ុន្តែតម្រូវឲ្យជនជាប់ចោទ ឬក៏មេធាវីរបស់ខ្លួនហ្នឹងដាក់នូវពាក្យសុំលះបង់សិទ្ធិនេះជាលាយលក្ខណ៍អក្សរដោយមានចុះហត្ថលេខា ឬក៏ផ្តិតម្រាមដៃផ្ទាល់ពីជនជាប់ចោទ។

ហើយឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូប ទៅកាន់បន្ទប់រង់ចាំខាងក្រោម ហើយនៅរសៀលនេះឲ្យនាំខ្លួនតែលោក ខៀវ សំផន មកកាន់សាលសវនាការ។ ចំណែកឯ នួន ជា ជាមួយ អៀង សារី គឺទុកលទ្ធភាពឲ្យគាត់បន្តការតាមដានសវនាការពីចម្ងាយនៅបន្ទប់ខាងក្រោម។ ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់នូវរូបភាពសំឡេងទៅបន្ទប់ខាងក្រោម ដើម្បីឲ្យជនជាប់ចោទអាចមានលទ្ធភាពតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១២:១០ នាទី ដល់ម៉ោង ១៣:៣៥ នាទី)*

[១៣:៣៥:៣៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅរសៀលនេះ អង្គជំនុំជម្រះនឹងដំណើរការសួរចម្លើយជនជាប់ចោទ ខៀវ សំផន។

អនុរក្សមន្ទីរឃុំឃាំងនាំលោក ខៀវ សំផន មកឈរវាងវង់ក្រចកសេះ នៅចំពោះមុខអង្គជំនុំជម្រះ។

សូមអញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបាទសូមលោកប្រធានមេត្តាបញ្ជាក់ថា តើការហៅលោក ខៀវ សំផន មកឆ្លើយនៅពេលនេះដើម្បីបញ្ជាក់ពីសារតារ ឬក៏ទាក់ទងទៅនឹងរចនាសម្ព័ន្ធរដ្ឋបាល និងរចនាសម្ព័ន្ធនៃការប្រាស្រ័យទាក់ទងការងារ?

សូមអរគុណ។

[១៣:៣៦:៤៣]

**ប្រធានអង្គជំនុំ៖**

អនុរក្សមន្ទីរឃុំឃាំងនាំមកសិនមក! នាំខ្លួនគាត់មកឈើវាងវង់ក្រចកសេះ នៅចំពោះមុខអង្គជំនុំជម្រះនេះ។ នេះគឺជាបញ្ជារបស់ប្រធានអង្គជំនុំជម្រះ។

*(ជនជាប់ចោទ ខៀវ សំផន ទៅកាន់ឈើវាងវង់ក្រចកសេះ)*

សូមជម្រាបលោកមេធាវីការពារក្ដី មេធាវីជាតិការពារក្ដី ខៀវ សំផន ថា អង្គជំនុំជម្រះបានកំណត់ជាក់លាក់នូវអង្គហេតុក្នុងវគ្គទីមួយសម្រាប់ធ្វើសវនាការដេញដោលចំពោះជនជាប់ចោទ។ ដូច្នេះសូមលោកមេធាវីក្ដាប់នូវបញ្ហាទាំងអស់នេះឲ្យបានថា ដំណាក់កាលវគ្គទីមួយហ្នឹងធ្វើអី ហើយបន្ទាប់មកទៀតការសម្រេចវគ្គទីពីរ វគ្គទីបី ទីបួន អង្គជំនុំជម្រះនឹងជម្រាបជូនដោយធ្វើការបែងចែកទាំងអង្គហេតុកំណត់នោះផងក្នុងការធ្វើសវនាការ។ នេះគឺច្បាស់លាស់ហើយ។ ហើយសូមជម្រាបថា ដោយសារលក្ខណៈនៃលោក ខៀវ សំផន វាមានភាពខុសគ្នាជាមួយនឹងករណី អៀង សារី ដោយសារលោក អៀង សារី បានបង្ហាញជំហរយ៉ាងជាក់ច្បាស់ថា គាត់នៅស្ងៀមមិនឆ្លើយតបទេ តាំងពីចាប់ផ្ដើមនៃការដេញដោលរហូតចប់កិច្ចដំណើរការសួរដេញដោល នៅក្នុងដំណើរការរឿងក្ដីដែលអង្គជំនុំជម្រះបានបំបែកយកមកធ្វើនៅដំណាក់កាលដំបូងនេះ។

[១៣:៣៩:១៧]

ដោយឡែកលោក ខៀវ សំផន កាលពីយើងសួរអំពីសាវតារជាតិបញ្ជាក់អំពីអត្តសញ្ញាណបុគ្គលហើយនិងប្រាប់សិទ្ធិរបស់គាត់។ គាត់មិនបានបង្ហាញបញ្ហានេះជាក់ច្បាស់ទេ ដោយគាត់បានប្រើ-- នឹងប្រើសិទ្ធិនៅពេលណាដែលការបង្ហាញភស្ដុតាងដោយសហព្រះរាជអាជ្ញាចំពោះគាត់ គឺថាបង្ហាញភស្ដុតាងដាក់បន្ទុកចំពោះគាត់ ទើបគាត់ឆ្លើយតប។ អ៊ីចឹងហើយបានជាមានការមិនទាន់ច្បាស់លាស់លើបញ្ហានៃការរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបនេះ។

[១៣:៤០:០០]

ដូច្នេះហើយបានជាអង្គជម្រះហៅគាត់មកចំពោះមុខអង្គជម្រះដើម្បីធ្វើនីតិវិធីឲ្យច្បាស់លាស់អំពីបញ្ហានេះ ប្រសិនបើគាត់ប្រកាន់ជំហរឲ្យបានច្បាស់លាស់ដូចគ្នាជាមួយនឹង អៀង សារី នោះ អង្គជម្រះនឹងពិចារណាសម្រេច ដូចករណី អៀង សារី ដែលអង្គជម្រះមិនបានបន្តនីតិវិធីក្នុងការដេញដោល

ចំពោះ អៀង សារី ទេ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយមុននឹងគាត់លះបង់សិទ្ធិហ្នឹង គឺគាត់បានទៅតាមបញ្ជារបស់អង្គជម្រះនៅមុខឈើរាងវង់ក្រចកសេះនៅចំពោះមុខអង្គជម្រះ ហើយបង្ហាញអំពីជំហររបស់គាត់។

[១៣:៤១:០១]

**លោក គង់ សំអុន៖**

លោកប្រធានសូមអរគុណ។ តាមរយៈខ្ញុំលោក ខៀវ សំផន គាត់បានប្រកាន់ជំហរមិនឆ្លើយនៅសំណួរនេះដូចដែលគាត់បានប្រកាស កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ កន្លងទៅ ហើយគាត់ប្រកាន់យកនូវសេចក្តីថ្លែងការណ៍របស់គាត់ ដែលគាត់បានធ្វើក្នុងរយៈពេលកន្លងមកនេះដែរ។ បាទសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ ឥឡូវហ្នឹងដើម្បីឲ្យច្បាស់លាស់លើបញ្ហានេះ។

សូមអញ្ជើញលោកមេធាវី នួន ជា!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជូនជាព័ត៌មានសង្ខេបថា កូនក្តីរបស់ខ្ញុំគាត់នឿយហត់ណាស់ព្រឹកមិញនេះ ឥឡូវនេះគាត់នៅខាងក្រោយ ប៉ុន្តែគាត់សម្រាន្តលក់។ ដូច្នេះ គាត់មិនបានចូលរួមដោយសកម្មទេ។ ដូច្នេះគ្រាន់តែជម្រាបជូនលោកប្រធានជ្រាប។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ សូមប្រគល់វេទិកាទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីសួរសំណួរទៅកាន់ជនជាប់ចោទ ខៀវ សំផន។ អញ្ជើញលោក ខៀវ សំផន!

**លោក ខៀវ សំផន៖**

ខ្ញុំសូមលោកប្រធានអនុញ្ញាត សូមបញ្ជាក់ថា សួរខ្ញុំពីរឿងអី។ បើថាសួរពីបរិបទប្រវត្តិសាស្ត្រ ខ្ញុំបានថ្លែងការណ៍ជម្រាបលោកប្រធានហើយ។ ហើយខ្ញុំបានសុំស្នើថា ក្រោយពីខ្ញុំសុំថ្លែងការណ៍ហើយ ខ្ញុំសូមមិនទាន់ឆ្លើយនឹងសំណួរទេ រង់ចាំព្រះរាជអាជ្ញាផ្តល់ភស្តុតាងដែលលោកចោទខ្ញុំសិន។ ហើយលោកប្រធានក៏បានអនុញ្ញាតហើយ។ មេធាវីខ្ញុំ មេធាវីអន្តរជាតិរបស់ខ្ញុំក៏មាននិយាយមុនខ្ញុំ ក៏សុំអីចឹងដែរ។ ដូច្នេះវា ដូចខ្ញុំសូមបញ្ជាក់ពីរឿងហ្នឹង។ បើថានិយាយពីបរិបទប្រវត្តិសាស្ត្រ ខ្ញុំបានថ្លែងអស់ហើយ ខ្ញុំអត់មានអីនិយាយទៀតទេ។ ហើយបើថា ថ្លែងពីរចនាសម្ព័ន្ធរដ្ឋបាល ខ្ញុំយល់ឃើញថា ដូចជាមិនទាន់

ដល់ទេ ពីព្រោះឯកសារ E155 នេះ បានបញ្ជាក់ច្បាស់ណាស់គឺថា លុះត្រាតែបរិបទការដេញពិភាក្សាពីបរិបទប្រវត្តិសាស្ត្រចប់ បានចូលមកក្នុងន័រចនាសម្ព័ន្ធរដ្ឋបាល។ ខ្ញុំរង់ចាំដល់ពេលរចនាសម្ព័ន្ធរដ្ឋបាលបានខ្ញុំអាចមានថ្លែងការណ៍ទៀត។ ខ្ញុំសូមជម្រាបលោកប្រធានអនុញ្ញាតគឺមានប៉ុណ្ណឹង។ ឯបើថាសួរពីបរិបទប្រវត្តិសាស្ត្រទេ ខ្ញុំបាទអត់មានអីនឹងឆ្លើយទៀតទេ ពីព្រោះខ្ញុំបានថ្លែងការណ៍ហើយបានជម្រាបហើយ ថាខ្ញុំមិនទាន់ឆ្លើយសំណួរទេ បាទ។

[១៣:៤៥:២២]

**ប្រធានអង្គជំនុំ៖**

បាទអរគុណលោក ខៀវ សំផន ដែលបានបញ្ជាក់សាជាថ្មីឲ្យកាន់តែច្បាស់លាស់ទៀត។

ឥឡូវនេះ លោក ខៀវ សំផន បានបង្ហាញនូវជំហររបស់គាត់ច្បាស់លាស់ហើយលើអង្គហេតុអំពីពាក់ព័ន្ធទៅនឹងប្រវត្តិបក្សកុម្មុយនីស្តកម្ពុជានេះ។ តើលោកចៅក្រម ហ្សង់ម៉ាក មានអ្វីចង់សួរ ឬចង់បង្ហាញជម្រាបជូនទៅលោក ខៀវ សំផន ដែរឬទេ?

សូមអញ្ជើញប្រសិនបើមាន!

[១៣:៤៦:០៥]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ មុននឹងសិក្សាអំពីបញ្ហាពាក់ព័ន្ធទៅនឹងលោក ខៀវ សំផន ខ្ញុំចង់ឲ្យយើងបញ្ជាក់អំពីបញ្ហានៃអវត្តមានរបស់លោក នួន ជា សិន។ ខ្ញុំចង់ដឹងថា តើខាងមេធាវីការពារក្តីគាត់--គឺថាយល់ស្របថា លោក នួន ជា មិនមានសភាពក្នុងការចូលរួមក្នុងសវនាការតុលាការ ឬក៏គាត់បាននិយាយថា គិតថា នួន ជា គ្រាន់តែលះបង់សិទ្ធិក្នុងការចូលរួមក្នុងសវនាការ។ ហើយប្រសិនបើគាត់លះបង់សិទ្ធិ តើវាជាការ មានការដាក់ជូននូវឯកសារជាលាយលក្ខណ៍អក្សរទៅខាងក្រឡាបញ្ជីដែរ ហើយឬនៅ?

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំបានដាក់ជូននូវឯកសារមួយជូនតុលាការ ដែលថាគាត់បោះបង់សិទ្ធិក្នុងការវត្តមាន ក្នុងការចូលរួមនេះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ដូច្នេះ គឺខាងមេធាវីការពារក្តីមិនមានការជំទាស់ថា ជនជាប់ចោទហ្នឹង គាត់មិនមានសម្បទា

គ្រប់គ្រាន់ក្នុងការចូលរួមក្នុងសវនាការនោះទេ តើមែនទេ? ឬគឺខាងលោកនិយាយថាគ្រាន់តែគាត់បោះបង់សិទ្ធិតែប៉ុណ្ណោះ។

[១៣:៤៧:២៨]

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំនិយាយដោយសង្ខេប ខ្ញុំមិនចង់ដាស់គាត់ទេ គាត់សម្រាន្តលក់។ ខ្ញុំបានដាក់នូវឯកសារជូនតុលាការដែលថាគាត់បានបោះបង់សិទ្ធិក្នុងការសវនាការថ្ងៃនេះ គាត់បោះបង់សិទ្ធិ ហើយខ្ញុំបានជូនជាភាសាខ្មែរ និងអង់គ្លេស ជូនមន្ត្រីក្រឡាបញ្ជីតុលាការ បាទ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណចំពោះការបំភ្លឺនេះ។

លោក ខៀវ សំផន ខ្ញុំគិតថា យើងទាំងអស់គ្នាដឹងហើយយើងអំពីជំហររបស់លោកនោះ គឺអ៊ីចឹងខ្ញុំគ្រាន់តែចង់ឲ្យ-- លោកបានចេញសេចក្តីថ្លែងការណ៍មួយចំនួនកាលពីខែធ្នូឆ្នាំមុននេះ ហើយយើងគិតថានេះជាសេចក្តីថ្លែងការណ៍ដោយស្ម័គ្រចិត្ត ហើយលោកបានធ្វើអត្ថាធិប្បាយមួយចំនួននៅក្នុងសេចក្តីថ្លែងការណ៍ទាំងនោះ ទាក់ទងទៅនឹងកថាខណ្ឌមួយចំនួននៃដីកាដំណោះស្រាយ ពាក់ព័ន្ធទៅនឹងបរិបទប្រវត្តិសាស្ត្រដែលជាផ្នែកមួយនៃដីកាដំណោះស្រាយ ដែលពាក់ព័ន្ធទៅនឹងសម័យកាលនោះ។ ដូច្នេះនៅក្នុងសំណុំរឿងយើងមានឯកសារមួយចំនួនដែលពាក់ព័ន្ធទៅនឹងលោក ខៀវ សំផន ផ្ទាល់ ហើយនិងពាក់ព័ន្ធទៅនឹងផ្នែកបរិបទប្រវត្តិសាស្ត្រនេះ។

[១៣:៤៨:៥៩]

ដូច្នេះ សវនាការនៅរសៀលនេះ គឺមានគោលបំណងពីរ គឺទីមួយ គឺចង់ដោយ-- នៅពេលដែលស្តាប់ឮយោបល់របស់-- អត្ថាធិប្បាយរបស់លោកនោះ យើងចង់បាននូវសេចក្តីបំភ្លឺមួយចំនួនពាក់ព័ន្ធទៅនឹងបរិបទអត្ថាធិប្បាយរបស់លោកនេះ។ ហើយបន្ទាប់មកទៀត ធៀបទៅនឹងឯកសារដែលពាក់ព័ន្ធនោះ ចំពោះខ្ញុំ ខ្ញុំគិតថាវាមានការគួរឲ្យកត់សម្គាល់ គឺត្រូវតែមានការសួរចម្លើយពីខាងអង្គជំនុំជម្រះធៀបទៅនឹងឯកសារទាំងអស់នោះ ដើម្បីឲ្យដឹងថាតើឯកសារទាំងនោះ សមស្រប សមហេតុផល ឬក៏ពាក់ព័ន្ធទាំងអស់ ហើយមានតម្លៃគ្រប់គ្រាន់ដែរឬទេ? អាស្រ័យហេតុនេះ បានជាឯកសារទាំងអស់ត្រូវដាក់ជូននៅក្នុងអង្គជំនុំជម្រះ ហើយនឹងត្រូវអាន ហើយនិងផ្តល់ឱកាសឲ្យលោកក្នុងការផ្តល់នូវបទអត្ថាធិប្បាយទៅលើឯកសារទាំងអស់នោះ។ ហើយប្រសិនបើលោកមិនចង់ឆ្លើយតបទៅនឹងឯកសារទាំង

អស់នោះទេ គឺជាសិទ្ធិសេរីភាពរបស់លោក។ ប៉ុន្តែលោកត្រូវតែដឹងឲ្យច្បាស់ថា នេះថ្ងៃនេះគឺជាឱកាសដែលផ្តល់ជូនលោកក្នុងការឆ្លើយតប។ តើលោកអាចយល់ច្បាស់ទេនូវអ្វីដែលអង្គជំនុំជម្រះចង់បានពីលោក? តើលោកចង់ឲ្យមានការបំភ្លឺបន្ថែមទៀត ឬក៏យ៉ាងណា? តើលោកអាចសួរថាតើសំណួរប្រភេទណាដែលនឹងសួរនោះ ក៏ខ្ញុំអាចបំភ្លឺជូនលោកបានដែរ?

[១៣:៥០:៣៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ នៅពេលនេះ ក្រោយពីបានស្តាប់យោបល់របស់លោកចៅក្រមឡាវ៉ែន៍ ខ្ញុំបាទមានសំណូមពរពីរចំណុចដែលលើក។ ទីមួយ សូមបញ្ជាក់ថា លោក ខៀវ សំផន បានបោះបង់សិទ្ធិមិនឆ្លើយតបនឹងសំណួរទាំងឡាយ ដែលនឹងលើកឡើងទាក់ទងនឹងប្រវត្តិសាវតារនេះរួចហើយ។ ហើយលោកចៅក្រមក៏បានបញ្ជាក់ថា លោកបានយល់នូវចំណុចនេះដែរ។ ដូច្នេះ ខ្ញុំសំណូមពរថាមិនគួរមានសំណួរអ្វីនឹងត្រូវលើកដាក់តាំងទៅនឹងលោក ខៀវ សំផន ទាក់ទងទៅនឹងសាវតារនេះទេ។

ទីពីរ ក្នុងករណីដែលលោកចៅក្រមទាមទារឲ្យមានការបញ្ជាក់ណាមួយទៅលើសេចក្តីថ្លែងការណ៍របស់លោក ខៀវ សំផន កាលពីពេលកន្លងទៅនេះ ខ្ញុំបាទសូមពេលវេលា ដើម្បីពិភាក្សាជាមួយនឹងលោក ខៀវ សំផន សិន។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រមសូមអនុញ្ញាត និងសូមបំភ្លឺដោយសង្ខេប។ ដោយថានៅក្នុងខែធ្នូ លោក ខៀវ សំផន បញ្ជាក់ថាគាត់មិនបានប្រើសិទ្ធិរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបទេ ប៉ុន្តែក្នុងចំណុចណាមួយ កាលណាពិនិត្យមើលភស្តុតាងនោះគាត់នឹងឆ្លើយ គាត់នឹងផ្តល់នូវសក្ខីកម្ម ហើយនិងឆ្លើយសំណួរពីចៅក្រម ឬក៏ពីភាគី កាលណាដាក់ភស្តុតាងនោះ។

[១៣:៥២:៣៣]

ដូច្នេះ មេធាវីការពារក្តីលើកឡើងអម្បាញ់មិញនោះ ថាលោក ខៀវ សំផន ដែលថាគោលជំហរ

របស់គាត់ហ្នឹងដូចខុសពីមុន។ ដែលថាលោក ខៀវ សំផន មិនឆ្លើយនូវសំណួរអ្វីទាំងអស់ ប៉ុន្តែខ្ញុំពិបាកយល់គោលជំហររបស់គាត់ណាស់នៅពេលនេះ។ ប៉ុន្តែ នៅចុងបញ្ចប់នៅផ្នែកនេះ នៅដំណាក់កាលសវនាការដំបូងនេះ ប្រសិនបើលោក ខៀវ សំផន មានគោលជំហរថាពិនិត្យភស្តុតាងហើយ គាត់ឆ្លើយតប។ ដូច្នេះយើងនឹងដាក់ជូននូវគំនិតមួយចំនួនទាក់ទងទៅនឹងប្រវត្តិសាស្ត្រនៅពេលនេះ ឬក៏រហូតដល់បញ្ចប់នៃសវនាការវគ្គទីមួយនេះ។ ដូច្នេះជំហររបស់សហព្រះរាជអាជ្ញា គឺថាតុលាការគប្បីបញ្ជាក់គាត់ថាតើគាត់នឹងប្រកាន់ជំហរដូចម្តេច ថានឹងគាត់ឆ្លើយតបទេនៅពេលដំណើរការវិវត្តន៍ទៅមុខ។

នៅក្នុងករណីនេះ គឺសហព្រះរាជអាជ្ញានឹងពិនិត្យមើលថាតើការបកស្រាយជាអវិជ្ជមានទៅលើគោលជំហរហ្នឹង ប្រកាន់ទៅលើចំណុចណា។ ដូច្នេះព្រះរាជអាជ្ញាសូមរក្សាសិទ្ធិត្រង់ចំណុចនេះ។

[១៣:៥៤:១២]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៥៥:២៦]

**ប្រធានអង្គជំនុំ៖**

បាទមុននឹងឈានដល់ទុកឱកាសឲ្យមេធាវី និងកូនក្តីរបស់គាត់លោក ខៀវ សំផន ពិភាក្សាគ្នាដើម្បីឆ្លើយតបទៅនឹងបញ្ហានេះ។ អង្គជំនុំជម្រះសូមឲ្យលោក ហ្សង់ម៉ាក ឡាវែន៍ ដែលអង្គជំនុំជម្រះបានប្រគល់ភារកិច្ចដល់គាត់ក្នុងការសួរដេញដោលចំពោះជនជាប់ចោទ ខៀវ សំផន ដើម្បីធ្វើការបង្ហាញនូវឯកសារនៅក្នុងសំណុំរឿង ដែលពាក់ព័ន្ធទៅនឹងប្រវត្តិសាស្ត្របក្សកុម្មុយនីស្តកម្ពុជាជាមុនសិន។

សូមអញ្ជើញលោក ហ្សង់ម៉ាក!

[១៣:៥៦:២១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ ខៀវ សំផន! មានបញ្ហាអីទៅ?

**លោក ខៀវ សំផន៖**

សូមគោរពលោកប្រធាន!

**ប្រធានអង្គជំនុំ៖**

លោកអាចអង្គុយបាន អង្គុយនិយាយ អនុញ្ញាតឲ្យអង្គុយក្នុងការនិយាយ អាចអង្គុយបានមិនបាច់ងើបឈរទេ។

[១៣:៥៦:៤៦]

**លោក ខៀវ សំផន៖**

បាទ សូមគោរពលោកប្រធាន! ខ្ញុំបាទបានជម្រាបតាំងពីថ្ងៃ១៣ ធ្នូ ម្ល៉េះ ថាខ្ញុំសូមមិនទាន់ឆ្លើយនឹងសំណួរអ្វីទាំងអស់។ ហើយខ្ញុំមិនមានន័យអីថែមថយលើសេចក្ដីថ្លែងការណ៍របស់ខ្ញុំថ្ងៃ១៣ ធ្នូ នោះទេ។ អាហ្នឹងខ្ញុំសូមជម្រាបបញ្ជាក់ថែមប៉ុណ្ណឹង។ ដូច្នេះលោក សូមទោសលោកមេធាវី ឡាវ៉ែន ដើម្បីកុំឲ្យខាតពេលលើកសំណួរអីវែងឆ្ងាយ ខ្ញុំសូមជម្រាបថា ខ្ញុំមិនមានអីថែមថយទៀតទេ ក្រៅពីសេចក្ដីថ្លែងការណ៍ ដែលខ្ញុំបានធ្វើរួចហើយនោះ កាលពីថ្ងៃ១៣ ធ្នូនោះ។ បាទ សូមអរគុណ។

[១៣:៥៧:៤៧]

**ប្រធានអង្គជំនុំ៖**

បាទអរគុណនូវបញ្ហានេះ ប៉ុន្តែមែនរឿងចប់ត្រឹមនេះទេ នូវមានការដាក់ឯកសារដែលពាក់ព័ន្ធនឹងឯកសារនេះនៅចំពោះមុខភាគី ដោយអង្គជំនុំជម្រះដែលចៅក្រមទទួលបន្ទុក និងដាក់។ អម្បាញ់មិញនេះបានជាយើងពាក់ព័ន្ធនឹងបញ្ហានេះ ដោយសារយោបល់របស់មេធាវីការពារក្ដីលោកចង់បានពេលវេលាពិភាក្សាជាមួយលោក។ អង្គជំនុំជម្រះក៏បានឃើញដែរ នៅពេលដែលការដែលបំណងលើកមតិយោបល់នេះ គឺស្របគ្នា លោកក៏មានបំណងនិយាយ ហើយនិងមេធាវីរបស់លោកមានបំណងនិយាយ។ អ៊ីចឹងហើយបានជាអង្គជំនុំជម្រះផ្ដល់លទ្ធភាពទៅឲ្យមេធាវីរបស់លោកនិយាយមុន។

[១៣:៥៨:៣៩]

ដូច្នេះ សិទ្ធិរបស់លោកនៅស្ងៀមមិនឆ្លើយតបតាមកាលៈទេសៈ តាមសំណួរ ឬក៏ទាំងមូល អង្គជំនុំជម្រះបានជម្រាបរួចហើយ អំពីសិទ្ធិជនជាប់ចោទចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នៅទីនេះ គឺចាប់តាំងពីដើមដំបូងនៃការប្រាប់អំពីបទចោទ និងសិទ្ធិរបស់ជនជាប់ចោទចំពោះមុខអង្គជំនុំជម្រះ។

ជាកិច្ចបន្តអង្គជំនុំជម្រះសូមប្រគល់វេទិកាទៅលោក ហ្សង់ម៉ាក ដើម្បីបន្តកិច្ចដំណើរការនីតិវិធី។

**ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៖**

សូមអរគុណលោកប្រធាន។ សូមការបញ្ជាក់មួយ។

**ប្រធានអង្គជំនុំ៖**

ម៉េចទៅ? សូមអញ្ជើញលោកមេធាវីការពារក្ដី!

[១៣:៥៩:៣៧]

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំយល់ថា វាជាការចាំបាច់ ដើម្បីឲ្យខ្ញុំបានជួបពិភាក្សាជាមួយ លោក ខៀវ សំផន ជាមុនសិន មុនឹងលោកចៅក្រម ឡាវែន៍ ដាក់សំណួរ។ ដោយហេតុថា លោក ខៀវ សំផន គាត់បានប្រកាសរួចហើយថា គាត់នឹងមិនឆ្លើយតបអ្វីទេ ដល់អីចឹងការដាក់សំណួរមកវានាំឲ្យអត់ ប្រយោជន៍ អត់បានពិភាក្សាដដែល។

[១៤:០០:០៦]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនបានមានការសួរដេញដោលអីទេ។ អង្គជំនុំជម្រះគ្រាន់តែពន្យល់អំពីកិច្ចដំណើរ ការនីតិវិធីនាពេលនេះ ហើយនិងផែនការរបស់អង្គជំនុំជម្រះ ដែលនឹងដាក់ឯកសារចំពោះមុខភាគីពាក់ ព័ន្ធនឹងអង្គហេតុដែលបានចោទប្រកាន់ ហើយបានលើកមកដេញដោលនៅវគ្គទីមួយនេះ ដែលពាក់ព័ន្ធ ទៅនឹងជនជាប់ចោទ ខៀវ សំផន។

កិច្ចពិភាក្សានេះគឺអង្គជំនុំជម្រះពន្យល់ជាមុនសិន បើយល់ហើយស្តាប់សិន រួចសឹមពិភាក្សា ឬក៏ មិនបាច់ពិភាក្សាទេ បង្ហាញជំហរច្បាស់លាស់ ដើម្បីអង្គជំនុំជម្រះប្រគល់-- ផ្តល់ពេលវេលាសមស្រប សម្រាប់កិច្ចពិភាក្សារវាងលោកជាមួយនិងកូនក្តីរបស់លោក។ សូមអញ្ជើញ!

[១៤:០១:០៩]

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ បញ្ហាត្រង់ថា លោក ខៀវ សំផន គាត់អាចមិនយល់ពី-- ថាតើត្រូវ ស្តាប់នូវបញ្ហាដែលលោកចៅក្រម ហ្សង់ម៉ាក នឹងដាក់នៅពេលនេះយ៉ាងម៉េច? ដូច្នេះនៅពេលដែលយើង ពិភាក្សាគ្នា ខ្ញុំអាចផ្តល់យោបល់ផ្សេងៗទាក់ទងទៅនឹងសិទ្ធិ ដែលគាត់អាចប្រើប្រាស់បានចំពោះបញ្ហា ដែលត្រូវលើកដាក់ដោយលោកចៅក្រម ហ្សង់ម៉ាក។ ដូច្នេះ ខ្ញុំបាទមិនសូមពេលច្រើនទេ អាចត្រឹមតែ ១០នាទីក៏បានដែរ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះអង្គជំនុំជម្រះពន្យល់សិន អំពីរបៀបរបបនៃកិច្ចដំណើរនីតិវិធី និងទៅមុខ ដើម្បីឲ្យ លោកហ្នឹងទៅពិភាក្សាហ្នឹងបញ្ហាអី ដែលអង្គជំនុំជម្រះនឹងដំណើរការនៅពេលខាងមុខ។ តើរក្សាសិទ្ធិនៅ ស្ងៀម ឬក៏ត្រូវតទល់ជាមួយនឹងភស្តុតាងដែលអង្គជំនុំជម្រះបង្ហាញនេះ។

សូមអញ្ជើញលោក ហ្សង់ម៉ាក!

[១៤:០២:១៦]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ដូច្នេះពេលនេះគឺគ្រាន់តែជាការពន្យល់បំភ្លឺ ខ្ញុំនឹងមិនសួរសំណួរភ្លាមៗទេ។ ខ្ញុំគ្រាន់តែបំភ្លឺ អ្វីដែលខ្ញុំចង់ពន្យល់បង្ហាញនោះគឺថា អង្គជំនុំជម្រះនឹងពិចារណាទៅលើឯកសារមួយចំនួនដែលបានដាក់បញ្ចូលទៅក្នុងសំណុំរឿងរួចហើយ។ ហើយឯកសារទាំងអស់ហ្នឹងគឺអង្គជំនុំជម្រះយល់ឃើញថា វាមានភាពជាប់ពាក់ព័ន្ធ ហើយយើងនឹងបង្ហាញនៅក្នុងអង្គសវនាការ ហើយនឹងបង្ហាញជូនលោក ខៀវ សំផន។ ហើយលោក ខៀវ សំផន ក៏គាត់មានលទ្ធភាពក្នុងការប្រតិកម្មតបទៅនឹងឯកសារទាំងនោះ ហើយនិងផ្តល់នូវបទអត្ថាធិប្បាយ ហើយអ្វីដែលអង្គជំនុំជម្រះ-- នេះជាអ្វីដែលអង្គជំនុំជម្រះចង់ធ្វើនៅពេលនេះ។ ហើយខ្ញុំសូមបញ្ជាក់ជូនផងដែរ ថាឯកសារទាំងអស់នេះភាគច្រើនពាក់ព័ន្ធទៅនឹងសេចក្តីប្រកាស ឬក៏សេចក្តីថ្លែងការណ៍របស់លោក ខៀវ សំផន ឬក៏ពាក់ព័ន្ធទៅនឹងសំណេរ ឬឯកសារសរសេរដែលជាលោក អ្នកនិពន្ធនេះគឺជា ខៀវ សំផន ហើយដាក់ចូលទៅក្នុងសំណុំរឿង។ ហើយក្នុងសៀវភៅទាំងអស់នោះ មានព័ត៌មានមួយចំនួនធំដែលមានសារៈសំខាន់សម្រាប់អង្គជំនុំជម្រះ ដើម្បីឲ្យដឹងថាតើព័ត៌មានដែលសរសេរនៅក្នុងសៀវភៅនោះ អាចទុកចិត្តបានដែរឬទេ? ហើយថាតើជនជាប់ចោទនោះគាត់ចាត់ទុកថាព័ត៌មានទាំងអស់នោះមានតម្លៃដែរឬទេ? ឬមានសុពលភាពឬទេ? បាទនេះគឺជាគោលបំណងនៃសវនាការនៅរសៀលនេះ។ ដូច្នេះ ខ្ញុំសង្ឃឹមថា ការពន្យល់នេះអាចបំភ្លឺឲ្យបានយល់ច្បាស់អំពីកម្មវត្ថុនៃសវនាការនៅរសៀលនេះ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:០៤:៣៦]

**ប្រធានអង្គជំនុំ៖**

តទៅនេះ អង្គជំនុំជម្រះអនុញ្ញាតឲ្យមេធាវី ខៀវ សំផន ហើយនិងលោក ខៀវ សំផន ពិភាក្សាគ្នា។

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។

[១៤:០៥:០០]

*(មេធាវីជាតិ និងជនជាប់ចោទ ខៀវ សំផន ពិភាក្សាគ្នា)*

[១៤:០៧:២១]

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ក្រោយពីការពិភាក្សាជាមួយលោក ខៀវ សំផន គាត់បានបញ្ជាក់ប្រាប់ខ្ញុំថា គាត់នឹងមិនឆ្លើយនូវសំណួរទាំងអស់ ដែលនឹងដាក់មកទាក់ទងនឹងប្រវត្តិសាវតារនេះបាទ។

សូមអរគុណ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ដូច្នេះឯកសារដែលនឹងអាននេះ គឺនឹងអាចអនុញ្ញាតឲ្យលោក ខៀវ សំផន ផ្លាស់ប្តូរយោបល់របស់គាត់ហើយនិងយល់អំពីកម្មវត្ថុនៃគោលបំណងនៃសវនាការនេះ។

**ស៖** ចៅក្រម យើងទាំងអស់នៅទីនេះ គឺថានៅដើម្បីវាយតម្លៃទាំងភស្តុតាងដោះបន្ទុក និងដាក់បន្ទុក។ ដូច្នេះ ក្នុងចំណោមភស្តុតាងទាំងអស់នៅក្នុងសំណុំរឿងនោះ គឺជាកំណត់ហេតុដែលស្តាប់ចម្លើយសួរចម្លើយលោក ខៀវ សំផន ផ្ទាល់តែម្តង និងជាពិសេសគឺឯកសារដែលមាននៅក្នុងលេខ D46 និង D47 នៃសំណុំរឿង។ ហើយការសួរចម្លើយនេះ គឺត្រូវបានប្រព្រឹត្តទៅនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី១៣-១៤ ខែធ្នូ ឆ្នាំ២០០៧។

[១៤:០៨:៥៧]

ឧទាហរណ៍ ខ្ញុំអាចអាននូវឃ្លាមួយនៃការសួរចម្លើយលោក ខៀវ សំផន ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី១៣ ខែធ្នូ ដែលមានលេខ D46 ជាភាសាបារាំងទំព័រទី៤ ហើយគេសួរសំណួរទៅកាន់លោក ខៀវ សំផន ពាក់ព័ន្ធនឹងមុខងារដែលលោកបានកាន់នៅសម័យខ្មែរក្រហម។ លោកបានឆ្លើយថា៖ “នៅពេលដែលខ្ញុំនៅតែបន្ត លាក់ខ្លួននោះគឺខ្ញុំទៅភ្នំឱរ៉ាល់ ជាមួយនឹង តាម៉ុក គឺថាប្រហែលជានៅខែកញ្ញា ឆ្នាំ៧០ ហើយយើងបានឆ្លងកាត់តាមទន្លេសាប ដើម្បីទៅកាន់ស្ទឹងជីនិត។ ហើយនៅទីនោះហើយដែលយើងបានជួបលោក ប៉ុល ពត ហើយនិងលោក នួន ជា។ ខ្ញុំឃើញគាត់នៅពេលនោះគឺជាលើកដំបូងហើយ កាលពីមុនមក ប៉ុល ពត គឺស្ថិតនៅក្នុងតំបន់រតនគិរី ហើយគាត់បានចាកចេញនៅពេលក្រោយរដ្ឋប្រហារឆ្នាំ(១៩)៧០។ ហើយនៅពេលដែលខ្ញុំបាន គាត់ជួបគាត់នោះ ខ្ញុំបានដឹងថា ប៉ុល ពត ដែលកាលនោះ ខ្ញុំបានស្គាល់តែឈ្មោះ សាឡុត ស ទេ គឺជាលេខាបក្ស។ គាត់បានស្នើឲ្យយើងផ្តល់អត្តសញ្ញាណ ហើយនិងបញ្ជាក់អំពីដើមកំណើតនៃសង្គម។ ដូច្នេះ ខ្ញុំបានឆ្លើយតបទៅគាត់ថា ខ្ញុំជាបញ្ញាជន

ហើយ ប៉ុល ពត បានឆ្លើយមកខ្ញុំវិញថា ខ្ញុំគឺកូននៃវណ្ណៈសក្តិភូមិរលំរលាយ។ ខ្ញុំដឹងថា គ្រួសារខ្ញុំក្រ ហើយខ្ញុំក៏នឹកឃើញដែរថា លោក នួន ជា បានសួរទៅ ប៉ុក ហើយគាត់បានឆ្លើយថា ពីព្រោះថាគាត់បានស្អប់នូវរបបរាជាធិបតេយ្យ ហើយលោក នួន ជា បានឆ្លើយថា "ទេ"។ លោកគឺជាសក្តិភូមិដែលជាដែលប្រឆាំងទៅនឹងនរោត្តម ហើយ ប៉ុក កុមារ (ស៊ីក) ក៏ខឹង នួន ជា យ៉ាងខ្លាំងនៅពេលនោះ"។

[១៤:១១:១៦]

ខ្ញុំកត់សម្គាល់ឃើញថា នៅក្នុងកំណត់ហេតុសួរចម្លើយនេះ បន្តទៅដល់ថ្ងៃស្អែកទៀតនោះគឺ D47។ លោក ខៀវ សំផន ជាថ្មីម្តងទៀតគាត់បានប្រើពាក្យថា "ជាកូននៃវណ្ណៈសក្តិភូមិដែលរលំរលាយ"។ ហើយនៅក្នុងការសួរចម្លើយទីពីរនេះ នៅទំព័រទីប្រាំមួយ គាត់បានឆ្លើយ-- និយាយថាតួនាទីរបស់ខ្ញុំគឺថា គ្រាន់តែជាតួនាទីប្រូត្រកូលប៉ុណ្ណោះ។ គឺយើងទាំងអស់គ្នាដឹងថា ប៉ុល ពត គឺគាត់បានចាត់ទុកខ្ញុំថា "ជាកូនរបស់វណ្ណៈសក្តិភូមិដែលរលំរលាយ" ហើយដែលជាបញ្ញាជនស្នេហាជាតិដែលមិនមានឥទ្ធិពលអ្វីទាល់តែសោះនៅក្នុងសង្គម។

ដូច្នេះលោក ខៀវ សំផន ទាំងអស់គឺគ្រាន់តែជាឯកសារដំបូងដែលអង្គជំនុំជម្រះយល់ឃើញថាមានភាពពាក់ព័ន្ធនឹងលោក ហើយមានលក្ខណៈសមស្រប ដូច្នេះយើងជាការសំខាន់ណាស់ដែលអង្គជំនុំជម្រះចង់បាននូវសេចក្តីអត្ថាធិប្បាយពីលោក ហើយនិងចង់យល់ឲ្យបានច្បាស់ថា១ ចំពោះលោកមានន័យថាម៉េចដែលមានន័យថា "ជាកូននៃវណ្ណៈសក្តិភូមិដែលរលំរលាយ" នោះ?

តើលោកចង់ធ្វើបទអត្ថាធិប្បាយអ្វីទៅលើចំណុចនេះ ឬក៏លោកគិតថាលោកមិនធ្វើអ្វីទេនោះ? ឬក៏លោកបដិសេធមិនឆ្លើយតែម្តង?

[១៤:១២:៥៥]

**លោក ខៀវ សំផន៖**

**ឆ៖** អ្វីដែលខ្ញុំបានឆ្លើយនៅមុខចៅក្រម ហើយដែលលោកចៅក្រមស៊ើបអង្កេត ហើយដែលលោកចៅក្រម ម៉ាក់ឡាវែន៍ ទើបបានមានប្រសាសន៍អម្បាញ់មិញនេះ វាបញ្ជាក់នូវអ្វីដែលខ្ញុំបានថ្លែងកាលពីថ្ងៃ១៣ ធ្នូ អំពីលក្ខខណ្ឌដែលខ្ញុំ គេឲ្យខ្ញុំចូលបក្ស។ លក្ខខណ្ឌដែលគេឲ្យខ្ញុំចូលគណៈមជ្ឈិមគឺគេអនុគ្រោះទេ។ ខ្ញុំមិនពេញលក្ខណៈសម្បត្តិ ដើម្បីចូលបក្ស ចូលមជ្ឈិមទេ ព្រោះខ្ញុំជាកូនសក្តិភូមិ ហើយខ្ញុំអត់-- ភ្ជាក់ខ្លួនព្រឺតដែរ ពេលដែលគេនិយាយថា "សក្តិភូមិ"។ អាហ្នឹងបញ្ជាក់នូវទស្សនៈរបស់បក្សកុម្មុយនីស្តកម្ពុជាចំពោះរូបខ្ញុំ។ អាហ្នឹងដែលខ្ញុំបាន វាស្របនឹងការដែលខ្ញុំបានជម្រាបនៅថ្ងៃ១៣ ធ្នូ

ហ្នឹងហើយ។ គ្រាន់តែបញ្ជាក់អ៊ីចឹង ដូច្នេះ ខ្ញុំអត់មានថែមថយអីទេ។

[១៤:១៤:១២]

ហើយខ្ញុំសង្ឃឹមថា ឯកសារនេះដែលខ្ញុំថ្លែងការណ៍ ហើយឯកសារដែលខ្ញុំឆ្លើយនៅមុខសហចៅក្រមស៊ើបអង្កេតនេះ វាមានប្រយោជន៍ដើម្បី អស់លោក លោកស្រី លោកចៅក្រមទាំងអស់យកទៅវិនិច្ឆ័យអំពីការដែលចោទទៅក្រោយៗទៀតថា ខ្ញុំជាអ្នកដឹកនាំធំនៅក្នុងបក្សកុម្មុយនីស្តកម្ពុជាអីៗនោះ ក៏លោកសង្ឃឹមថា ឯកសារទាំងអស់នេះ វាមានប្រយោជន៍ដើម្បីលោកយកទៅគិតពិចារណាហើយ។ បាទ សូមអរគុណ។

[១៤:១៥:១០]

**ស៖** ខ្ញុំគិតថាអ្វីដែលអាចជួយយើងបាននោះ គឺសូមលោកឆ្លើយទៅនឹងអ្វីដែលខ្ញុំចង់ចោទសួរ។ ហើយនៅក្នុងចំណោមសំណួរទាំងអស់នេះ ខ្ញុំសូមលើកឡើងវិញនូវអ្វីដែល-- ខ្ញុំសួរអំមិញនេះ គឺថាខ្ញុំចង់ដឹងថា តើពាក្យថា កូននៃវណ្ណៈសក្តិភូមិរលំរលាយនោះ មានន័យថាយ៉ាងម៉េចដែរ? ហេតុអីបានជាលោកទៅជាកូននៃវណ្ណៈសក្តិភូមិដែលរលំរលាយនោះទៅវិញ? តើដោយសារតែគ្រួសាររបស់លោក ឬក៏ការសិក្សារបស់លោក តើលោកចង់យោងទៅលើអ្វីមួយដែរ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបាទសូមបញ្ជាក់សាឡើងវិញពីជំហររបស់លោក ខៀវ សំផន។ លោកបានបញ្ជាក់ថា លោកនឹងមិនឆ្លើយអ្វីបន្ថែមទៀតទេ អម្បាញ់មិញនេះ ក៏លោកបានបញ្ជាក់ដែរ។ ក៏ប៉ុន្តែខ្ញុំសូមលើកសំណូមពរមួយ បើសិនជាលោកចៅក្រម ឡាវែន៍ គាត់មានបំណងចង់ឲ្យលោក ខៀវ សំផន ឆ្លើយនូវសំណួរណានោះ សូមអាចឲ្យខ្ញុំបាទអាចសុំជាសំណួរហ្នឹងឲ្យហើយមក ដើម្បីខ្ញុំអាចពិភាក្សាជាមួយនឹងលោក ខៀវ សំផន។ បាទ សូមអរគុណ។

[១៤:១៦:៤៤]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

តើលោកមានបានមើលឃើញថា មានបទប្បញ្ញត្តិណាមួយនៅក្នុងវិធានផ្ទៃក្នុងដែលថាត្រូវខ្ញុំផ្តល់សំណួរមុនទៅដល់កូនក្តីរបស់លោកទេ? ខ្ញុំគិតថា ខ្ញុំមានការកត់សម្គាល់ផ្សេងទៀត ពាក់ព័ន្ធនឹងកំណត់

ហេតុនេះ ហើយខ្ញុំនឹង-- យើងនឹងត្រឡប់មកនិយាយទៅលើកំណត់ហេតុនេះវិញ នៅពេលក្រោយទៀត ពីព្រោះថាវាពាក់ព័ន្ធទៅនឹងកាលបរិច្ឆេទដែលលោក ខៀវ សំផន បានប្រកាសថាបានជួយលោក ប៉ុល ពត និង នួន ជា ជាលើកដំបូង។ ដូច្នេះ នឹងមានឯកសារផ្សេងទៀតដែលយើងនឹងពិនិត្យមើលទាំងអស់គ្នាដែលពាក់ព័ន្ធទៅនឹងចំណុចនេះ។ ខ្ញុំចង់បញ្ជាក់ជូនថា ក្នុងកំណត់ហេតុសួរចម្លើយនៅថ្ងៃទី១៣ ខែធ្នូនេះ លោក ខៀវ សំផន គាត់បាននិយាយពាក់ព័ន្ធទៅនឹងកាលបរិច្ឆេទដែលបានប្រព្រឹត្តទៅនៅមហាសមាជនៃបក្សកុម្មុយនីស្តកម្ពុជា។ ដូច្នេះ ខ្ញុំគិតថាលោក ខៀវ សំផន នោះ គាត់ប្រហែលជាមិនចង់ធ្វើបទអត្ថាធិប្បាយអីផ្សេងទៀតទេ មែនទេ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី!

[១៤:១៨:០២]

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។

ខ្ញុំសូមធ្វើការកត់សម្គាល់តូចមួយទៅលើការកត់សម្គាល់របស់លោកចៅក្រម ឡាវែន៍ អម្បាញ់មិញ។ លោកបង្ហាញថា តើមាននីតិវិធី ឬបទបញ្ញាផ្ទៃក្នុងណាដែលតម្រូវឱ្យលោកត្រូវតែបង្ហាញសំណួរទៅដល់កូនក្តី ទៅដល់លោក ខៀវ សំផន នោះ។ ខ្ញុំបាទសូមបញ្ជាក់ថា មូលហេតុនៃការស្នើសុំសំណួរនេះ គឺដោយសារលោក ខៀវ សំផន គាត់បានបដិសេធមិនព្រមឆ្លើយ បើគាត់មិនឆ្លើយហើយ ហើយលោកសួរដដែលៗថែមទៀត អាហ្នឹងវាទៅជា ដូចជាអាចថាជារំខានមិនគោរពសិទ្ធិនៃការមិនឆ្លើយរបស់លោក ខៀវ សំផន។ ហើយការស្នើសុំសំណួរនេះ វាគ្រាន់តែជាការសម្រួលមួយ សម្រួលយ៉ាងម៉េច? ក្រែងថាលោកទាមទារឱ្យមានការពន្យល់នូវចំណុចណា ហើយប្រសិនជាសំណួរទាំងអស់នោះបានដាក់ជូនមក ហើយលោក ខៀវ សំផន គាត់យល់ថា គាត់អាចឆ្លើយបាន គាត់ឆ្លើយ។ អានោះ វាជាការផ្តល់ឱ្យគ្នាទៅវិញទៅមក។ ដូច្នេះ គ្មានកាតព្វកិច្ចណាតម្រូវឱ្យលោក ខៀវ សំផន ឆ្លើយទេ ពីព្រោះវាសិទ្ធិរបស់គាត់។ ហើយសិទ្ធិហ្នឹង គឺមានសរសេរនៅក្នុងទាំងរដ្ឋធម្មនុញ្ញ ទាំងនៅក្នុងច្បាប់នៃតុលាការរបស់យើងនេះ។ ដូច្នេះ បើសិនជាលោកចៅក្រមទាមទារឱ្យសួរហើយសួរទៀត ឱ្យឆ្លើយ វាហាក់ដូចជាមិនផ្តល់សិទ្ធិឱ្យគាត់អីចឹង។ បាទ សូមអរគុណ។

[១៤:១៩:៤៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម។ ជនជាប់ចោទដូចប្រកាន់ជំហរច្បាស់លាស់ហើយ ហើយនីតិវិធីរបស់អង្គជំនុំជម្រះគួរតែត្រូវបានដាក់នូវឯកសារចំពោះមុខភាគី ចំពោះករណីដែលពាក់ព័ន្ធនឹងអង្គហេតុសម្រាប់ធ្វើសវនាការវគ្គមួយនេះតែម្តងទៅ ដើម្បីបញ្ចប់កិច្ចដំណើរការនីតិវិធី ហើយចំពោះករណីនេះ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ឯកសារផ្សេងទៀត ដែលអង្គជំនុំជម្រះយល់ឃើញថាមានភាពពាក់ព័ន្ធនោះ គឺជាសៀវភៅមួយក្បាល ដែលមានចំណងជើងថា "ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់" ឯកសារនេះ គឺមាននៅក្នុងសំណុំរឿងហើយ គឺលេខ ES4.23 ហើយលេខ ERN ជាភាសាបារាំងគឺមានដូចតទៅ 00595363-00595329 ERN ជាភាសាអង់គ្លេស 00103717-00103801 ហើយ ERN ជាភាសាខ្មែរ 00103802 ទៅដល់ 00103899។

ដូច្នេះ សៀវភៅនេះគឺត្រូវបានសន្មតថាសរសេរដោយលោក ខៀវ សំផន ផ្ទាល់ ហើយនៅក្នុងសៀវភៅនោះ គឺមានការចង្អុលបង្ហាញអំពីព័ត៌មានមួយចំនួនដែលមានសារៈសំខាន់ និងមានលក្ខណៈគួរឲ្យចាប់អារម្មណ៍ ជាពិសេសនៅទំព័រទី២៧ ជាភាសាបារាំង លេខ ERN ជាភាសាបារាំង 00595388 ERN ជាភាសាអង់គ្លេស 00103729 ដល់ 00103730 ហើយ ERN ជាភាសាខ្មែរ 00103815 ទៅដល់ 00103816។

[១៤:២២:៤១]

នេះជាការដកស្រង់មួយដែលពាក់ព័ន្ធទៅនឹងការបញ្ចប់នៃសកម្មភាពរបស់លោក ខៀវ សំផន ក្នុងឋានៈជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម។ ហើយគាត់បាននិយាយបែបដូច្នេះថា៖ "នៅពេលដែលមានកលល្បិចមួយចំនួន ខ្ញុំត្រូវបានដកចេញពីមុខងាររបស់ខ្ញុំ ហើយខ្ញុំមិនអាចបញ្ចប់ការងាររបស់ខ្ញុំបានទេ"។

[១៤:២៣:១០]

ដូច្នេះ ប៉ុន្មានខែមុននោះ នៅក្នុងពេលមានបាតុកម្មរបស់សិស្សនៅសៀមរាប លន់ នល់ បានបង្កើតបញ្ជីមួយដែលមានមនុស្ស៣៤នាក់ ដែលនឹងត្រូវចាប់ខ្លួន។ ប៉ុន្តែ អន្តរាគមន៍របស់សម្តេច សីហនុ គឺថាបានចៀសវាងមិនឲ្យមានការចាប់ខ្លួននេះ ហើយបន្ទាប់ក៏មានកលល្បិចផ្សេងមួយទៀត គឺសមាជជាតិ បានដកនូវសេចក្តីទុកចិត្តមួយពី ខៀវ សំផន ដោយលើកហេតុផលថាមានការឡើងថ្លៃសាច់គោ

ប៊ីស្មោក។ ហើយដូច្នេះ សភាជាតិនោះក៏មិនបានអនុម័តទៅលើសេចក្តីសម្រេចនេះដែរ។

ដូច្នេះខ្ញុំចង់សួរថា តើគាត់ជាអ្នកសរសេរឃ្លានេះដែរឬទេ ដើម្បីឲ្យគាត់បញ្ជាក់អំពីខ្លឹមសារបន្ថែម ឬក៏គាត់ត្រូវពន្យល់អ្វីបន្ថែមទៀតនោះ។ ប្រសិនបើខ្ញុំមិនត្រូវបានសួរ មិនអនុញ្ញាតឲ្យសួរសំណួរនោះទេ។

**លោក ខៀវ សំផន៖**

**ផ៖** បាទសូមគោរពលោកប្រធាន ខ្ញុំសូមឆ្លើយនឹងសំណួររបស់លោក ម៉ាកឡាវែន៍ លោកចៅក្រម ម៉ាកឡាវែន៍ ថាខ្ញុំបានសរសេរយ៉ាងនេះមែន ហើយចំណុចដែលខ្ញុំបានសរសេរនេះ វាស្របដូចខ្ញុំបានប្រកាសកាលពីថ្ងៃ១៣។ ហើយខ្ញុំប្រកាសថ្ងៃ១៣ ធ្នូ នោះ វាច្បាស់ជាងដែលខ្ញុំសរសេរទៀត។

ដូច្នេះ ខ្ញុំអត់មានអីថែមថយទៀតទេ។

[១៤:២៤:៤៣]

**ស៖** សូមអរគុណ។ នៅទំព័រទី៣៣ និងទំព័រ៣៤ នៃសៀវភៅដែលនេះ ហើយលេខ ERN ជាភាសាបារាំង 00595393 ដល់ 00599395 ហើយ ERN ជាភាសាអង់គ្លេស 00103732 ទៅដល់ 00103733 ERNជាភាសាអង់គ្លេស 00103732 ទៅដល់ 00103733 ERNជាភាសាខ្មែរ 00103818 ទៅដល់ 00103819។ ហើយពេលនេះគឺជាការដកស្រង់មួយ ដែលពាក់ព័ន្ធនឹងហេតុការណ៍មួយដែលកើតឡើងនៅឆ្នាំ១៩៦៦ ហេតុការណ៍នេះគឺពាក់ព័ន្ធទៅនឹងរដ្ឋប្រហារ។

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបាទសូមអនុញ្ញាតលោកប្រធានមេត្តាកុំឲ្យលោកចៅក្រម ឡាវែន៍ លើកតាំងជាសំណួរចំពោះលោក ខៀវ សំផន តទៅទៀត ហើយដោយលោកបានបញ្ជាក់ជាច្រើនដង ហើយថាលោកសុំមិនឆ្លើយតបទៅនឹងសំណួរទាំងអស់នោះទេ។ ដូច្នេះការព្យាយាមតាំងសំណួរដដែលនេះអាចធ្វើឲ្យគាត់ភ័ន្តច្រឡំ ហើយឆ្លើយនូវចំណុចណាដែលធ្វើឲ្យប៉ះពាល់នៅការប្រើប្រាស់សិទ្ធិដែលជាសិទ្ធិស្របច្បាប់របស់គាត់។ សូមអរគុណ។

[១៤:២៧:២៤]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ខ្ញុំនឹងអាននូវសម្រង់នូវសៀវភៅដែលខ្ញុំបានបញ្ជាក់អម្បាញ់មិញនេះ "លន់ នល់ គឺថាគាត់ដេរបិទដៃផង និងចូលរួមពត់ផងទៅម្ខាង ហើយគាត់ប្រមូលពួកជើងដែលប្រឆាំងនយោបាយ ហើយ

ដោយសារតែមានជំនួយពីអាមេរិកកាំង ហើយក៏មានគិតទៅដល់រហូតអ្នករដ្ឋការតូចតាច និងបញ្ញាជនមួយចំនួនដែលកាន់តែមានច្រើនទៅៗ ដែលកាន់តែអស់សង្ឃឹមកាន់តែខ្លាំងៗទៅ ដោយសារអំពើពុករលួយដែលនៅក្នុងប្រទេស។ ដូច្នេះ ក៏មានកើតនៅសង្គ្រាមក្រោមដីមួយប្រឆាំងនឹងសម្តេចនរោត្តមសីហនុ ហើយលេចចេញជាពាក្យចចាមអារ៉ាមសម្ភុយសម្តេច ហើយនិងព្រះរាជវង្សានុវង្សពាសពេញទីក្រុងភ្នំពេញ។

គាប់ជួនពេលនោះត្រូវដល់ពេលរៀបចំជ្រើសតាំងសភាពជាថ្មីម្តងទៀត អ្នកដែលសរសេរសំបុត្រមកសុំសម្តេចឲ្យជ្រើសរើសខ្លួនជាបេក្ខជនសង្គមរាស្ត្រនិយមនោះ គឺក៏មានច្រើន។ គឺថាមានការរិះគន់ចំពោះការអន្តរាគមន៍ផ្ទាល់របស់សម្តេច ក្នុងការជ្រើសរើសបេក្ខជននៅពេលបោះឆ្នោតកាលពីលើកមុននោះ។ ហេតុដូច្នេះហើយក៏ព្រះអង្គក៏ឈប់ជ្រើសរើសដោយផ្ទាល់ព្រះអង្គដូចមុនៗទៀត ហើយក៏សម្រេចព្រះទ័យបើចំហឲ្យសមាជិកសង្គមរាស្ត្រនិយមឈរឈ្មោះប្រកួតប្រជែងគ្នា។ ប្រហែលមកពីព្រះអង្គនឿយណាយនឹងការរិះគន់ក៏មិនដឹង ឬក៏មកពីព្រះអង្គពិបាកព្រះទ័យក្នុងការសម្រេចជ្រើសរើសអ្នកណា ចោលអ្នកណាក៏មិនដឹង។ ក្នុងសភាពការណ៍បែបនេះ បើព្រះអង្គជ្រើសរើសអ្នកនេះ ច្បាស់ជានាំឲ្យមានអ្នកដែលមិនត្រូវបានជ្រើសរើសមិនបានសប្បាយចិត្ត ហើយក៏ងាកដៃចូលជើងទៅជាមួយនឹងអ្នកដែលប្រឆាំងជាមួយព្រះអង្គជាមិនខាន។ ទោះបីជាយ៉ាងណាក៏ដោយ ការដែលព្រះអង្គសម្រេចព្រះទ័យយ៉ាងនេះនឹងនាំឲ្យមានបច្ច័យយ៉ាងធ្ងន់ធ្ងរដល់ព្រះអង្គផង និងចំពោះប្រទេសជាតិផង។ ពីព្រោះថាជាយូរឆ្នាំណាស់ហើយ ពួក លន់ នល់ បានជ្រកពួនក្រោមស្លាកសង្គមរាស្ត្រនិយម ហើយដោយយកលេសថាប្រឆាំងពួកកុម្មុយនីស្តបានរៀបចំ ដើម្បីឡើងកាន់អំណាចដោយខ្លួនឯង។ សម្តេចទ្រង់មិនបានជ្រាបទេ ពួក លន់ នល់ បានប្រមូលចៅហ្វាយខេត្ត ចៅហ្វាយស្រុក និងមេឃុំស្ទើរតែទាំងអស់។ ដូច្នេះសភាដែលកើតចេញពីការបោះឆ្នោតសេរីនៅឆ្នាំ៦៦ នោះ ការពិតគឺ “ការបោះឆ្នោតដោយសេរីនេះ” (គឺដាក់នៅក្នុងអព្ភនរៈ) សភាដែលកើតចេញពីការបោះឆ្នោតដោយសេរីនៅឆ្នាំ៦៦ នេះ គឺថាជាសភាដែល លន់ នល់ រៀបចំដោយផ្ទាល់ដៃ ហើយគឺសភានេះហើយដែលពេលបួនឆ្នាំក្រោយមកបានបោះឆ្នោតទម្លាក់ព្រះអង្គជាឯកច្ឆន្ទ។

ខ្ញុំមិនសួរសំណួរលោកទេ ខ្ញុំគ្រាន់តែចង់សួរថា តើលោកមានអ្វីដែលត្រូវអត្ថាធិប្បាយទៅលើឃ្លាដែលលោកបានសរសេរដោយផ្ទាល់នេះដែរឬទេ?

**លោក ខៀវ សំផន៖**

**ផ៖** បាទ សូមគោរពលោកប្រធាន ខ្ញុំបាទអត់មានអត្ថាធិប្បាយអីថែមពីលើខ្ញុំសរសេរនោះទេ។

[១៤:៣០:៣៨]

**ស៖** ហើយបន្ទាប់មកទៀត ក៏លោកបានសរសេរថា៖ “ទោះបីជាមានសញ្ញាមួយដែលបញ្ជាក់ថា ព្រះអង្គ គាត់បាត់បង់នូវការត្រួតត្រាទៅលើរដ្ឋាភិបាល។ គឺមានជាលក្ខណៈក្រុមតូចៗ គឺគេនិយាយអំពី ស៊ូហាតូ និង ណាស៊ុនស៊ុន កម្ពុជា ដែលនិយាយសំដៅទៅលើរដ្ឋប្រហារបង្ហូរឈាមខែមីនា ឆ្នាំ១៩៥៦ នៅឥណ្ឌូនេស៊ី។ ហើយនៅក្នុងកាលៈទេសៈបែបនោះ គឺមានការចោទប្រកាន់ទៅលើ ហ៊ូ យន់ ហើយនិង ខ្ញុំផ្ទាល់ គឺជាដើមហេតុនៅក្នុងរឿងនេះ ហើយដែលត្រូវបង្ហាញខ្លួននៅចំពោះមុខតុលាការយោធា។ ដូច្នេះ យើងខ្ញុំក៏គិតថា យើងខ្ញុំលែងមានសន្តិសុខទៀតហើយនៅភ្នំពេញ។ ដូច្នេះហើយបានជាយើងសុខចិត្ត ទទួលយកតាមការស្នើរបស់បក្សកម្មុយនីស្តកម្ពុជា ដែលជួយឲ្យយើងខ្ញុំរត់គេចខ្លួនទៅពួកកន្លែងណាមួយ នៅតាមជនបទ។

[១៤:៣១:៤៥]

ការស្នើឡើងនេះ ធ្វើតាមសំបុត្រមួយ ដែលមានការវិភាគអំពីសភាពការណ៍ល្អិតល្អន់បង្គួរ ដែល នាំឲ្យយើងមិនមានការមន្ទិលសង្ស័យណាមួយចំពោះម្ចាស់នោះទេ។ ម្យ៉ាងទៀត អ្នកដែលនាំយកសំបុត្រ នេះមកឲ្យយើងខ្ញុំ គឺយើងខ្ញុំទាំងពីរនាក់ក៏ស្គាល់ច្បាស់ គឺជាមនុស្សដែលចាស់ទុំ ហើយគួរឲ្យគោរព ហើយដែលគាត់ជាមនុស្សចាស់ផង ហើយនិងគាត់បានចូលរួមយ៉ាងសកម្មទៅនឹងការប្រជុំដែលរៀបចំ ដោយសមាគមសិស្ស អតីតសិស្សនៃវិទ្យាល័យស៊ីសុវត្ថិ ដែលយើងបានចូលរួមផងដែរ។ ហើយនៅ ពេលយប់ដែលយើងត្រូវបានកំណត់នោះ គាត់បានជូនយើងតាមរថយន្តទៅតាមផ្លូវលេខ៣ ហើយបាន ដាក់យើងនៅខាងកើតអង្គតាសោមបន្តិច ហើយនៅទីនេះមានកសិករមួយក្រុមនៅចាំយើងខ្ញុំ”។

ដូចគ្នាដែរ តើលោក ខៀវ សំផន លោកមានប្រតិកម្ម ឬក៏មានយោបល់អ្វីទៅលើឃ្លាទាំងអស់ នេះទេ?

[១៤:៣២:៤៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ជាថ្មីម្តងទៀត ខ្ញុំសូមបញ្ជាក់ថា លោក ខៀវ សំផន គាត់កំពុងតែប្រើប្រាស់សិទ្ធិមិនឆ្លើយតប ហើយសិទ្ធិនេះគឺត្រូវតែគោរព ពីព្រោះច្បាប់របស់យើងបានផ្តល់សិទ្ធិនេះឲ្យទៅគាត់។ ហើយអ្វីដែលខ្ញុំឃើញថាថ្មី ដែលជាការតាំងសំណួររបស់លោកចៅក្រម ឡាវែន៍ នោះគឺស្នើឲ្យលោក ខៀវ សំផន ផ្តល់យោបល់ ឬក៏ធ្វើអត្ថាធិប្បាយ។

[១៤:៣៣:៣៣]

អានេះវាគ្រាន់តែជា ការផ្លាស់ប្តូរពីរបៀបសំណួរ ការតាំងសំណួរហ្នឹងធ្វើគ្រាន់តែមិនឲ្យចេញជាសំណួរ ឲ្យទៅជាប្រយោគធម្មតា ហើយដើម្បីឲ្យលោក ខៀវ សំផន ឆ្លើយតប។ អ៊ីចឹងបានន័យថា សិទ្ធិក្នុងការមិនឆ្លើយហ្នឹង មិនត្រូវបានអនុវត្តទេនៅពេលនេះ គឺដដែល ដូចគ្នាដដែល។ បានន័យថា លោក ខៀវ សំផន ត្រូវតែឆ្លើយតប។ អ៊ីចឹងការធ្វើដដែលៗ បែបនេះ វាបង្ហាញថា យើងកំពុងតែបង្ខំឲ្យលោក ខៀវ សំផន ឆ្លើយតប។ សូម្បីតែគាត់បានបញ្ជាក់ម្តងហើយម្តងទៀតថា គាត់ប្រើប្រាស់សិទ្ធិមិនឆ្លើយតបនេះ។ ដូច្នេះ ខ្ញុំបាទសូមលោកចៅក្រម ក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិចារណាចំណុចនេះឲ្យច្បាស់ ហើយកុំបង្កើតសំណួរ ឬក៏ឲ្យលោក ខៀវ សំផន ធ្វើអត្ថាធិប្បាយទៅលើចំណុចទាំងឡាយណាទៀតទាំងអស់។ សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៣៥:៤០]

**ប្រធានអង្គជំនុំ៖**

លោក ហ្សង់ម៉ាក បន្តនីតិធី ហើយតាមជំហររបស់ជនជាប់ចោទនិងមេធាវីបានបង្ហាញច្បាស់លាស់ហើយ សូម្បីតែឲ្យគាត់ធ្វើអត្ថាធិប្បាយ ឬក៏សង្កេតទៅលើឯកសារភស្តុតាងដែលអង្គជំនុំជម្រះដាក់ចំពោះមុខភាគីក៏គាត់បានលះបង់សិទ្ធិ មិនប្រើប្រាស់នូវសិទ្ធិធ្វើការអត្ថាធិប្បាយ ឬសង្កេតលើឯកសារទាំងអស់នេះទេ។ ដូច្នេះកុំឲ្យមានការពេល ពន្យារពេលវេលាក្នុងកិច្ចដំណើរការសវនាការយូរសូមឲ្យលោកចៅក្រម ធ្វើការបង្ហាញការដាក់ឯកសារចំពោះមុខភាគី ដោយបង្ហាញអំពីកម្រិតត្រឹមតែអត្តសញ្ញាណឯកសារ ដើម្បីពន្លឿនកិច្ចដំណើរការនេះ។ ហើយយើងសង្កេតឃើញច្បាស់លាស់ហើយថា គាត់បានលះបង់សិទ្ធិនៅក្នុងការឆ្លើយតបនឹងសំណួរនោះជារឿងមួយ។ ឥឡូវសូម្បីតែធ្វើការសង្កេត ឬក៏ធ្វើការអត្ថាធិប្បាយនូវអ្វីដែលជាការបង្ហាញរបស់អង្គជំនុំជម្រះចំពោះខ្លឹមសារនៃស្នាដៃនិពន្ធរបស់គាត់ ក៏គាត់មិន--

លះបង់សិទ្ធិ បានន័យថាមិនធ្វើការសង្កេតដែរ។

[១៤:៣៧:០៥]

ដូច្នេះមិនគប្បីបន្តកិច្ចដំណើរការនីតិវិធីរបៀបនេះតទៅទៀតទេ។ សូមបញ្ចប់ត្រឹមនេះ ហើយសូមលោកចៅក្រមបន្តកិច្ចដំណើរការនីតិវិធីនៃការដាក់ឯកសារ ចំពោះមុខភាគីដោយអង្គជំនុំជម្រះ។

សូមអរញ្ជើញ!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា យើងអាចនិយាយបានថាជនជាប់ចោទគឺ គាត់មិនចង់ប្រើប្រាស់ឱកាសដែលផ្តល់ឲ្យគាត់នោះ ក្នុងការធ្វើបទអត្ថាធិប្បាយទៅលើឯកសារដែលបានដាក់ចូលទៅក្នុងសំណុំរឿងរួចទៅហើយ។ ដូច្នេះ ខ្ញុំបញ្ជាក់ថា នៅក្នុងសៀវភៅដែលនេះ ដែលមានចំណងជើងថា “ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនិងជំហរសេចក្តីរបស់ខ្ញុំជាបន្តបន្ទាប់” ហើយគឺជាពិសេសនៅទំព័រ ៤៦ ជាភាសាបារាំង។ បន្ទាប់មកគឺទំព័រទី៥៣ ពាក់ព័ន្ធនឹងការចាកចេញរបស់ ខៀវ សំផន ហើយនិងសមមិត្តរបស់គាត់ទៅភ្នំឱរ៉ាល់ បន្ទាប់ពីការប្រកាសពីរដ្ឋប្រហារ ហើយនិងឯកសារមួយទៀតគឺឯកសារដែលមានលេខ D213.2 ដែលជាសៀវភៅផ្ទាល់ ដែលសរសេរដោយលោក ខៀវ សំផន តែម្តង គឺមានចំណងជើងថា “ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា ពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ”។ ហើយនៅក្នុងឯកសារនេះ នៅក្នុងសៀវភៅនេះគឺមានសម្រង់នៅទំព័រ១០ ជាភាសាបារាំងដែលពាក់ព័ន្ធទៅនឹងការកសាងអ្នកដែលចូលថ្មីរបស់បក្សកុម្មុយនីស្តកម្ពុជា។ ហើយនៅទំព័រទី៤២ និង៤៣ មានព័ត៌មានសំខាន់ៗពាក់ព័ន្ធទៅនឹងរដ្ឋប្រហារ ហើយនិងប្រតិកម្មរបស់ព្រះមហាក្សត្រ ហើយនិង ប៉ុល ពត ហើយឯកសារមួយទៀតនោះ គឺឯកសារលេខ D58។

[១៤:៣៩:២៣]

ឯកសារនេះគឺជាឯកសារភ្ជាប់ទៅនឹងលិខិតមួយដែលផ្ញើដោយមេធាវីការពារក្តីរបស់លោក ខៀវ សំផន នៅពេលចាប់ផ្តើមកិច្ចស៊ើបសួរ។ ហើយក្នុងឯកសារនោះលោក ខៀវ សំផន គឺចង់ដាក់ជូនទៅនឹងចៅក្រមស៊ើបអង្កេតនៅការពន្យល់បំភ្លឺមួយចំនួន ហើយក៏គាត់បានភ្ជាប់ទៅនឹងលិខិតរបស់គាត់នោះនៅការបកប្រែមួយគឺថា ការបកប្រែនៃសៀវភៅដែលបានលើកឡើងអម្បាញ់មិញនេះ គឺសៀវភៅ “ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា ពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ”។

[១៤:៤០:០០]

ហើយលេខ ERN ជាភាសាបារាំងមានដូចតទៅនេះ 00157640, 00157604 ERN ភាសាអង់គ្លេស 00170881 ដល់ 00170884 ERN ជាភាសាខ្មែរ 00157632 ដល់ 00157639។ ហើយឯកសារមួយទៀត ដែលមានភាពពាក់ព័ន្ធដែរនោះ ដែលមានលេខកូដ IS18.1 ឯកសារនេះមានចំណងជើងថា "អាសនៈរបស់កម្ពុជានៅក្នុងអង្គការសហប្រជាជាតិ" លេខ ERN ជាភាសាបារាំង និងភាសាអង់គ្លេស មានដូចតទៅនេះ 00068111 ទៅដល់ 00068129។ ហើយឯកសារនេះគឺមានតែការបកប្រែដោយផ្នែកតែប៉ុណ្ណោះជាភាសាខ្មែរ ដែលមានលេខកូដ 00290197 ទៅដល់ 00290198។

ហើយខ្ញុំសូមបញ្ជាក់ថា ឯកសារនេះកំពុងតែបកប្រែទៅជាភាសាខ្មែរ ចំពោះផ្នែកផ្សេងៗទៀត ហើយដើម្បីឲ្យមានការព័ត៌មានកាន់តែច្បាស់នោះ ឯកសារទាំងអស់នេះគឺត្រូវបានធ្វើឡើងដោយរណសិរ្សរួបរួមជាតិកម្ពុជា ហើយនៅពេលដែលរណសិរ្សរួបរួមជាតិកម្ពុជា ហើយនិងរណសិរ្សរួបរួមជាតិកម្ពុជាហ្នឹង ព្យាយាមទទួលបានភាពស្របច្បាប់របស់កម្ពុជា នៅចំពោះមុខអង្គការសហប្រជាជាតិ។

[១៤:៤២:១១]

ហើយមានឯកសារផ្សេងទៀតផងដែរ គឺឯកសារ D243/2.1 ជាទស្សនាវដ្តីទង់បដិវត្តលេខ៨ នៅឆ្នាំ១៩៧៥។ ហើយមាន D243/2.1.9 គឺជាទស្សនាវដ្តីទង់បដិវត្តដដែល ហើយលេខពិសេសខែធ្នូ ឆ្នាំ៧៧ ហើយគឺផ្នែកដែលបានអានកាលពីព្រឹកមិញនេះ ដោយសហព្រះរាជអាជ្ញារួចមកហើយគឺពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជនចេញពីទីក្រុង។ ខ្ញុំសូមបញ្ជាក់ផងដែរថា ខ្ញុំនឹងផ្តល់ជូននូវឯកសារយោងផ្សេងទៀតនៅពេលក្រោយ គឺជាឯកសារមួយដែលជាអត្ថបទមួយនៃទស្សនាវដ្តីមួយដែលមានចំណងជើងថា "នូវែលឌុយកាំបូតស៍" ដំណឹងពីកម្ពុជាដោយទីភ្នាក់ងារសារព័ត៌មានកម្ពុជា" វាគឺជាបញ្ជីនៃសមាជិកកម្មាភិបាលរួបរួមជាតិ ហើយនិងសម្រង់សុន្ទរកថាដែលថ្លែងដោយលោក ខៀវ សំផន ក្នុងឱកាសផ្សេងៗគ្នា ជាពិសេសនៅពេលដែលលោកធ្វើដំណើរទស្សនៈកិច្ចទៅប្រទេសចិន ទៅកាន់កូរ៉េ ឬក៏វៀតណាម។ ដូច្នេះខ្ញុំគិតថា ខ្ញុំបានបញ្ជាក់ជូនចប់សព្វគ្រប់ហើយសូមអរគុណ។

[១៤:៤៣:៥២]

**ប្រធានអង្គជំនុំ៖**

បាទអរគុណលោកចៅក្រម។

*(ចៅក្រមពិភាក្សាគ្នា)*

សូមអញ្ជើញលោក!

[១៤:៤៤:៥៧]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ប្រហែលជានៅដំណាក់កាលនេះយើងត្រឡប់ទៅរកមតិយោបល់ពីដើមដែលថា យើងរហូតមកដល់ចុងបញ្ចប់នៃផ្នែកនេះ ហើយយើងនឹងចូលទៅដល់ប្រព័ន្ធរដ្ឋបាល ប្រហែលជាអាចដល់ពេលសមស្រប។ យើងនឹងអាចសួរទៅលោក ខៀវ សំផន និងមេធាវីរបស់គាត់ថាតើគាត់នឹងសួរ គាត់នឹងឆ្លើយនូវសំណួរនៅកន្លែងនោះឬអត់ ដែលភាគីផ្សេងៗក៏អាចនឹងចង់ដឹង បាទ ដែលថាអាចនឹងចូលដល់ពេលក្នុងពេលឆាប់ៗខាងមុខនេះ ចំពោះវគ្គដែលពិភាក្សាពីរឿងករណីនោះ។

[១៤:៤៥:៤០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៤៦:៣៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

បាទសូមអរគុណលោកប្រធាន។ ឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញាលើកអម្បាញ់មិញនេះ ខ្ញុំបាទគ្រាន់សូមទាញចំណាប់អារម្មណ៍ថា សវនាការយើងក្នុងដំណាក់កាលប្រវត្តិសាវតារលើកទីមួយនេះអាចចប់ ទើបយើងឈានចូលដល់ដំណាក់កាលបន្ទាប់ទៀត ដូចលោកប្រធានមានប្រសាសន៍ពីដំបូងហ្នឹង។ ដូច្នេះ បើសិនជាសាក្សីមិនទាន់បានឆ្លើយអស់នៅក្នុងដំណាក់កាលប្រវត្តិសាវតារនេះទេ ការចាត់នីតិវិធីបន្តទៅលើការគ្រប់គ្រងរដ្ឋបាលរបស់កម្ពុជាប្រជាធិបតេយ្យនុ៎ង មិនគួរត្រូវបានធ្វើទេ មិនគួរត្រូវធ្វើទេ។ ដោយហេតុថានៅក្នុងសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងនេះលេខ E155 នោះបញ្ជាក់យ៉ាងច្បាស់ថាទាល់តែចប់នៅក្នុងដំណាក់កាលដំបូងសិន។ ដូច្នេះ បើនៅពេលណាដែលចប់នៅក្នុងដំណាក់កាលប្រវត្តិសាវតារនេះ សឹមបន្តបាន។ សូមអរគុណ។

[១៤:៤៨:០៤]

**ប្រធានអង្គជំនុំ៖**

សូមអរគុណ។ ប៉ុន្តែគោលបំណងនៃសហព្រះរាជអាជ្ញារងអន្តរជាតិចង់ដឹងនោះបែបជាមិនមែនដូច្នេះទេ គឺចង់ដឹងថា នៅពេលខាងមុខឆាប់ៗនេះ បានន័យថាបន្ទាប់ពីកិច្ចដំណើរការសវនាការដេញ

ដោលលើអង្គហេតុប្រវត្តិសាស្ត្របក្សកុម្មុយនីស្ត ប្រវត្តិបក្សកុម្មុយនីស្តកម្ពុជាដែលហាក់ដូចជាកំពុងតែខិតទៅជិតដល់ការចប់នូវវគ្គនេះហើយ។ ហើយវគ្គទីពីរ នឹងសួរដេញដោលអំពីរចនាសម្ព័ន្ធរដ្ឋបាល។ សំណួរសួរថា តើជំហររបស់លោក នួន ជា (សុំទោស) ទៅលោក ខៀវ សំផន ថាតើគាត់រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប ឬក៏គាត់រក្សាសិទ្ធិនៅក្នុងការឆ្លើយតបទៅនឹងសំណួរដែលសួរ។ ហើយប្រសិនបើមាន-- គាត់ប្រើប្រាស់សិទ្ធិរបស់គាត់នៅក្នុងការឆ្លើយតបគឺសូមឲ្យលោក ខៀវ សំផន នឹងត្រៀមខ្លួនជាបណ្តើរៗទៅ ដើម្បីអាចចូលរួមនៅក្នុងការដេញដោលចំពោះអង្គហេតុនោះបាន។

តើលោក ខៀវ សំផន និងមេធាវីអាចបញ្ជាក់ជំហរចំពោះអង្គហេតុដែលនឹងគ្រោងធ្វើនៅពេលខាងមុខនេះបានដែរឬទេ?

[១៤:៤៩:៤៤]

**លោក គង់ សំអុន៖**

បាទសូមអរគុណលោកប្រធាន។ហើយសូមអរគុណនិងដំបូន្មានរបស់តំណាងអយ្យការដែរ ខាងយើងមុខតែធ្វើហើយ ព្រោះអានេះជាតួនាទី បើសិនជាត្រូវដល់ដំណាក់កាលនោះលោក ខៀវ សំផន នឹងឆ្លើយនឹងថ្លែងទៅតាមអ្វីដែលលោកចង់បង្ហាញអង្គជំនុំជម្រះនៅពេលនោះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ម៉េចទៅលោក ខៀវ សំផន? អង្គហេតុលើកក្រោយហ្នឹង គឺអង្គជំនុំជម្រះមានគម្រោងផែនការក្នុងការធ្វើសវនាការអំពីអង្គហេតុរចនាសម្ព័ន្ធរដ្ឋបាលកម្ពុជាប្រជាធិបតេយ្យ។ តើខ្លួនលោកផ្ទាល់នេះ តើលោកប្រកាន់ជំហរយ៉ាងម៉េច? ប្រកាន់ជំហរដូចលើនេះនៅស្ងៀមមិនឆ្លើយតប ឬក៏ប្រើសិទ្ធិរបស់លោកក្នុងការឆ្លើយតបទៅនឹងសំណួរដេញដោលផ្សេងៗពីភាគី ពីអង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងអង្គហេតុនៅវគ្គទីពីរនេះ។

សូមអញ្ជើញមេធាវី!

លោកមេធាវីស្តាប់បញ្ហាឲ្យបាន គឺដោយសារបញ្ហាទីមួយនេះ លោក ខៀវ សំផន បានបង្ហាញជំហរនៅស្ងៀមមិនឆ្លើយតប ប៉ុន្តែចំពោះអង្គហេតុបន្ទាប់ យើងមិនធ្វើស្អែក ឬអាទិត្យក្រោយនេះទេ។ មានន័យថា នៅពេលដែលអង្គជំនុំជម្រះកំណត់ថាអង្គហេតុនៅវគ្គទីមួយបានចប់ហើយ យើងឈានចូលការពិភាក្សាដេញដោលអង្គហេតុទីពីរ ដូចដែលអង្គជំនុំជម្រះបានចេញអនុស្សរណៈជម្រាបជូនដល់ភាគីរួចហើយ។ សំណួរសួរថា ដល់ពេលដំណាក់កាលនៃការសួរដេញដោលអង្គហេតុវគ្គពីរ ស្តីពីរចនាសម្ព័ន្ធ

របស់រដ្ឋបាលកម្ពុជាប្រជាធិបតេយ្យនោះ តើលោក ខៀវ សំផន ប្រកាន់ជំហរយ៉ាងដូចម្ដេច? តើលោកនៅតែប្រកាន់ជំហរថានៅស្ងៀមមិនឆ្លើយតប ឬក៏ប្រើសិទ្ធិរបស់គាត់ក្នុងការឆ្លើយតបនៅក្នុងអំឡុងពេលនៃកិច្ចពិភាក្សាដេញដោលពាក់ព័ន្ធនឹងអង្គហេតុ ដែលអង្គជំនុំជម្រះនឹងគ្រោងនឹងលើកមកធ្វើសវនាការនាពេលខាងមុខ គឺអង្គហេតុសម្រាប់វគ្គទីពីរនៃដំណាក់ដំបូងនៃដំណើរការសំណុំរឿង ០០២/០១ នេះ ដើម្បីកុំចៀសវាងនិយាយដដែលៗ ឲ្យច្បាស់លាស់ ពីព្រោះងាយស្រួលក្នុងការរៀបចំផែនការក្នុងការគ្រប់គ្រងដឹកនាំសវនាការ ដោយសារសំណុំរឿងក្ដីហ្នឹងវាធំធេង ហើយវាមានលក្ខណៈលំបាកស្មុគស្មាញ។

[១៤:៥៣:២២]

អ៊ីចឹងហើយបានជាភាគីតែងតែមានការផ្ដល់ព័ត៌មាន ផ្ដល់ដំណឹងគ្នាជាមុនទៅវិញទៅមក ដើម្បីឲ្យកិច្ចដំណើរការប្រព្រឹត្តទៅដោយឆាប់រហ័ស និងមានប្រសិទ្ធភាព។

**លោក គង់ សំអុន៖**

បាទសូមអរគុណលោកប្រធាន។ ការពិតទៅខ្ញុំបាទបានស្ដាប់ច្បាស់ហើយ យល់ច្បាស់ហើយបញ្ហានេះ ហើយខ្ញុំបាទសុំពេលអាចពីរនាទី ដើម្បីជួបជាមួយលោក ខៀវ សំផន មុននឹងគាត់ឆ្លើយ។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត សូមអញ្ជើញ!

[១៤:៥៦:២២]

**លោក ខៀវ សំផន៖**

សូមគោរពលោកប្រធាន សូមគោរពលោកស្រី អស់លោកចៅក្រមទាំងអស់។ អំពីសំណួរដែលលោកសហព្រះរាជអាជ្ញាបានលើកឡើងអម្បាញ់មិញនេះ ខ្ញុំសូមទោស ខ្ញុំឆ្លើយមិនទាន់បានទេ ចាំខ្ញុំគិតពិចារណាសិន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកលោក ខៀវ សំផន។

ដោយតាមគម្រោងផែនការនៃកិច្ចដំណើរការដេញដោលសម្រាប់ថ្ងៃនេះ គឺអង្គជំនុំជម្រះគ្រោងធ្វើការដេញដោលចំពោះជនជាប់ចោទ ខៀវ សំផន។ ប៉ុន្តែដោយហេតុលោក ខៀវ សំផន បានរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប។ ដូច្នេះកិច្ចដំណើរការពិភាក្សាដេញដោលសម្រាប់ថ្ងៃនេះ ឃើញថាវាលឿនតាម

លើសពីផែនការពេលវេលាដែលបានគ្រោងទុក។ ហើយដូច្នេះ អង្គជំនុំជម្រះសវនាការសម្រាប់ថ្ងៃនេះ គឺត្រូវចប់ត្រឹមប៉ុណ្ណេះ។ ប៉ុន្តែមុននឹងបញ្ចប់ មុននឹងឈប់សម្រាកអង្គជំនុំជម្រះសាលាដំបូងសូមជម្រាបជូនដំណឹងដល់ភាគីនៃរឿងក្តី និងសាធារណជនថា នៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅក្នុងសប្តាហ៍ក្រោយ ចាប់ពីថ្ងៃចន្ទ ទី១៦ ដល់ថ្ងៃព្រហស្បតិ៍ ទី១៩ ខែមករា ឆ្នាំ២០១២ លោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ មានធុរៈមិនអាចចូលរួមក្នុងកិច្ចដំណើរការសវនាការបានទេ។ ហើយបញ្ហានេះបន្ទាប់ពីយើងខ្ញុំពិគ្រោះយោបល់ជាមួយនឹងចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងយើងសម្រេចចាត់តាំងលោកស្រី ក្លូឌា ហ្វេនស៍ ឲ្យជំនួសកន្លែងលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ក្នុងអំឡុងពេលដែលលោកស្រីអវត្តមានរហូតដល់ពេលលោកស្រី ស៊ីលវៀ ខាតវ៉ាយថ៍ មានវត្តមាន និងអាចបំពេញការងារចូលរួមសវនាការនៅអង្គជំនុំជម្រះសាលាដំបូងវិញបាន។

[១៤:៥៩:០៦]

បញ្ហាទីពីរ ក៏សូមជម្រាបជូនផងដែរថា នៅក្នុងកិច្ចដំណើរការសវនាការនៅក្នុងសប្តាហ៍ក្រោយនេះ អង្គជំនុំជម្រះគ្រោងនឹងដំណើរការសវនាការទាញហេតុផលផ្ទាល់មាត់លើឯកសារនានា។ គឺផែនការនេះ គឺធ្វើពេញមួយសប្តាហ៍តែម្តង គឺរយៈពេល៤ថ្ងៃ គឺថ្ងៃចន្ទ រហូតដល់ថ្ងៃព្រហស្បតិ៍។

ហេតុដូច្នេះសូមភាគី និងសាធារណជនជ្រាប។

ឥឡូវនេះកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ អង្គជំនុំជម្រះប្រកាសផ្អាកសវនាការត្រឹមនេះ ហើយសវនាការលើកបន្តធ្វើនៅព្រឹកថ្ងៃចន្ទ ទី១៦ ខែមករា ឆ្នាំ២០១២ ចាប់ពីម៉ោងប្រាំបួនព្រឹក។

ហេតុដូច្នេះ សូមភាគីនិងសាធារណជនជ្រាប។ អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងបីរូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយនិងឲ្យនាំខ្លួនគាត់ទាំងបីរូបត្រឡប់មកកាន់បន្ទប់សវនាការនេះនៅព្រឹកថ្ងៃស្អែក-- នៅព្រឹកថ្ងៃចន្ទទី១៦ ខែមករា ឆ្នាំ២០១២ ឲ្យបានមុនម៉ោង៩ព្រឹកជាកំណត់។ សូមសម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៥:០០ នាទី)*